ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការធានាគុណភាពអប់រំ
# នៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប

# THE SITUATION OF EDUCATION QUALITY ASSURANCE AT PROVINCIAL TEACHER TRAINING COLLEGE IN SIEM REAP PROVINCE

ម៉ៃ ខេង

MAY KHENG

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការធានាគុណភាពអប់រំ
# នៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប

# THE SITUATION OF EDUCATION QUALITY ASSURANCE AT PROVINCIAL TEACHER TRAINING COLLEGE IN SIEM REAP PROVINCE

ម៉ៃ ខេង

MAY KHENG

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២០-២០២២

គ្រូណែនាំគោល៖ ឯកឧត្តមបណ្ឌិត សិត សេង

គ្រូណែនាំរង៖ លោកបណ្ឌិត នួន វីរ៉ា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទសិក្សាស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ អាទិត្យ ១៣កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

**ហត្ថលេខា**

**ម៉ៃ ខែង**

# លិខិតបញ្ជាក់

**ឯកឧត្តមបណ្ឌិត សិត សេង** ជាគ្រូណែនាំគោល

**បណ្ឌិត នួន វីរ៉ា** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ម៉ៅ ខេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្ដីពី «**ស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

.................................... .................................

**ឯកឧត្តមបណ្ឌិត សិត សេង**

នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

**លោកបណ្ឌិត នួន វីរ៉ា**

នាយករងវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៣៧០២៥ អយក.ខុទក

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | ឈាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វ៉ៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប តេនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួលៈ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វេជអ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ..៣៧២៦..អយក.ឧទន**

(**ការសម្គាល់**)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២

អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# ឧទ្ទិសកថា

ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ **ម៉ៃ ខែង**

## សូមឧទ្ទិសស្នាដៃនិក្ខេបបទនេះជូនដល់ព្រះវិញ្ញាណក្ខន្ធចំពោះ

**សម្តេចព្រះសង្ឃរាជជោតញ្ញាណោ ជួន ណាត** ដែលព្រះអង្គបានពលីព្រះជន្មក្នុងបុព្វហេតុវិស័យសាសនា អក្សរសាស្ត្រខ្មែរ និងក្បួនច្បាប់អប់រំដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ។

**ព្រះបរមរតនកោដ្ឋ ព្រះបាទសម្តេច នរោត្តម សីហនុ** ព្រះវីរក្សត្រ ព្រះរាជបិតាឯករាជ្យបូរណភាពទឹកដី ដែលព្រះអង្គបានលះបង់ព្រះកាយពល នាំមកនូវឧត្តមប្រយោជន៍សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ជាពិសេសព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីប្រទេសនាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

សូមឧទ្ទិសស្នាដៃនេះ ប្រគេន ថ្វាយចំពោះបុព្វបុរសដែលជាបញ្ញាវន្តទាំងអស់បានពលីជីវិតដើម្បីប្រទេសជាតិមាតុភូមិ ការពារថែក្សានូវវិស័យសាសនា វិស័យអប់រំឱ្យបានរីកចម្រើនរហូតដល់សម័យបច្ចុប្បន្ន។

សូមដួងព្រះវិញ្ញាណក្ខន្ធរបស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ ព្រះបរមរតនកោដ្ឋបានយាងទៅកាន់ឋានសួគ៌ា ព្រមទាំងបុព្វការីជនទាំងអស់បានសោយសុខក្នុងសុគតិភព។

## សូមឧទ្ទិសស្នាដៃនិក្ខេបបទនេះជូនដល់វិញ្ញាណក្ខន្ធចំពោះ

**លោកឪពុក ម៉ៃ ឃឿន អ្នកម្តាយ យាន ទ៉ាន់** ដែលបានផ្តល់កំណើតកូន បានថែរក្សាបីបាច់កូនបានអប់រំទូន្មានប្រៀនប្រដៅកូន ព្រមទាំងឱ្យកូនបានរៀនសូត្ររហូតទទួលបានជោគជ័យ និងបានបម្រើការងារក្នុងក្របខណ្ឌរាជការជូនសង្គមជាតិ ដើម្បីអនាគតដ៏រុងរឿងរបស់កូន។

**លោកឪពុកក្មេក មាស អ៊ិរ អ្នកម្តាយក្មេក ត្នួន លេខ** ដែលបានអប់រំទូន្មានប្រៀនប្រដៅកូនដើម្បីអនាគតដ៏រុងរឿងរបស់កូន។

សូមវិញ្ញាណក្ខន្ធរបស់អ្នកមានគុណទាំងអស់ទៅបានសោយសុខក្នុងសុគតិភព។

# សេចក្តីថ្លែងអំណរគុណ

ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ **ម៉ៃ ខែង**

**សូមក្រាបថ្វាយបង្គំ**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមថ្លែងអំណរគុណព្រះរាជគុណ សម្តេចព្រះអម្ចាស់ជីវិតលើត្បូង ដែលបានបំពេញព្រះរាជសកម្មភាពដ៏ឧត្តុងឧត្តមថ្លៃថ្លា និងទឹកព្រះទ័យប្រកបដោយព្រះព្រហ្មវិហារធម៌ ដែលទ្រង់តែងតែលះបង់ព្រះកាយពល និងព្រះបញ្ញាញាណ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែរទូទាំងប្រទេស។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

- **ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា**
- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- **ថ្នាក់ដឹកនាំ នៃក្រសួងអប់រំ យុវជន និងកីឡា**

ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យខ្ញុំបាទបានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទា ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការសិក្សានិងការស្រាវជ្រាវរហូតទទួលបានជោគជ័យជាស្ថាពរ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- **ឯកឧត្តមបណ្ឌិត សិត សេង** គ្រូណែនាំគោល
- **លោកបណ្ឌិត នូវ វីរ៉ា** គ្រូណែនាំរង

ដែលតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការដឹកនាំ ផ្តល់គំនិត ណែនាំជាទ្រឹស្តីល្អៗ កែលម្អចំណុចខ្វះខាត ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត ផ្នែកបច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ ឯកឧត្តមបណ្ឌិត លោកបណ្ឌិតបានផ្តល់នូវឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងបានជួយបង្ហាញទិសដៅដល់រូបខ្ញុំហូតការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកនៃវិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ការអភិវឌ្ឍកម្មវិធីសិក្សា*
- **លោកបណ្ឌិត នួច វីរ៉ា** នាយករងនៃវិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ក្រមសីលធម៌វិជ្ជាជីវៈអ្នកដឹកនាំការងារអប់រំ* និង *ការពិនិត្យតាមដាន និងវាយតម្លៃ*
- **លោក ថៃ ហេង** នាយករងនៃវិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *មូលដ្ឋានគ្រឹះស្ថិតិអប់រំ*
- **លោកស្រី នូ ចន្ទី** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ចិត្តវិទ្យាអប់រំ*
- **លោកបណ្ឌិត ឈាង សទ្ធាត** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *វិធីសាស្ត្រស្រាវជ្រាវអប់រំ* និង *ការអប់រំ និងគោលនយោបាយអប់រំ* ព្រមទាំងបានផ្តល់ឯកសារជំនួយបន្ថែមពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនេះ
- **លោកបណ្ឌិត ម៉ម ចាន់សៀន** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *រដ្ឋបាលអប់រំ៖ ការកសាងផែនការ អនុវត្តផែនការ* និង *ការអប់រំនៅកម្ពុជា* ព្រមទាំងបានផ្តល់ឯកសារជំនួយបន្ថែម ពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនេះ
- **លោកបណ្ឌិត នី រដ្ឋា** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *សង្គមវិទ្យាអប់រំ* និង *ការគ្រប់គ្រងការបំពេញការងារក្នុងសាលារៀន*
- **លោក សៀង វាសនា** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ការគ្រប់គ្រងការបង្រៀន និងបច្ចេកវិទ្យាអប់រំ*
- **លោក សារី ពៅ** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ការគ្រប់គ្រងសម្ភារៈ និងថវិកាវិស័យអប់រំ*
- **ឯកឧត្តម នៀ សុផន** សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា *ការគ្រប់គ្រងធនធានមនុស្ស*

ដែលបានចំណាយពេលវេលាបង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់ ក្នុងពេលកំពុងសិក្សាកន្លងមក ជាពិសេសបានផ្តល់ឯកសារជាច្រើនល្អៗទាក់ទងនឹងប្រធានបទនិក្ខេបបទនេះ។

- លោក **ចាប រតនា** លោក **ខាង ចាន់ណាក់** លោកស្រី **ឯម សុភាលក្ខ័** ព្រមទាំងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ ដែលបានចំណាយពេលវេលាជួយសម្របសម្រួលជាមួយគ្រូដឹកនាំគោល គ្រូដឹកនាំរង ជាមួយនិស្សិតទាំងអស់ បានផ្តល់ឯកសារផ្សេងៗ រួមមាន លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ លិខិតឧទ្ទេសនាមគ្រូណែនាំគោល គ្រូណែនាំរង និងព័ត៌មានផ្សេងទៀតទាក់ទងនឹងវគ្គសិក្សានេះដល់ខ្ញុំបាទ ដោយមិនគិតពីការនឿយហត់ ព្រមទាំងបានផ្តល់ឯកសារជាល្អៗទាក់ទងនឹងប្រធានបទនិក្ខេបបទនេះ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- ភរិយា **មាស ដាវី**
- កូនប្រុស **ឃឿន សុវិជ្ជា**
- កូនស្រី **ឃឿន សុលក្ខណា**
- កូនស្រី **ឃឿន សុរក្សា**

ជាទីស្រឡាញ់ ដែលបានផ្តល់ឱកាស គាំទ្រ ជំរុញលើកទឹកចិត្តនៃដំណើរការសិក្សារបស់ខ្ញុំ ជួយឧបត្ថម្ភថវិកាថ្លៃសិក្សាចំនួន $ 1 500 (មួយពាន់ ប្រាំរយ ដុល្លារ) ស្មើនឹង ៦ ០០០ ០០០ រៀល (ប្រាំមួយលានរៀល) និងថវិកាចំណាយផ្សេងៗទៀតរហូតចប់ជាស្ថាពរប្រកបដោយជោគជ័យ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- លោក **លី ម៉ិនណា** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- លោក **ហុង ឧប្បលវណ្ណា** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- លោកស្រី **ថុន ស៊ីណា** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- លោក **ទេព គឹមហេង** ប្រធានការិយាល័យបឋមសិក្សា នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- លោក **ញ៉ឹក សាគុណា** ប្រធានការិយាល័យមធ្យមសិក្សា នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប

- **លោក ឡូន មិថុនា** ប្រធានការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- **លោក សាំង ទិន្ទ** ប្រធានការិយាល័យបុគ្គលិក និងបណ្ដុះបណ្ដាល នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- **លោក ឈុន ម៉ុណ្ណា** ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- **លោក ចៅ មុន្នីណា** អនុប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- **លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យ ព្រមទាំងបុគ្គលិកអប់រំពាក់ព័ន្ធ** នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប

ដែលបានចូលរួមសហការគាំទ្រលើកទឹកចិត្ត បានផ្ដល់ឯកសារពាក់ព័ន្ធ និងទិន្នន័យតាមរយៈកិច្ចសម្ភាសន៍ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- **លោក ឈត់ ឆៀង** នាយកនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប
- **លោកស្រី ហ៊ុន មករា** នាយិការងនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប
- **លោក ង៉ែ ចយ** នាយករងនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប
- **លោកគ្រូ អ្នកគ្រូឧទ្ទេស បុគ្គលិកអប់រំពាក់ព័ន្ធ ព្រមទាំងគរុសិស្សទាំងអស់** នៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប

ដែលបានសហការក្នុងការផ្ដល់ទិន្នន័យ និងចូលរួមឆ្លើយកម្រងសំណួរធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- **លោកបណ្ឌិត សុខ សិរី** និពន្ធនាយករងកាលិបត្រស្រាវជ្រាវអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជានិពន្ធនិយករងកាលិកបត្រអប់រំកម្ពុជានៃក្រសួងអប់រំ យុវជន និងកីឡា ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃធ្វើបទបង្ហាញ ស្តីពី **វិធីសាស្ត្រស្រាវជ្រាវអប់រំ** ក្នុងកម្មវិធីលើកកម្ពស់សមត្ថភាពនិស្សិត និងបុគ្គលិកវិទ្យាស្ថានជាតិអប់រំ លើផ្នែកសារៈសំខាន់នៃការស្រាវជ្រាវវិទ្យាសាស្ត្រ ប្រភពចំណេះដឹង ក្របខណ្ឌបញ្ញត្តិ និងបទពិសោធល្អនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងបានផ្តល់ឯកសារពាក់ព័ន្ធលើកិច្ចការស្រាវជ្រាវដើម្បីជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។
- **លោក ហ៊ុន សំអុល លោកស្រី ឈិត សូភី លោក នាង សុភាព** ដែលតែងតែផ្តល់ភាពរាក់ទាក់កក់ក្តៅ គំនិតល្អៗ និងជួយផ្តល់ឯកសារពាក់ព័ន្ធដើម្បីជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។
- **លោក ចាន់ សុភាព លោក អ៊ឹម សាលី** ព្រមទាំងសិស្សច្បងទាំងអស់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ដែលតែងតែផ្តល់ភាពរាក់ទាក់កក់ក្តៅ គំនិតល្អៗ និងជួយផ្តល់ឯកសារពាក់ព័ន្ធដើម្បីជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។
- **និស្សិតរួមថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩** ទាំងអស់ដែលតែងតែផ្តល់ភាពកក់ក្តៅរាក់ទាក់ ចែករំលែកបទពិសោធន៍ល្អៗតាមរយៈកិច្ចការស្រាវជ្រាវ ការពិភាក្សា ការផ្លាស់ប្តូរយោបល់ក្នុងពេលកំពុងសិក្សារយៈពេលពីរឆ្នាំកន្លងមកនេះ ព្រមទាំងបានផ្តល់ឯកសារផ្សេងៗដែលធ្វើឱ្យខ្ញុំមានកម្លាំងចិត្តតស៊ូពុះពាររាល់ការលំបាក ជម្នះរាល់ឧបស័គ្គនានាដើម្បីសម្រេចគោលដៅនៃការសិក្សា ស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

# មាតិកា

**ខ្លឹមសារ** **ទំព័រ**

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន**............ i

**លិខិតបញ្ជាក់**............ ii

**លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគការការពារនិក្ខេបបទ**............ iii

**ឧទ្ទិសកថា**............ vii

**សេចក្តីថ្លែងអំណរគុណ**............ viii

**មាតិកា**............ xiii

**បញ្ជីតារាង**............ xvi

**បញ្ជីរូបភាព**............ xvii

**បញ្ជីក្រាហ្វ**............ xviii

**ឧបសម្ព័ន្ធ**............ xix

**បញ្ជីអក្សរកាត់**............ xx

**មូលន័យសង្ខេប**............ xxii

ABSTRACT............ xxiv

**ជំពូក១ ៖ សេចក្តីផ្តើម**............ 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ............ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ............ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ............ 5

១.៤ សំណួរស្រាវជ្រាវ............ 5

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ............ 5

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ............ 6

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ............ 8

ជំពូក២ ៖ រំលឹកទ្រឹស្តី ....................................................................................9
២.១ និយមន័យនៃការធានាគុណភាពអប់រំ ....................................................................9
២.២ ប្រព័ន្ធអប់រំនៅកម្ពុជា ....................................................................................11
២.៣ ការកសាងសមត្ថភាពអ្នកអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ឆ្នាំ២០៣០ ....................12
២.៣.១ ការកសាងធនធានគ្រូបង្រៀននៅកម្ពុជា .........................................................14
២.៣.២ ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀននៅកម្ពុជា ..........................................15
២.៤ គោលការណ៍នៃការលើកកម្ពស់គុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ...............19
២.៤.១ និន្នាការអន្តរជាតិ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំគ្រូបង្រៀន ...............................19
២.៤.២ កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា ......................................20
២.៤.៣ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា .............................................................24
២.៤.៤ ស្តង់ដានាយកសាលារៀននៅកម្ពុជា ................................................................25
២.៥ ក្របខណ្ឌធានាគុណភាពអប់រំ ..........................................................................26
២.៥.១ គោលការណ៍នៃការធានាគុណភាពអប់រំ .........................................................30
២.៥.២ ការធានាគុណភាពអប់រំក្នុងការផ្តល់គុណវឌ្ឍិ .....................................................30
២.៥.៣ ការធានាគុណភាពអប់រំសម្រាប់គ្រឹះស្ថានមានវិជ្ជាជីវៈដំបូង ..................................33
២.៥.៤ កំណែទម្រង់សាលាគរុកោសល្យ ...................................................................33
២.៦ ការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានសិក្សា ..................................................34
២.៦.១ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់នាយកសាលាគរុកោសល្យ .........................37
២.៦.២ មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេស ...................................................41
២.៦.៣ ការចូលរួមពីភាគីពាក់ព័ន្ធវិស័យអប់រំ ............................................................44
ជំពូក៣ ៖ វិធីសាស្ត្រស្រាវជ្រាវ .................................................................................45
៣.១ គម្រោងស្រាវជ្រាវ ...........................................................................................45
៣.១.១ វិធីសាស្ត្របែបបរិមាណវិស័យ .........................................................................45

៣.១.២ វិធីសាស្ត្របែបគុណវិស័យ ........ 46
៣.២ ការប្រមូលទិន្នន័យ ........ 46
៣.៣ ឧបករណ៍ស្រាវជ្រាវ ........ 47
៣.៣.១ ការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ ........ 47
៣.៣.២ ការសិក្សាស្រាវជ្រាវបែបគុណវិស័យ ........ 51
៣.៤ ការជ្រើសរើសភាគសំណាក ........ 53
៣.៥ ការវិភាគទិន្នន័យ ........ 54
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 56
**ជំពូក៤ ៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ........ 58
៤.១ ឧបករណ៍វិភាគទិន្នន័យ ........ 58
៤.២ ការវិភាគទិន្នន័យរបស់អ្នកឆ្លើយសំណួរលើកម្រងសំណួរ ........ 58
៤.២.១ ផ្នែកទី១ ព័ត៌មានទូទៅ ........ 58
៤.២.២ ផ្នែកទី២ ស្ថានភាពនៃការធានាគុណភាពអប់រំ ........ 64
៤.៣ លទ្ធផលនៃការស្រាវជ្រាវលើស្ថានភាពនៃការធានាគុណភាពអប់រំ ........ 84
៤.៤ ការពិភាក្សានៃការអនុវត្តស្តង់ដាទាំង៩ពីស្ថានភាពនៃការធានាគុណភាពអប់រំ ........ 88
៤.៥ ឧត្តមានុវត្តន៍ក្នុងការអនុវត្តការធានាគុណភាពអប់រំ ........ 89
៤.៦ បញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ ........ 95
៤.៧ កាលានុវត្តភាពក្នុងការអនុវត្តការធានាគុណភាពអប់រំ ........ 95
**ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 98
៥.១ សេចក្តីសន្និដ្ឋាន ........ 98
៥.២ សំណូមពរ ........ 99
**ឯកសារយោង** ........ 103
**ឧបសម្ព័ន្ធ** ........ 110

# បញ្ជីតារាង

តារាងទី 1៖ ស្ថិតិបុគ្គលិកអប់រំតាមភូមិសិក្សា ពីឆ្នាំសិក្សា១៩៧៩-៨០ ដល់ឆ្នាំសិក្សា២០២០-២១......... 17

តារាងទី 2៖ ប្រព័ន្ធនៃការបណ្តុះបណ្តាលគ្រូនៅបណ្តាប្រទេសក្នុងអាស៊ាន ..................................... 22

តារាងទី 3៖ និយមន័យនៃវាក្យសព្ទសមត្ថភាព ........................................................................ 31

តារាងទី 4៖ តារាងគណនាពិន្ទុសរុប ................................................................................... 48

តារាងទី 5៖ តារាងពិន្ទុមធ្យមភាគស្តង់ដានីមួយៗ ................................................................... 49

តារាងទី 6៖ តារាងលទ្ធផលនៃការវាយតម្លៃ ......................................................................... 50

តារាងទី 7៖ ចំនួនសំណាកទិន្នន័យប្រមូលពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស ............................. 54

តារាងទី 8៖ ចំនួនសំណាកផ្តល់កិច្ចសម្ភាសន៍ ....................................................................... 54

# បញ្ជីរូបភាព


រូបភាពទី 1៖ ទិដ្ឋភាពក្លោងទ្វារមុខសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តសៀមរាប............................6

រូបភាពទី 2៖ ភាពទាក់ទងសហការគ្នារួមចំណែកដល់ការលើកកម្ពស់គុណភាពអប់រំ............................7

រូបភាពទី 3៖ ប្រព័ន្ធអប់រំនៅកម្ពុជា...............................................................................................11

រូបភាពទី 4៖ សមាសភាគទាំងប្រាំពីរនៃគុណភាពគ្រូបង្រៀនក្នុងយុគសម័យឌីជីថល ........................13

រូបភាពទី 5៖ ប្រព័ន្ធធានាគុណភាពអប់រំ ........................................................................................27

រូបភាពទី 6៖ គោលការណ៍ការអភិវឌ្ឍសមត្ថភាពប្រកបដោយវិជ្ជាជីវៈលើគ្រូបង្រៀន និងសិស្ស...........42

# បញ្ជីក្រាហ្វ

ក្រាហ្វទី 1៖ ទិន្នន័យតាមភេទរបស់គណៈគ្រប់គ្រងបានបំពេញកម្រងសំណួរ (គិតជា%) ................. 58

ក្រាហ្វទី 2៖ ទិន្នន័យតាមភេទរបស់គ្រូឧទ្ទេសបានបំពេញកម្រងសំណួរ (គិតជា%) ......................... 59

ក្រាហ្វទី 3៖ ទិន្នន័យតាមភេទរបស់គរុសិស្សបានបំពេញកម្រងសំណួរ (គិតជា%)............................ 59

ក្រាហ្វទី 4៖ ទិន្នន័យតាមអាយុរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេសបានបំពេញកម្រងសំណួរ (គិតជា%)..60

ក្រាហ្វទី 5៖ ទិន្នន័យតាមអាយុរបស់គរុសិស្សបានបំពេញកម្រងសំណួរ (គិតជា%)......................... 60

ក្រាហ្វទី 6៖ ការប្រៀបធៀបកម្រិតវប្បធម៌របស់គណៈគ្រប់គ្រង និងគ្រូឧទ្ទេស (គិតជា%) ................ 61

ក្រាហ្វទី 7៖ កម្រិតវប្បធម៌របស់គរុសិស្ស (គិតជា%) ................................................................ 62

ក្រាហ្វទី 8៖ ការប្រៀបធៀបបទពិសោធន៍ការងាររបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស (គិតជា%)............ 63

ក្រាហ្វទី 9៖ ការអនុវត្តស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (គិតជា%) ......................... 64

ក្រាហ្វទី 10៖ ការអនុវត្តស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង (គិតជា%) ............................... 66

ក្រាហ្វទី 11៖ ការអនុវត្តស្តង់ដា៣៖ បុគ្គលិកអប់រំ (គិតជា%) ......................................................... 68

ក្រាហ្វទី 12៖ ការអនុវត្តស្តង់ដា៤៖ កម្មវិធីអប់រំ (គិតជា%) ........................................................... 70

ក្រាហ្វទី 13៖ ការអនុវត្តស្តង់ដា៥៖ សេវាគរុសិស្ស/និស្សិត (គិតជា%).............................................. 72

ក្រាហ្វទី 14៖ ការអនុវត្តស្តង់ដា៦៖ ធនធានសិក្សា (គិតជា%) ......................................................... 74

ក្រាហ្វទី 15៖ ការអនុវត្តស្តង់ដា៧៖ ធនធានរូបវន្ត (គិតជា%)........................................................ 76

ក្រាហ្វទី 16៖ ការអនុវត្តស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ...................................................................... 78

ក្រាហ្វទី 17៖ ការអនុវត្តស្តង់ដា៩៖ ការធានាគុណភាពអប់រំផ្ទៃក្នុង ................................................. 80

ក្រាហ្វទី 18៖ ទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស បានបំពេញកម្រងសំណួរ (គិតជា%)...... 84

ក្រាហ្វទី 19៖ ទិន្នន័យពីថ្នាក់ដឹកនាំគ្រប់គ្រងអប់រំបានចូលរួមផ្តល់កិច្ចសម្ភាសន៍ (គិតជា%) ................ 85

ក្រាហ្វទី 20៖ ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ (គិតជាមធ្យមភាគ)....................... 86

ក្រាហ្វទី 21៖ លទ្ធផលសរុបនៃការអនុវត្តស្តង់ដាទាំង៩ពីស្ថានភាពនៃការធានាគុណភាពអប់រំ ............. 88

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី 1៖ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ........................................................ 110

ឧបសម្ព័ន្ធទី 2៖ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស ..............................................................118

ឧបសម្ព័ន្ធទី 3៖ កម្រងសំណួរសម្រាប់គរុសិស្ស ............................................................... 126

ឧបសម្ព័ន្ធទី 4៖ សំណួរសម្ភាសន៍ ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត បុគ្គលិកអ្នកពាក់ព័ន្ធ ......................... 134

ឧបសម្ព័ន្ធទី 5៖ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស ............................... 140

ឧបសម្ព័ន្ធទី 6៖ លិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់ ...................................... 143

ឧបសម្ព័ន្ធទី 7៖ សេចក្តីជូនដំណឹង ស្តីពីការការពារនិក្ខេបបទបញ្ចប់ការបណ្តុះបណ្តាល ................. 146

ឧបសម្ព័ន្ធទី 8៖ បំណែងចែកនិស្សិតឡើងការពារនិក្ខេបបទបញ្ចប់ ............................................. 147

ឧបសម្ព័ន្ធទី 9៖ សេចក្តីជូនដំណឹង ស្តីពីការប្រគល់សេចក្តីព្រាងនិក្ខេបបទលើកទី១ .......................151

ឧបសម្ព័ន្ធទី 10៖ កម្មវិធីបណ្តុះបណ្តាល និងកាលបរិច្ឆេទការពារបញ្ចប់វគ្គសិក្សា ........................... 152

ឧបសម្ព័ន្ធទី 11៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ............ 153

ឧបសម្ព័ន្ធទី 12៖ លិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ជូនដំណឹងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប.......................................................................... 154

ឧបសម្ព័ន្ធទី 13៖ លិខិតអនុញ្ញាតរបស់សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ................... 155

ឧបសម្ព័ន្ធទី 14៖ លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទ . 156

ឧបសម្ព័ន្ធទី 15៖ អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០....................... 159

ឧបសម្ព័ន្ធទី 16៖ ប្រកាសលេខ ២៩៥៤ អយក.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ........................ 163

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| % | Percent | ភាគរយ |
| ACC | Accreditation Committee of Cambodia | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| ASEAN | Association of Southeast Asian Nations | សហគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| BTEC | Battambang Teacher Education College | វិទ្យាស្ថានគរុកោសល្យបាត់ដំបង |
| CPD | Continuous Professional Development | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| DTMT | District Training and Monitoring Team | ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក |
| EQA | Education Quality Assurance | ការធានាគុណភាពអប់រំ |
| ESD | Education for Sustainable Development | ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ICT | Information and Communications Technology | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| INSET | In-Service Training | វិក្រឹតការគ្រូបង្រៀន |
| M | Mean | មធ្យមភាគ |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MISTI | Ministry of Industry, Science, Technology & Innovation | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| NGS | New Generation Schools | សាលារៀនជំនាន់ថ្មី |

| | | |
|---|---|---|
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| NQF | National Qualifications Framework | ក្របខណ្ឌគុណវុឌ្ឍិ |
| PISA | Programme for International Student Assessment | កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស |
| PISA-D | Programme for International Student Assessment for Development | កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ |
| PLC | Professional Learning Community | សមាគមសិក្សាវិជ្ជាជីវៈ |
| POE | Provincial Department of Education | មន្ទីរអប់រំ យុវជន និងកីឡា រាជធានី/ខេត្ត |
| PRESET | Pre-Service Teacher Training | ការបណ្តុះបណ្តាលដំបូង |
| PTEC | Phnom Penh Teacher Education College | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| PTTC | Provincial Teacher Training College | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |
| QA | Quality Assurance | ការធានាគុណភាព |
| QAF | Quality Assurance Framework | ក្របខណ្ឌធានាគុណភាព |
| S.D | Standard Deviation | គម្លាតស្តង់ដា |
| SBM | School Based Management | ការគ្រប់គ្រងតាមសាលារៀន |
| SDG 4 | Sustainable Development Goal 4 | ការអប់រំប្រកបដោយគុណភាព ទី៤ |
| TEC | Teacher Education College | វិទ្យាស្ថានគរុកោសល្យ |
| TPAP | Teacher Policy Action Plan | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |
| TQU | Teacher Qualifications Upgrade | ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន |

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៣ ចាប់ផ្តើមនៃការកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាល និងការជ្រើសរើសគ្រូបង្រៀនក្នុងគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពសមត្ថភាពស្របតាមក្រមសីលធម៌វិជ្ជាជីវៈ។ បន្ទាប់មកក្រសួងអប់រំបានកសាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយគ្រូបង្រៀននៅឆ្នាំ២០១៥ មានគោលបំណងធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់ (សាលាគរុកោសល្យ និងឧត្តមសិក្សា)។ ក្រសួងអប់រំក៏បានដាក់ចេញស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅឆ្នាំ២០១៦ មានគោលបំណងលើកស្ទួយគ្រូបង្រៀនឱ្យស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាននិងសង្គមផ្អែកលើពុទ្ធិ ជាពិសេសការបង្រៀននិងរៀនរបស់គ្រូបង្រៀនដល់សិស្សឱ្យទទួលបានលទ្ធផលសិក្សាមានកម្រិតសមស្របអាចទទួលយកបាន។

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប**" មានគោលបំណងឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ និងបង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ។

ការសិក្សាស្រាវជ្រាវនេះប្រើវិធីសាស្ត្របែបបរិមាណវិស័យ និងបែបគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យប្រមូលបានគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស មានចំនួនសំណាកសរុប១៧៦នាក់ស្មើ១០០ភាគរយ ក្នុងនោះប្រុស៦៥នាក់ស្មើ៣៦,៩៣ភាគរយ ស្រី១១១នាក់ស្មើ៦៣,០៧ភាគរយ និងទិន្នន័យតាមបែបគុណវិស័យតាមរយៈសំណួរសម្ភាសន៍ចំនួនសរុប០៦នាក់ស្មើ១០០ភាគរយ ក្នុងនោះប្រុស៥នាក់ស្មើ៨៣,៣៣ភាគរយ ប្រុសនាក់ស្មើ៣៣,៣៣ភាគរយ។

ជាលទ្ធផលនៃការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ បានបង្ហាញថាគណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៥ គម្លាតស្តង់ដា=១,០៧)។ គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៦ គម្លាតស្តង់ដា=

០,៨៣)។ ចំណែកគរុសិស្សបានផ្ដល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២០ គម្លាតស្តង់ដា=០,៥០)។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលបានបង្ហាញជូននេះ អ្នកសិក្សាស្រាវជ្រាវជ្រាវអាចធ្វើសន្និដ្ឋានបានថា ស្ថានភាពនៃការធានាគុណភាពអប់រំតាមការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំទទួលកម្រិតល្អគួរជាទីមោទនៈ (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០១)។ ប្រការនេះបង្ហាញថាសាលាគរុកោសល្យ និងវិក្រិតការខេត្តសៀមរាបបានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិភាគច្រើន។ ក្នុងន័យនេះគណៈគ្រប់គ្រងបានផ្សព្វផ្សាយចក្ខុវិស័យបេសកកម្មនិងគោលបំណង បានទូលំទូលាយដល់ភាគីពាក់ព័ន្ធមានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា ព្រមទាំងបានកំណត់តួនាទីនិងការទទួលខុសត្រូវ។ ចំពោះគ្រូឧទ្ទេសបានដើរតួនាទីអនុវត្តកិច្ចការផ្សេងកម្រិតល្អដែលគណៈគ្រប់គ្រងបានប្រគល់ភារកិច្ចឱ្យបានបំពេញភារកិច្ចរបស់ខ្លួន គឺដើម្បីលទ្ធផលសិក្សារបស់គរុសិស្សប្រកបដោយគុណភាព។ ចំណែកគរុសិស្សបានចូលរួមរាល់គ្រប់សកម្មភាពនៃការសិក្សាកម្រិតល្អណាស់តាមរយៈការណែនាំ ការខិតខំប្រឹងប្រែងរបស់សាលា និងភាគីពាក់ព័ន្ធ។

ទោះបីយ៉ាងណា លទ្ធផលនេះក៏នៅមានចំណុចប្រឈមមួយផងដែរដោយគុណវឌ្ឍិគ្រូឧទ្ទេសមួយចំនួនពុំទាន់ស្មើគ្នានៃកម្រិតកក្របខណ្ឌនៅឡើយ (ទាបជាងបរិញ្ញាបត្រមាន២,២៧ភាគរយ បរិញ្ញាបត្រមាន៦១,៣៦ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់មាន៣៤,០៩ភាគរយ និងខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់មាន២,២៧ភាគរយ)។ សមត្ថភាពដំបូងរបស់គរុសិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងកុំព្យូទ័រពុំទាន់ល្អប្រសើរនៅឡើយ។ បច្ចុប្បន្នប្រទេសកម្ពុជាស្ថិតក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.០ (Industry 4.0) ដែលទាមទារគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្សអនុវត្តឱ្យទាន់សង្គមបែបឌីជីថលឱ្យឆ្លើយតបនឹងកំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ គោលនយោយាបាយស្តីពីគ្រូបង្រៀន (TPAP) និងក្របខណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន។

***ពាក្យគន្លឹះ៖*** *ស្ថានភាព ការធានាគុណភាពអប់រំ ប្រព័ន្ធនៃការធានាគុណភាព គុណវុឌ្ឍិ សមត្ថភាពគ្រូ សាលាគរុកោសល្យ និងវិក្រឹតការ*

# ABSTRACT

The Teacher Policy was approved by the Ministry of Education, Youth and Sport (MoEYS) in 2013, the first step in reforming the national teacher recruitment and training system to develop teachers with quality, competencies with professional code. The next step, the MoEYS formulated the Teacher Policy Action Plan (TPAP) in 2015 to reform all teaching education Institutions (PTTCs, higher education institutions). The MoEYS has also established the Teacher Professional Standard in 2016 to raise the current capacity of teachers, to enhance teacher's teaching and learning skills to facilitate students learning.

The study on "**Situation of Quality Education Assurance at Provincial Teacher Training College in Siem Reap**" aims to understand the situation of quality education assurance, the best practices and challenges in implementing the quality assurance in the provincial teacher training college.

The researcher used the quantitative and qualitative methods. The quantitative data was collected by the management team, trainers and student teachers. There were 176 samples in total (100%), including 65 males (36.93%), 111 females (63.07%). The qualitative data was collected by interviewing. There were 6 interviewees (100%) of which 5 men (83.33%) and 1 woman (33.33%).

As a result of the implementation of the nine standards of quality education assurance, the report identified that the management team has contributed as a "good" level (M=4.05, S.D=1.07). The trainers have contributed at a "good" level (M= 3.76, S.D=0.83). The student teachers have contributed as a "good" level (M= 4.20, S.D=0.50). Based on the results of this study, researchers can conclude that the situation of quality education assurance in the implementation of the nine standards of quality education assurance went well and should be proud (M=4.01). This shows that the implementing of Provincial Teacher Training College of Siem Reap has done in line the average score for all standards.

In this sense, the management has disseminated the vision, mission and objectives widely to the stakeholders, has a clear structure that reflects the authority and working relationship in the school, as well as defined roles and responsibilities. For the trainers, they performed their role and other tasks at a good level, which the management team has assigned to fulfill their duties, for the quality of the student teachers' academic results. The student teachers participated in all the activities of the study very well by guiding from stakeholders. However, this result is still a challenge, with the qualifications of some trainers not yet equal to the level of the qualification (2.27% lower than bachelors, 61.36% bachelors, 34.09% master's degree, and 2.27% higher than Master's degree. The initial skills of student teachers in English and computer subjects have not yet improved. Cambodia is currently in the context of the Industrial Revolution 4.0, which

requires management team, teachers and student teachers to adopt a digital society in response to teacher education reform of Teacher Policy Action Plan (TPAP) and a framework of Continuous Professional Development (CPD).

**Keywords**: *Situation, Education Quality Assurance, System of Quality Assurance, Qualifications, Teacher Competency, and Teacher Training College*

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក ១ ៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សេចក្តីថ្លែងការណ៍វេទិកាពិភពលោកនៅទីក្រុង អ៊ីនឈុន (Incheon) សម្រាប់វិស័យអប់រំឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ២០៣០ (Education 2030 Incheon Declaration) បានប្តេជ្ញាដើម្បីលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតបង្កើនឱកាសទទួលបានបច្ចេកទេស ការអប់រំបណ្តុះបណ្តាល ការអប់រំនៅឧត្តមសិក្សា និងការស្រាវជ្រាវប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា ការផ្លាស់ប្តូរជីវិតឱ្យប្រសើរឡើងតាមរយៈការអប់រំដោយទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់នៃការអប់រំ ជាកត្តាគន្លឹះនៃការអភិវឌ្ឍ និងការសម្រេចគោលដៅអភិវឌ្ឍដោយចីរភាព (UNESCO et al., 2015)[1]។

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) បានដាក់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា បានផ្តោតលើ «**កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**»។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងនៅក្នុងប្រទេសកម្ពុជា មានចំណូលមធ្យមកម្រិតទាប ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

ក្រសួងអប់រំ យុវជន និងកីឡា (២០២២) បានដាក់ចេញនូវ «**អាទិភាពកំណែទម្រង់ដំណាក់កាលទី១**» នៅឆ្នាំ២០១៤ដែលមាន៨ចំណុច គឺ៖ (១) ការពង្រឹងគុណភាពអប់រំ (២) ការពង្រឹងការគ្រប់គ្រងបុគ្គលិក (៣) ការពង្រឹងការប្រឡងគ្រប់ប្រភេទ (៤) កំណែទម្រង់ឧត្តមសិក្សា (៥) ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេសនិងជំនាញទន់ (៦) កំណែទម្រង់ការគ្រប់ហិរញ្ញវត្ថុសាធារណៈ (៧) កំណែទម្រង់អប់រំកាយនិងកីឡា និង (៨) ការបង្កើតអង្គភាពស្រាវជ្រាវគោលនយោបាយវិស័យអប់រំ (ហង់ជួន ណារ៉ុន, ២០១៥)។ បន្ទាប់មកក្រសួងអប់រំបានបន្តវឌ្ឍនភាពនៃកំណែទម្រង់១៥ចំណុច ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ (ណាត ប៊ុនរឿន, ២០១៩) បានដាក់ចេញ «**ចក្ខុវិស័យកំណែទម្រង់អប់រំ**» ដែលឈរ

[1] អង្គការ យូណេស្កូ បានរៀបចំវេទិកាពិភពលោក ស្តីពីវិស័យអប់រំ ឆ្នាំ២០១៥ នៅទីក្រុង អ៊ីនឈុន (Incheon) សាធារណៈរដ្ឋកូរ៉េ ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ អ្នកចូលរួមប្រមាណ១៦០០នាក់ ដែលមកពី១៦០ប្រទេស រួមមានរដ្ឋមន្ត្រីជាង១២០រូប។ [ភាសាខ្មែរ] [ភាសាអង់គ្លេស]

លើ**សរសរស្តម្ភ៥** គឺ៖ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការធ្វើអធិការកិច្ច (៣) វង្វាយតម្លៃការសិក្សា (៤) ការកែលម្អការសិក្សានិងបរិស្ថានសិក្សា និង (៥) កំណែទម្រង់ឧត្តមសិក្សា (ហង់ជួន ណារ៉ុន, ២០១៥a)។ **សរសរស្តម្ភទី១** ស្តីអំពី**ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន(TPAP)** មានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនផ្អែកលើស្តង់ដាតាមរូបមន្ត ១២+៤ (បរិញ្ញាបត្រអប់រំ) នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (ហង់ជួន ណារ៉ុន, ២០១៥b)។ កំណែទម្រង់វិស័យអប់រំដំណាក់កាលទី២ នៅឆ្នាំ២០១៥ គឺ «**កំណែទម្រង់សាលារៀន**» ដែលក្រសួងអប់រំបានសាកល្បងអនុវត្តកំណែទម្រង់សាលារៀនដោយបង្កើតនូវគំរូកំណែទម្រង់ចំនួន២ គឺ (១) ការបង្កើតសាលារៀនជំនាន់ថ្មី(NGS) (២) ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SBM) (ហង់ជួន ណារ៉ុន, ២០២២)។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) បានលើកឡើងថាកម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់ សកលលោក ដែលមានមហិច្ឆតានិងវិសាលភាពធំទូលាយជាមុនសំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ និងសិក្សាពេញមួយជីវិត និងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដោយបានប្តូរគោលនយោបាយពីបីមកត្រឹមពីរក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដោយឈរលើមូលដ្ឋានគោលនយោបាយពីរ គឺ (១) **ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត** (២) **ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រងរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់** (ក្រសួងអយក, ២០១៩)។

ការអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ (រាជរដ្ឋាភិបាលកម្ពុជា ២០១៩)។ ការអប់រំគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមគ្គទេសក៏រួមចំណែកដ៏សំខាន់ក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយ សមធម៌ បរិយាបន្ន និងឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (ក្រសួងអយក ESP 2019-2013, ២០១៩)។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ គឺការអប់រំប្រកបដោយគុណភាព (SDG 4 Quality education) នៅកម្ពុជារហូតដល់ឆ្នាំ២០៣០ ពឹងផ្អែកជាសំខាន់លើគុណភាពអប់រំ (ក្រសួងអយក, ២០១៩, Roadmap ២០៣០)។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) បានដាក់ចេញគោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ មានគោលបំណង **ត្រង់ចំណុច ៤.៣** គឺលើកកម្ពស់គុណភាពនៃការរៀន ការបង្រៀន និងការស្រាវជ្រាវ ដើម្បីផ្តល់ឱកាសឱ្យនិស្សិតនូវ ***វិជ្ជាសម្បទា បំណិនសម្បទា*** និង***ចរិយាសម្បទា*** ដែលជាតម្រូវការទីផ្សារការងារ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) បានបង្ហាញពីកំណែទម្រង់លើវិស័យអប់រំជាបន្តបន្ទាប់ពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន ទទួលបាននូវលទ្ធផលវិជ្ជមានគួរឱ្យកត់សម្គាល់។ កត្តាជោគជ័យនេះមានការចូលគ្រប់ភាគីពាក់ព័ន្ធ។ ដើម្បីធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកំណែទម្រង់តាមគ្រប់កម្រិត ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់ចំនួន ៣ កម្រិត៖ (១) ការអនុវត្តកំណែទម្រង់គោលនយោបាយអប់រំកម្រិតជាតិក្នុងក្របខណ្ឌសសរស្តម្ភ៥ (២) ការអនុវត្តកំណែទម្រង់គ្រូបង្រៀនតាមសាលាគរុកោសល្យ និង (៣) ការអនុវត្តកំណែទម្រង់សាលារៀន។ តាមរបាយការណ៍សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា (២០២២) បានបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ការលើកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ក្នុងកម្មវិធីលើកកម្ពស់គុណវឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រង។

ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា (២០២០) បានដាក់ចេញដើម្បីលើកម្ពស់គុណភាពនិងប្រសិទ្ធភាពអប់រំគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (ប្រការ៨) តាមអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ការផ្ទេរសាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តគរុកោសល្យទាំង១៥ ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (ក្រសួងអយក, ២០២០) ក្នុងនោះមានសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាបផងដែរ (ត្រង់ប្រការ២) បានធ្វើកំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងបានកំពុងអនុវត្តនៅគ្រឹះស្ថានបណ្តុះបណ្តាល

គ្រូបង្រៀនចំនួន៣ រួមមានៈ (១) វិទ្យាស្ថានជាតិអប់រំ (២) វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និង (៣) វិទ្យាស្ថានគរុកោសល្យបាត់ដំបង (ក្រសួអយក, ២០២០)។

តាមគេហទំព័រផ្លូវការ ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវអគារសិក្សា និងសមិទ្ធផលនានាក្នុងបរិវេណវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ បានដកស្រង់ប្រសាន៍របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថា *"ក្រសួងអប់រំបាននិងកំពុងអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូឱ្យស័ក្តិសមជាកន្លែងអប់រំគ្រូបង្រៀនប្រកបដោយគុណភាពទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិក្ខារបង្រៀន និងរៀនព្រមទាំងការធ្វើទំនើបកម្មវិធីសាស្ត្របង្រៀនឱ្យស្របតាមបរិបទសតវត្សទី២១ ដើម្បីធានាថាគរុសិស្សមានមូលដ្ឋានរឹងមាំ ក្នុងការបង្រៀនបន្តដល់សិស្សនូវចំណេះដឹងប្រកបដោយប្រសិទ្ធភាព និងគុណភាព"*។

ទោះបីកំណែទម្រង់ដំណើរការល្អជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលពិនិត្យឡើងវិញនៅសាលាគរុកោសល្យ និងវិក្រឹតការ (ក្រសួងអយក, ២០១៧) រួមមានៈ (១) ពុំទាន់បានអភិវឌ្ឍសមត្ថភាពបុគ្គលិកបន្តដល់បុគ្គលិក និងកម្មវិធីបណ្តុះបណ្តាលឱ្យស្របតាមស្តង់ដាសមត្ថភាពកម្រិតគុណវុឌ្ឍិជាតិនិងតម្រូវការទីផ្សារការងារ (២) ពុំទាន់បានរៀបចំកម្មវិធីបណ្តុះបណ្តាលតាមរូបមន្ត ១២+៤នៅឡើយ (៣) ពុំទាន់បានដំឡើងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ជាវិទ្យាស្ថានគរុកោសល្យនៅឡើយ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៧)។ យោងតាមចក្ខុវិស័យរបស់សាលាគរុកោលសល្យ និងវិក្រឹតការខេត្តសៀមរាប (២០២២) ក៏បានកំណត់ជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការប្តេជ្ញាចិត្តខ្ពស់ដើម្បីក្លាយជាសាលាបណ្តុះបណ្តាលឈានមុខគេនៅក្នុងតំបន់លើផ្នែកគុណភាព សេចក្តីថ្លៃថ្នូរ និងប្រកបដោយវិជ្ជាជីវៈដើម្បីចូលរួមចំណែកយ៉ាងសកម្ម និងប្រសិទ្ធភាពក្នុងការអភិវឌ្ឍន៍សង្គម។ ដើម្បីធានាគុណភាព ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ឆ្លើយតបនឹងចក្ខុវិស័យនេះ សាលាគរុកោលសល្យ និងវិក្រឹតការខេត្ត មានបេសកកម្ម រួមមាន (១) ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយគុណភាពខ្ពស់ប្រកបដោយគុណតម្លៃ និងសីលធម៌ (២) ពង្រឹងការគ្រប់គ្រងតាមបែបចូលរួម ដើម្បីធ្វើឱ្យប្រសើរឡើងឈានឆ្ពោះទៅជាសាលាឈានមុខគេមួយលើការបណ្តុះបណ្តាល

(៣) លើកទឹកចិត្ត ជំរុញឥរិយាបថទទួលខុសត្រូវ ភាពជាអ្នកដឹកនាំចំពោះបុគ្គលិករដ្ឋបាល គ្រូឧទ្ទេស គរុសិស្ស និងកម្រិតជំនាញវិជ្ជាជីវៈខ្ពស់ (៤) ការអភិវឌ្ឍន៍បន្តនូវមូលដ្ឋានចំណេះដឹង និងកម្រិតសមត្ថភាព ដើម្បីធ្វើឱ្យសម្រេចគោលដៅបុគ្គលផ្ទាល់ និងចក្ខុវិស័យរបស់អង្គភាព។

ទាក់ទងនឹងបញ្ហាខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានសង្កេតឃើញថា ពុំទាន់មានអ្នកសិក្សាស្រាវជ្រាវបានស្រាវជ្រាវនៅឡើយទេ ដូច្នេះហើយទើបនាំឱ្យមានការស្រាវជ្រាវនេះកើតឡើង ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់អប់រំ ជាពិសេសកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងចំនួន២ គឺ៖

១. ឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប

២. បង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីសម្រេចវត្ថុបំណងខាងលើនេះមានសំណួរចំនួន២ ដែលបានកំណត់ដូចខាងក្រោម៖

១. តើការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត នៅខេត្តសៀមរាប មានស្ថានភាពយ៉ាងដូចម្តេច?

២. តើមានឧត្តមានុវត្ត និងបញ្ហាប្រឈមអ្វីខ្លះក្នុងការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺ៖

- ឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប

– បង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប

– ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការអភិវឌ្ឍកម្មវិធីសិក្សាសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ទៅជា**វិទ្យាស្ថានគរុកោសល្យ**។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅ**សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប** ក្នុងតំបន់ទីប្រជុំជន ស្ថិតក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ដោយផ្អែកលើអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពី**ការផ្ទេរសាលាគរុកោសល្យ និងវិក្រឹតការទាំង១៥ និងសាលាអនុវត្តន៍** ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (ក្រសួងអយក, ២០២០)។

រូបភាពទី 1៖ ទិដ្ឋភាពក្លោងទ្វារមុខសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តសៀមរាប




ឆ្លើយតបទៅនឹងបរិបទថ្មីនៃកំណែទម្រង់គុណភាពអប់រំ ក្រសួងអប់រំ (២០១៦) បានដាក់ចេញនូវស្តង់ដាជាតិអប្បបរមាទាំង៩ ជាជំនួយស្មារតីសម្រាប់មន្ត្រីវាយតម្លៃគុណភាពអប់រំគ្រឹះស្ថានសិក្សាជាមូលដ្ឋានសម្រាប់ប្រមូលព័ត៌មាន ទិន្នន័យ ភស្តុតាង រៀបចំសម្ភាសន៍ ស្ទង់មតិ អង្កេត ដាក់ពិន្ទុ វិភាគចំណុចខ្លាំង

និងចំណុចខ្វះខាត និងផ្តល់អនុសាសន៍ក្នុងការកែលម្អ ធានានិងលើកកម្ពស់គុណភាពអប់រំរបស់គ្រឹះស្ថានសិក្សាក្នុងការវាយតម្លៃនិងទទួលស្គាល់គុណភាពអប់រំ (ក្រសួងអប់រំ ២០១៩)។

ដែនកំណត់នៃការស្រាវជ្រាវនេះពុំបានធ្វើលក្ខណៈទ្រង់ទ្រាយទូទៅទេ គឺផ្តោតលើបញ្ញតិសំខាន់ៗតាមស្តង់ដាជាតិអប្បបរមាទាំង៩ ដែលបានកំណត់ (ACC, 2016, 2019)៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវានិស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨) ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

រូបភាពទី 2៖ ភាពទាក់ទងសហការគ្នារួមចំណែកដល់ការលើកកម្ពស់គុតភាពអប់រំ




*ប្រភព៖ K. Sitar and L. A. Cooke (2012)*

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា **៥ ជំពូក៖**

**ជំពូក១៖ សេចក្តីផ្តើម៖** ចំណុចបង្ហាញរួមមាន៖ (១) លំនាំបញ្ហានៃការស្រាវជ្រាវផ្តោតលើអាទិភាពកំណែទម្រង់ក្នុងវិស័យអប់រំនៅកម្ពុជា ខ្លឹមសារគោលនៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងគោលដៅប្រកបដោយចីរភាពទី៤នៅកម្ពុជារហូតដល់ឆ្នាំ២០៣០ (២) ចំណោទបញ្ហានៃការស្រាវជ្រាវឆ្លុះបញ្ចាំងពីសារៈសំខាន់នៃប្រធានបទស្រាវជ្រាវ និងឆ្លើយតបនឹងសំណួរស្រាវជ្រាវ (៣) គោលបំណងនៃការស្រាវជ្រាវមានចំនួនពីរ (៤) សំណួរនៃការស្រាវជ្រាវមានចំនួនពីរ (៥) សារៈសំខាន់នៃការស្រាវជ្រាវដើម្បីឈ្វេងយល់ពីស្ថានភាពដែលនាំឱ្យជានាគុណភាពអប់រំ និងជាមូលដ្ឋាគ្រឹះក្នុងអភិវឌ្ឍសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ទៅជាវិទ្យាស្ថានគរុកោសល្យ (៦) ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវផ្តោតលើអភិបាលកិច្ចនិងការគ្រប់គ្រង គុណវុឌ្ឍិសមត្ថភាពបុគ្គលិកអប់រំ ការអនុវត្តការងារជាប្រចាំ លទ្ធផលសិក្សា ការធានាគុណភាពអប់រំផ្ទៃក្នុងនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប (៧) បង្ហាញពីរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូក២៖ រំលឹកទ្រឹស្តី៖** គោលការណ៍នានាទាក់ទងនឹងស្ថានភាពនៃការធានាគុណភាពអប់រំ ស្តង់ដាអប្បបរមាទាំង៩ កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា។

**ជំពូក៣៖ វិធីសាស្រ្តនៃការស្រាវជ្រាវ៖** វិធីសាស្រ្តស្រាវជ្រាវមានចំនួនពីរគឺ (១) តាមបែបបរិមាណវិស័យដោយប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមចំនួនសំណាក (Taro Yamane, 1967) (២) តាមបែបគុណវិស័យប្រើសំណួរសម្ភាសន៍តាមក្រុមគោលដៅ (ចៃដន្យ)។

**ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា៖** បង្ហាញពីលទ្ធផលស្រាវជ្រាវទៅលើសំណួរទាំងពីរ រួចធ្វើការវិភាគពីស្ថានភាពនៃការធានាគុណភាពអប់រំ បង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ នៅស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប។

**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** ការសន្និដ្ឋានលើប្រធានបទតាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងសំណូមពរដល់ថ្នាក់ដឹកនាំគ្រប់ភាគីពាក់ព័ន្ធលើការងារអប់រំ ការរៀបចំគោលនយោបាយអប់រំ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ដើម្បីប្រែក្លាយសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ទៅជាវិទ្យាស្ថានគរុកោសល្យ។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូក ២ ៖ រំលឹកទ្រឹស្ដី

យុទ្ធសាស្ត្រទី១នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ "**ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស**" (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨) ត្រូវការរយៈពេលវែងដែលចាប់ផ្ដើមពីការពង្រឹងគុណភាពធាតុចូល ឈានទៅការពង្រឹងប្រសិទ្ធភាពសេវា និងចុងបញ្ចប់ការពង្រឹងប្រសិទ្ធផលនៃប្រព័ន្ធទាំងអស់ប្រកបដោយនិរន្តរភាព ត្រូវមានភាពច្បាស់លាស់ថាត្រូវធ្វើអ្វី ធ្វើដោយអ្នកណា និងធ្វើតាមរបៀបណាដោយផ្អែកលើការពិតបច្ចុប្បន្ន (ក្រសួងអយក, ២០២១)។

## ២.១ និយមន័យនៃការធានាគុណភាពអប់រំ

ដើម្បីបកស្រាយប្រធានបទនេះឱ្យបានច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវត្រូវពន្យល់អត្ថន័យនៃពាក្យគន្លឹះនៅក្នុងប្រធានបទនេះជាមុនដូចខាងក្រោម៖

**ស្ថានភាព** (***ស្ថាន*** មានន័យថា *ទីកន្លែងពិតប្រាកដ* ផ្សំជាមួយនឹងពាក្យ ***ភាព*** មានន័យថា *សភាពបែបបទជាក់លាក់*) ដូចនេះន័យជារួមថា *សភាពលក្ខណៈនៃទីកន្លែងពិតប្រាកដដែលទាក់ទងនឹងដំណើរការណ៍ដែលប្រព្រឹត្តទៅជាក់លាក់* (ជួន ណាត, ១៩៦៨)។

តាមវចនានុក្រមអង់គ្លេស-ខ្មែរ (ម៉ក់ បេន, ២០០៤) **ស្ថានភាព** (Situation) *ទីកន្លែងជាក់លាក់មួយតាមមុខតំណែងនៃលក្ខខណ្ឌការងារតាមពេលវេលាជាក់លាក់នៅក្នុងគ្រឹះស្ថានសិក្សា* (CAMBRIDGE Advanced Learner's Dictionary, Collins Dictionary)។

**គុណភាព** ជាដំណើរធ្វើឱ្យចម្រើនកើនឡើងដែលមានអានុភាពស័ក្តិសិទ្ធិ (ជួន ណាត, ១៩៦៨)។ ជាផលជះដល់សង្គម ផលសម្រេចនៃការផ្តល់សេវា ទិន្នផលដែលផលិតពីសេវា សកម្មភាពបំពេញស្តង់ដាការសិក្សា និងធាតុចូលដែលមានគុណភាព (ក្រសួងអយក, ២០២១)។

**គុណភាពអប់រំ** ជាការអភិវឌ្ឍធនធានមនុស្សដើម្បីរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលទាមទារធ្វើការត្រួតពិនិត្យ ការតាមដាន និងវង្វាយតម្លៃជាប់ជាប្រចាំ ដើម្បីលើកកម្ពស់ គុណភាព និងប្រសិទ្ធិភាពនៃសេវាអប់រំ (ក្រសួងអយក, ២០១៥a)។

**ការធានាគុណភាពអប់រំ** (រាជរដ្ឋាភិបាលកម្ពុជា, ២០១៤a) គ្រប់សកម្មភាពដែលផ្តល់ការធានាសេវានៃការអប់រំនិងបណ្តុះបណ្តាលរបស់គ្រឹះស្ថានសិក្សា ត្រូវបានផ្តល់ដោយប្រសិទ្ធភាពជាប់ជានិច្ចទៅតាមតម្រូវការស្តង់ដា។ តាមគោលការណ៍ណែនាំអាស៊ាន ស្តីពីការការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវឌ្ឍិសមត្ថភាព (អាស៊ាន, ២០១៦a) **ការធានាគុណភាពអប់រំ** គឺការធានាគុណភាព ផ្តោតលើដំណើរការដែលបានគ្រោងទុកលក្ខណៈជាប្រព័ន្ធ ដើម្បីផ្តល់ទំនុកចិត្តក្នុងការរៀបចំដំណើរការបណ្តុះបណ្តាលនិងការផ្តល់គុណវុឌ្ឍិក្នុងប្រព័ន្ធអប់រំនិងបណ្តុះបណ្តាល។ តាមសៀវភៅប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា (២០២១) **ការធានាគុណភាពអប់រំ** ជាស្នូលនៃការអភិវឌ្ឍសមត្ថភាពមន្រ្តីអប់រំតាមគ្រឹះស្ថានសិក្សាផ្តើមចេញពីអ្នកដឹកនាំអភិវឌ្ឍសមត្ថភាពខ្លួន ជួយមន្រ្តីអភិវឌ្ឍសមត្ថភាពនាំមកនូវផលជះដល់សង្គម។

**គុណវុឌ្ឍិ** (ជួន ណាត, ១៩៦៨) សេចក្តីចម្រើនដោយគុណ ដំណើរចម្រើនដោយសេចក្តីល្អដោយសេចក្តីរុងរឿង ដោយសេចក្តីបរិសុទ្ធ។ **គុណវុឌ្ឍិ** (រាជរដ្ឋាភិបាលកម្ពុជា, ២០១៤b) (១) ជាសំណុំសមត្ថភាពដែលឆ្លើយតបទៅនឹងតួនាទីការងារ និងផ្នែកសំខាន់នៅកន្លែងការងារ (២) ជាវិញ្ញាបនបត្រសញ្ញាបត្រ ឬកម្រិតដែលផ្តល់ឱ្យដោយគ្រឹះស្ថានសិក្សាដែលមានសិទ្ធិផ្តល់គុណវុឌ្ឍិនិងបញ្ជាក់ការទទួលស្គាល់លទ្ធផលសិក្សា (៣) ជាការបញ្ជាក់ផ្លូវការដែលចេញដោយអង្គភាពពាក់ព័ន្ធក្នុងការទទួលស្គាល់ថាបុគ្គលម្នាក់សម្រេចបានលទ្ធផលសិក្សា ឬសមត្ថភាពដែលទាក់ទងនឹងតម្រូវការ។

**សមត្ថភាព** (ជួន ណាត, ១៩៦៨) ភាពនៃសេចក្តីអាចហាន សេចក្តីមោះមុតធ្វើកើត។ **សមត្ថភាព** (រាជរដ្ឋាភិបាលកម្ពុជា, ២០១៤c) ជាចំណេះដឹង ជំនាញ និងឥរិយាបថជាក់លាក់ដែលត្រូវការក្នុងកន្លែងការងារ ហើយអនុវត្តចំណេះដឹងជំនាញទាំងនោះ ប្រតិបត្តិសកម្មភាពការងារឱ្យឆ្លើយតបទៅនឹងស្តង់ដាប្រតិបត្តិដែលមានជាក់លាក់។

ជារួម **ការធានាគុណភាពអប់រំ** គឺការអប់រំនិងបណ្តុះបណ្តាលរបស់គ្រឹះស្ថានសិក្សាស្របតាមស្តង់ដាលក្ខណៈជាប្រព័ន្ធដែលមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធមានគុណភាព។ **ការទទួលស្គាល់គុណភាពអប់រំ** គឺការការផ្តល់កម្រិតគុណភាពតាមគោលការណ៍និងនីតិវិធីនៃការទទួលស្គាល់គុណភាពអប់រំ (ACC, 2016)។

## ២.២ ប្រព័ន្ធអប់រំនៅកម្ពុជា

ច្បាប់ ស្តីពីការអប់រំ (២០០៧) មានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដើម្បីឱ្យអ្នកសិក្សាទទួលបានចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ ស្រឡាញ់ ការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ (ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២, ២០០៧)។ ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំសាធារណៈ និងការអប់រំឯកជនៈ (១) ការគាំពារនិងការអប់រំកុមារតូច (២) ការអប់រំចំណេះទូទៅ (៣) ការអប់រំឧត្តមសិក្សា (៤) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (៥) ការបណ្តុះបណ្តាលបុគ្គលិកអប់រំ (មាត្រា២ មាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០); (Sot, V., et al., 2019)។

រូបភាពទី 3៖ ប្រព័ន្ធអប់រំនៅកម្ពុជា




*ប្រភព៖ ក្រសួងអយក (២០២១); Sot, V., et al. (2019); Sokhom Chan, Sirichai Kanjanawasee (2014)*

## ២.៣ ការកសាងសមត្ថភាពអ្នកអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ឆ្នាំ២០៣០

ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) (យូណេស្កូ UNESCO, ២០២២) ត្រូវគិតពីអ្វីដែលយើងបានរៀន កន្លែងដែលយើងបានរៀន និងពីរបៀបដែលយើងរៀន ដើម្បីទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទា ដែលផ្ដល់លទ្ធភាពឱ្យយើងទាំងអស់គ្នាអាសម្រេចចិត្តបានត្រឹមត្រូវ៖ (១) ការផ្លាស់ប្តូរវិជ្ជមាននៅក្នុងសង្គម (២) វិធីសាស្រ្តគរុកោសល្យ និងបរិយាកាសរៀនសូត្រ (៣) លទ្ធផលនៃការសិក្សា (៤) ខ្លឹមសារនៃការសិក្សា។ អ្នកអប់រំ ជាតួអង្គសំខាន់ដែលសម្របសម្រួលជួយដល់អ្នកសិក្សាឆ្ពោះទៅរកបែបផែននៃជីវិតប្រកបដោយចីរភាពក្នុងការផ្លាស់ប្តូរខ្លួនឯង ផ្លាស់ប្តូរសង្គមបែបវិជ្ជមានដែលមានតួអង្គសំខាន់ៗ រួមមាន៖ (១) ថ្នាក់ដឹកនាំនិងបុគ្គលិកគ្រឹះស្ថានអប់រំគ្រូបង្រៀនគួរបញ្ចូលអភិវឌ្ឍសមត្ថភាព ESD ជាប្រព័ន្ធគ្រប់ជ្រុងជ្រោយនៅក្នុងវគ្គបណ្ដុះបណ្ដាល និងវិក្រឹតការ និងវាយតម្លៃគ្រូបង្រៀន (២) គ្រូឧទ្ទេសគួររៀបចំឱកាសរៀនសូត្រពីគ្នាទៅវិទៅមកក្នុងលក្ខណៈជាប្រព័ន្ធ (៣) អ្នកធ្វើគោលនយោបាយគួរផ្ដល់លទ្ធភាពលើកទឹកចិត្តនិងសាទរដល់អ្នកអប់រំដែលបានបញ្ចូល ESD ទៅក្នុងការបង្រៀន (៤) អ្នកអប់រំគួរបំពេញតួនាទីជាអ្នកសម្របសម្រួលដែលជួយដល់អ្នកសិក្សាបែបវិជ្ជមានការកសាងឯកទេស និងផ្សព្វចំណេះដឹងនាំមកនូវការផ្លាស់ប្រកបដោយចីរភាព។

ការអភិវឌ្ឍសមត្ថភាព (ក្រសួងអយក, ២០២០) លើកកម្ពស់វប្បធម៌នៃការសិក្សាពេញមួយជីវិតរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ដែលចង់វិនិយោគលើការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន រួមមាន៖ (១) សមត្ថភាពផ្នែកស្រាវជ្រាវ (២) សមត្ថភាពផ្នែកគោលនយោបាយ (៣) សមត្ថភាពផ្នែកប្រាស្រ័យទាក់ទង (៤) សមត្ថភាពផ្នែករៀបចំផែនការ (៥) សមត្ថភាពផ្នែកបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន (៦) សមត្ថភាពធ្វើការជាក្រុម។

គុណភាពគ្រូបង្រៀនក្នុងយុគសម័យឌីជីថល (ហង់ជួន ណារ៉ុន, ២០២១) សមត្ថភាពគ្រូបង្រៀនសតវត្សទី២១ (សិត សេង, ២០២១) Technological, Pedagogical, and Content Knowledge: TPACK (Mishra & Koehler, 2006)៖ (១) ចំណេះដឹងខ្លឹមសារមេរៀន (Content Knowledge: CK) (២) ចំណេះដឹងគរុកោសល្យ (Pedagogical Knowledge: PK) (៣) ចំណេះដឹងបច្ចេកវិទ្យា

(Technological Knowledge: TK) (៤) ចំណេះដឹងខ្លឹមសារមេរៀនសម្រាប់ការបង្រៀន (Pedagogical Content Knowledge: PCK) (៥) ចំណេះដឹងប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្ហាញខ្លឹមសារ តាមបែបថ្មី (Pedagogical Content Knowledge: PCK) (៦) ចំណេះដឹងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន (Technological Pedagogical Knowledge: TPK) និង (៧) ចំណេះដឹងដែលគ្រូត្រូវមានបញ្ចូលបច្ចេកវិទ្យាក្នុងការបង្រៀនខ្លឹមសារមេរៀន (Technological Pedagogical Content Knowledge: TPACK)។

រូបភាពទី 4៖ សមាសភាគទាំងប្រាំពីរនៃគុណភាពគ្រូបង្រៀនក្នុងយុគសម័យឌីជីថល




*ប្រភព៖ ឯកសាររបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០២១) ទំព័រ៣១*

*TPACK (Mishra & Koehler, 2006)*

តាមគេហទំព័រផ្លូវការ FN Fresh NEWS (២០១៩) បានចុះផ្សាយអនុសាសន៍របស់**សម្តេចក្រឡាហោម ស ខេង** ក្នុងពិធីអបអរសាទរទិវាគ្រូបង្រៀន ០៥ តុលា ២០១៩ ស្តីអំពី «**គុណភាពគ្រូជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល**» ទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា លោកគ្រូអ្នកគ្រូ និងអ្នក

ពាក់ព័ន្ធ សម្រាប់ជាការពិចារណាសំដៅលើកកម្ពស់គុណភាពគ្រូបង្រៀនដែលជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល ត្រូវជំរុញការអប់រំឌីជីថលឱ្យទាន់សភាពការណ៍ជាតិ តំបន់ និងពិភពលោក (១)ក្រសួងអប់រំត្រូវរៀបចំប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់គុណវឌ្ឍិរបស់គ្រូបង្រៀនគ្រប់កម្រិត ពិសេសការបង្រៀន និងការរៀនតាមបែបបច្ចេកវិទ្យាទំនើប ព្រមទាំងបន្តកែលម្អ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាលារៀន បន្ទប់រៀន បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ និងបន្ទប់សាស្ត្រាចារ្យតាមស្ថានភាពជាក់ស្តែងសម្រាប់បម្រើដល់ការបង្រៀនបែបថ្មី (២) ក្រសួងអប់រំ និងអ្នកពាក់ព័ន្ធត្រូវបង្កឱកាសឱ្យលោកគ្រូអ្នកគ្រូទទួលបានការអភិវឌ្ឍសមត្ថភាព (២) លោកគ្រូអ្នកគ្រូ និងគរុសិស្សត្រូវខិតខំប្រឹប្រែងអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដើម្បីដើរឱ្យទាន់បច្ចេកវិទ្យា និងយកចំណេះដឹងថ្មីៗមកបង្ហាត់បង្រៀនសិស្សបន្ត។

### ២.៣.១ ការកសាងធនធានគ្រូបង្រៀននៅកម្ពុជា

អង្គភាពមួយ កាលណាមានមនុស្សចាប់ពី២នាក់ឡើងទៅ ត្រូវតែមានអ្នកដឹកនាំដើម្បីអង្គភាពនោះមានសណ្តាប់ធ្នាប់ មានសន្តិសុខ និងមានការរីកចម្រើន (ក្រសួងអយក, ២០១៦)។ គ្រូបង្រៀនជាមនុស្សម្នាក់ដែលរដ្ឋបានផ្តល់ទំនុកចិត្តឱ្យបង្រៀន និងអប់រំកុមារនិងទំទង់ឱ្យមានតម្លៃចំពោះគ្រួសារ និងសង្គមប្រកបដោយគុណសម្បត្តិ៖ (១) គុណសម្បត្តិរូបរាងកាយ ឬកាយសម្បទា (២) គុណសម្បត្តិសីលធម៌ ឬសីលសម្បត្តិ (៣) គុណសម្បត្តិផ្នែកបញ្ញា (ណាត ប៊ុនរឿន, លឹម ប៉េង, ១៩៩៧)។ ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) បានកំពុងយកចិត្តទុកដាក់ជាប្រចាំក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើប្រទេសជាតិតាមរយៈការអប់រំ។

យោងតាមឯកសាររបស់**ឯកឧត្តម កង ឌិម** (បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ) ជំនួយការនៃរាជបណ្ឌិត្យសភាកម្ពុជា (២០២០) បានបង្ហាញថាក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំជាតិទាំងមូលត្រូវបានបង្កើតនិងស្តារឡើងវិញតាមរយៈការអភិវឌ្ឍធនធានមនុស្ស (គ្រូ សិស្ស និស្សិត) ដែលនៅសេសសល់ពីការសម្លាប់ក្រោមការឧបត្ថម្ភជំនួយបច្ចេកទេសពីបណ្តាប្រទេសសង្គមនានា។ គ្រូបង្រៀនដែលនៅរស់រានមានជីវិតមានចំនួនតិចពេក នៅពេលនោះក្រសួងអប់រំ យុវជន និងកីឡាក៏អនុវត្ត

គោលការណ៍ "**អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ**"។ គ្រូដែលគ្មានចំណេះដឹងខ្ពង់ខ្ពស់គ្មានគរុកោសល្យ "គ្រូចាត់តាំង" ត្រូវបង្រៀនសិស្សនៅបវេសនកាល និងត្រូវទទួលការសិក្សាគរុកោស្សនៅវិស្សមកាល។ ឯគ្រូបង្រៀនដែលនៅរស់រានមានជីវិតពីរបប ប៉ុល ពត ហៅថា "គ្រូចាស់" មានតួនាទីជាអ្នកផ្តល់ចំណេះដឹងគរុកោសល្យដល់ "គ្រូចាត់តាំង"។

ចាប់ពីដើមទស្សវត្សឆ្នាំ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡា បានប្រើរូបមន្តច្រើនសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន ចាប់ពី៤ខែទៅ៧ខែ ឈានទៅប្រើប្រាស់រូបមន្ត ៣+១, ៤+១, ៥+៣, ៧+១, ៨+១, ៧+៣, ១០+៣, ១០+៤, ១១+១, ១២+១, ១២+២ រហូតដល់បរិញ្ញាបត្រ+១ (ក្រសួងអយក, ២០១៥) (ហង់ជួន ណារ៉ុន, ២០២០)។

តាមក្រសួងអប់រំ យុវជន និងកីឡា (២០១៨) បានបង្ហាញថាគ្រូបង្រៀន គឺជាធនធានសំខាន់សម្រាប់ការសិក្សារបស់សិស្ស និងគុណភាពនៃការបណ្តុះបណ្តាលដែលគ្រូទទួលបានលក្ខណៈប្រឡងចូលតាមគន្លងអាជីពគ្រូបង្រៀនកំណត់បាននូវគុណភាពគ្រូបង្រៀន។

### ២.៣.២ ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀននៅកម្ពុជា

ក្រោយឆ្នាំ១៩៧៩ (ធយ អូន, ១៩៩៨) ការស្តារនិងកសាងឡើងវិញវិស័យអប់រំ ការកសាងជួរគ្រូបង្រៀនជាភារកិច្ចជាគន្លឹះតាមរយៈការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា គ្រូមធ្យមសិក្សាបឋមភូមិ គ្រូមធ្យមសិក្សាទុតិយភូមិ នៅកម្ពុជា បានបង្ហាញពីការវិវត្តច្រើនប្រភេទឆ្លើយតបទៅនឹងការអភិវឌ្ឍការងារនៃអប់រំដោយផ្តោតលើកត្តាសំខាន់ៗ រួមមាន៖ (១) កាលៈទេសៈ (គ្រូចាត់តាំងឆ្លងកាត់វគ្គខ្លី ២ ទៅ ៣ខែ) (២) ការបង្កើនសមត្ថភាពគ្រូបបឋមសិក្សា (ប្រព័ន្ធ ៧+១, ១១+២, ១២+២) (៣) ប្រភពបណ្តុះបណ្តាល (ចាប់ពីឆ្នាំ១៩៩៧ ចែកខេត្តវាលរាប និងដាច់ស្រយាលតាមរយៈការប្រឡងចូល) (៤) កត្តាសង្គមកិច្ច (ឆ្នាំ១៩៩៥ ពេលជ្រើសរើសគ្រូបបឋមសិក្សា១១+២ មានអ្នកមានបរិញ្ញាបត្រមួយចំនួនចេញពីសាកលវិទ្យាល័យភ្នំពេញ បានស្ម័គ្រចិត្តចូលធ្វើគ្រូបឋមសិក្សា) (៥) កត្តានយោបាយ (អ្នករៀនចប់បរិញ្ញាបត្រឆ្នាំ១៩៩៥ ជាអ្នកជាប់បរិញ្ញាបត្រទូទៅមិនទាន់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅឡើយ ហើយរូបមន្តបណ្តុះបណ្តាលថ្មីក៏មានឡើង គឺគ្រូមធ្យមសិក្សាទុតិយភូមិ បរិញ្ញា+១ ចេញបម្រើការ

ដំបូងឆ្នាំ១៩៩៦ គ្រូមធ្យមសិក្សាទុតិយភូមិ បរិញ្ញា+១ ស្ម័គ្រចិត្តជួយបង្រៀននៅបឋមសិក្សា ចេញបម្រើការឆ្នាំ១៩៩៧ ព្រោះក្រសួងអប់រំខ្វះគ្រូបឋមសិក្សា គ្រូមធ្យមសិក្សាទុតិយភូមិ បរិញ្ញាបត្រ+១ បង្រៀនពីមធ្យមសិក្សាបឋមភូមិចេញបង្រៀននៅឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ១៩៩៩ ទើបមានគ្រូមធ្យមសិក្សាបឋមសិក្សាចេញបម្រើការតាមរូបមន្តបណ្តុះបណ្តាល ១២+២) (ហង់ជួន ណារ៉ុន, ២០២០)។

ជាក់ស្តែងស្ថានភាពបណ្តុះបណ្តាលនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប (២០២២) បានបណ្តុះបណ្តាលគ្រូបង្រៀន ដូចខាងក្រោម៖

- ឆ្នាំ១៩៨០-១៩៩២ ការបណ្តុះបណ្តាលរយៈពេលខ្លី៣ខែ មានចំនួន៤៦វគ្គ សិក្ខាកាមសរុប ៤០៥៨នាក់ ស្រី១០៧៦នាក់។
- ឆ្នាំ១៩៨៥-១៩៩៦ ការបំពេញរូបមន្តរយៈពេលខ្លី មានចំនួន១១វគ្គ សិក្ខាកាមសរុប៨៣១នាក់ ស្រី៣២៣នាក់។
- ឆ្នាំ១៩៨៥-១៩៩២ ការបណ្តុះបណ្តាលរយៈពេលវែង ១ឆ្នាំ (៧+១) មានចំនួន៦វគ្គ សិក្ខាកាម សរុប៦៤៩នាក់ ស្រី២៩៤នាក់។
- ឆ្នាំ១៩៩១-២០២០ ការបណ្តុះបណ្តាលរយៈពេលវែង ២ឆ្នាំ (៨+២, ១១+២, ១២+២ និង ៩+២) មានចំនួន៤០វគ្គ សិក្ខាកាមសរុប៥៦៩៣នាក់ ស្រី៣២១១នាក់ ក្នុងនោះ៖

  +ឆ្នាំ១៩៩១-១៩៩៤ គរុសិស្ស ៨+២ មានចំនួន២វគ្គ សិក្ខាកាមសរុប២២៨នាក់ ស្រី១៣០នាក់។

  +ឆ្នាំ២០០១-២០១៤ គរុសិស្ស ៩+២ មានចំនួន១២វគ្គ សិក្ខាកាមសរុប១៥១៤នាក់ ស្រី ៨២៧នាក់។

  +ឆ្នាំ១៩៩៣-២០១៨ គរុសិស្ស ១១+២ និង ១២+២ មានចំនួន២៤វគ្គ សិក្ខាកាមសរុប ៣៥៩១នាក់ ស្រី២០១៣នាក់។

  +ឆ្នាំ២០១៧-២០២១ គរុសិស្ស ១២+២ មានចំនួន៣វគ្គ រៀនតាមប្រព័ន្ធក្រេឌីត សិក្ខាកាម សរុប៥២៤នាក់ ស្រី៣៤៨នាក់ (គិតចាប់ពីជំនាន់ទី៣៦)។

  សរុបរួម: ១០៤វគ្គ សិក្ខាកាមសរុប១១ ៣៩៥នាក់ ស្រី៥ ០១១នាក់ (គិតត្រឹមជំនាន់ទី៣៨)។

ចាប់ពីឆ្នាំសិក្សា១៩៧៩-១៩៨០ ដល់ឆ្នាំសិក្សា២០២០-២០២១ ប្រទេសកម្ពុជា បានបណ្ដុះបណ្ដាលគ្រូបង្រៀនតាមកម្រិតថ្នាក់ដើម្បីបម្រើការតាមភូមិសិក្សានីមួយៗកើនឡើងទូទាំងប្រទេស។

តារាងទី 1៖ ស្ថិតិបុគ្គលិកអប់រំតាមភូមិសិក្សា ពីឆ្នាំសិក្សា១៩៧៩-៨០ ដល់ឆ្នាំសិក្សា២០២០-២១

| ឆ្នាំសិក្សា | ចំនួនបុគ្គលិកអប់រំ | | | |
|---|---|---|---|---|
| | មត្តេយ្យសិក្សា | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ |
| ១៩៧៩-១៩៨០ | ២៦៧ | ១៣ ៦១៩ | ២០៥ | ២០ |
| ១៩៨០-១៩៨១ | ៦៣០ | ៣០ ៣១៦ | ៦៧១ | ២៨ |
| ១៩៨១-១៩៨២ | ៨១៨ | ៣១ ៨៨៤ | ១ ៥៨៦ | ៦៥ |
| ១៩៨២-១៩៨៣ | ៩៥៩ | ៣៤ ៨៥៩ | ៣ ៣០០ | ១៥៨ |
| ១៩៨៣-១៩៨៤ | ១ ៤៩៣ | ៣៥ ៤៧៩ | ៤ ៥៩៤ | ២៧១ |
| ១៩៨៤-១៩៨៥ | ១ ៨៣៥ | ៣៥ ៥៧៨ | ៦ ១១៦ | ៥៦៨ |
| ១៩៨៥-១៩៨៦ | ២ ៣៩៨ | ៣៥ ០៨០ | ៧ ៤១៦ | ៦១៧ |
| ១៩៨៦-១៩៨៧ | ២ ៦២៥ | ៣៦ ៧៥៤ | ៨ ៩៦៧ | ៨៥៨ |
| ១៩៨៧-១៩៨៨ | ៣ ០១៧ | ៣៧ ២៩២ | ១០ ៨៦៦ | ១ ០៦៤ |
| ១៩៨៨-១៩៨៩ | ៣ ២០៩ | ៣៦ ៩៣០ | ១១ ៧០២ | ១ ៤០៣ |
| ១៩៨៩-១៩៩០ | ៣ ៣៨៣ | ៤១ ២៦១ | ១២ ៧០២ | ១ ៧៦៦ |
| ១៩៩០-១៩៩១ | ២ ៩៥៩ | ៤០ ០១៤ | ១៤ ៣៥១ | ២ ០៥៧ |
| ១៩៩១-១៩៩២ | ២ ៧៣៦ | ៤០ ៦៣១ | ១៤ ៦៦៨ | ៣ ១៤៩ |
| ១៩៩២-១៩៩៣ | ២ ៩២០ | ៤២ ៤០៥ | ១៣ ១០៧ | ៦ ៤៣៩ |
| ១៩៩៣-១៩៩៤ | ២ ៦៨២ | ៤៤ ៤៥៤ | ១៣ ៦២១ | ៧ ៦៤៥ |

| | | | | |
|---|---|---|---|---|
| ໑໙໙໔-໑໙໙໕ | ໒ ໖໒໘ | ໔໔ ໙໘໕ | ໑໒ ໑໗໙ | ໘ ໗໘໔ |
| ໑໙໙໕-໑໙໙໖ | ໒ ໕໑໙ | ໔໕ ໗໕໓ | ໑໑ ໓໑໕ | ໘ ໘໐໖ |
| ໑໙໙໖-໑໙໙໗ | ໒ ໐໗໑ | ໔໗ ໑໔໗ | ໑໗ ໔໕໙ | ໓ ໒໔໖ |
| ໑໙໙໗-໑໙໙໘ | ໑ ໙໗໑ | ໔໘ ໔໖໐ | ໑໗ ໓໙໙ | ໓ ໘໒໕ |
| ໑໙໙໘-໑໙໙໙ | ໑ ໙໘໓ | ໔໙ ໔໐໐ | ໑໗ ໕໘໒ | ໔ ໕໖໑ |
| ໒໐໐໐-໒໐໐໑ | ໒ ໑໘໑ | ໕໒ ໑໖໘ | ໑໘ ໙໕໒ | ໕ ໐໐໐ |
| ໒໐໐໑-໒໐໐໒ | ໒ ໓໔໖ | ໕໔ ໕໑໙ | ໑໙ ໖໕໐ | ໕ ໒໓໔ |
| ໒໐໐໒-໒໐໐໓ | ໒ ໕໓໘ | ໕໗ ໐໗໗ | ໑໙ ໘໔໑ | ໖ ໐໗໐ |
| ໒໐໐໓-໒໐໐໔ | ໒ ໖໙໗ | ໕໙ ໒໗໑ | ໒໑ ໓໐໗ | ໖ ໓໔໑ |
| ໒໐໐໔-໒໐໐໕ | ໒ ໘໓໓ | ໖໐ ໘໔໑ | ໒໑ ໙໘໕ | ໖ ໘໒໙ |
| ໒໐໐໕-໒໐໐໖ | ໒ ໘໘໒ | ໖໑ ໖໕໗ | ໒໑ ໗໒໙ | ໗ ໙໘໑ |
| ໒໐໐໖-໒໐໐໗ | ໒ ໙໗໘ | ໕໙ ໘໘໙ | ໒໔ ໐໕໒ | ໗ ໗໒໒ |
| ໒໐໐໗-໒໐໐໘ | ໓ ໑໓໐ | ໕໘ ໗໗໖ | ໒໗ ໒໔໐ | ໗ ໘໕໗ |
| ໒໐໐໘-໒໐໐໙ | ໓ ໒໔໗ | ໕໖ ໙໗໘ | ໒໗ ໗໘໔ | ໑໐ ໖໘໑ |
| ໒໐໐໙-໒໐໑໐ | ໓ ໓໕໓ | ໕໖ ໖໗໐ | ໒໘ ໒໕໒ | ໑໑ ໖໘໐ |
| ໒໐໑໐-໒໐໑໑ | ໓ ໗໑໑ | ໕໖ ໓໓໙ | ໓໐ ໐໑໒ | ໑໑ ໖໘໐ |
| ໒໐໑໑-໒໐໑໒ | ໔ ໐໓໒ | ໕໖ ໓໔໔ | ໓໑ ໖໙໘ | ໑໑ ໗໐໖ |
| ໒໐໑໒-໒໐໑໓ | ໔ ໓໐໙ | ໕໖ ໑໐໘ | ໓໑ ໘໑໕ | ໑໒ ໘໘໐ |

| | | | | |
|---|---|---|---|---|
| ២០១៣-២០១៤ | ៤ ៧១៧ | ៥៥ ៩៥៨ | ៣២ ៦១៦ | ១៣ ៣៣០ |
| ២០១៤-២០១៥ | ៥ ០២៧ | ៥៥ ៧៨៨ | ៣២ ៥២៥ | ១៤ ០៥៥ |
| ២០១៥-២០១៦ | ៤ ៧២២ | ៥៦ ៤២១ | ៣៣ ១៦៤ | ១៤ ៤៣៤ |
| ២០១៦-២០១៧ | ៥ ០៨៤ | ៥៧ ៨៤៤ | ៣៣ ៧៦៣ | ១៤ ៤៥៧ |
| ២០១៧-២០១៨ | ៥ ៣៩៨ | ៥៧ ៩១៥ | ៣៣ ១៧១ | ១៥ ១៧២ |
| ២០១៨-២០១៩ | ៥ ៥៥៩ | ៥៧ ៨១១ | ៣៣ ៦៣៨ | ១៥ ៧៦១ |
| ២០១៩-២០២០ | ៥ ៦៧៨ | ៥៧ ៣៤៧ | ៣២ ៦២០ | ១៧ ៤៤២ |
| ២០២០-២០២១ | ៥ ៧១៧ | ៥៧ ៣០០ | ៣៣ ២៧៤ | ១៧ ៨៧៩ |

*ប្រភព៖ ក្រសួងអយក (២០២១) ស្ថិតិ និងសូចនាករអប់រំសាធារណៈ២០២០-២០២១ ទូទាំងប្រទេស*

## ២.៤ គោលការណ៍នៃការលើកកម្ពស់គុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា (២០២០) បានដាក់ចេញគោលការណ៍ និងយន្តការការងារគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រង់ប្រការ៨ (ហង់ជួន ណារ៉ុន, ២០២១) រួមមាន៖ (១) រៀបចំផែនការការបង្កើនសមត្ថភាពបុគ្គលិក គ្រូឧទ្ទេស និងគណៈគ្រប់គ្រង ដើម្បីបណ្តុះបណ្តាលគរុសិស្សមានគុណភាពល្អ (២) បំប៉នសត្តភាពការប្រើប្រាស់កម្មវិធីសិក្សា និងកម្មវិធីលម្អិត (៣) រៀបចំកម្មវិធីវិក្រឹតការគ្រូបង្រៀននិងធ្វើវិក្រឹតការទៀងទាត់ចំពោះគ្រូបង្រៀន (គុណវុឌ្ឍិ) (៤) ហេដ្ឋារចនាសម្ព័ន្ធ-IT Labs ដើម្បីឆ្លើយតបទៅនឹងយុគសម័យបច្ចេកវិទ្យា (៥) សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំការប្រឡងចូលគ្រឹះស្ថានស្របតាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា។

### ២.៤.១ និន្នាការអន្តរជាតិ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំគ្រូបង្រៀន

យោងតាមឯកសាររបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០២០) បានបង្ហាញថានិន្នាការអន្តរជាតិ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំគ្រូបង្រៀន មាន៥ ដូចខាងក្រោម៖

(១) និន្នាការថ្មីនៃការអប់រំគ្រូ គឺត្រូវកំណត់គុណវុឌ្ឍិអប្បបរមាសម្រាប់តាមគ្រប់ភូមិសិក្សាដោយបង្កើតពីបរិញ្ញាបត្រ (១២+៣) ដល់បរិញ្ញាបត្រជាន់ខ្ពស់ (១២+៥) ពិសេសនៅតាមប្រទេសអភិវឌ្ឍ។

(២) យកចិត្តទុកដាក់លើការពង្រឹងមុខវិជ្ជាឯកទេស ការបង្កើនស្តង់ដាវិជ្ជាជីវៈ ការលើកទឹកចិត្តការបំពេញការងារផ្តល់ឱកាសសម្រាប់អាជីពគ្រូបង្រៀន។

(៣) ទម្រង់នៃការអប់រំគ្រូបង្រៀនកម្រិតបរញ្ញាបត្រជាន់ខ្ពស់មានពីរកម្រិតៈ (១) ការអប់រំចំនួន៣ឆ្នាំទទួលបានសញ្ញាបត្របរិញ្ញាបត្រ (១៨០ក្រេឌីត) និង (២) ការអប់រំ២ឆ្នាំ ដើម្បីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ (១២០ក្រេឌីត)។

(៤) មុខវិជ្ជាក្នុងការអប់រំគ្រូ គឺផ្តោតលើការបង្រៀននិងមុខវិជ្ជាឯកទេស(academic studies) និងមុខវិជ្ជាស្នូល រួមមានៈ គរុកោសល្យ (៤០ក្រេឌីត) វិធីសាស្រ្តបង្រៀននិងទ្រឹស្តីនៃការសិក្សាអប់រំ(education studies) (២០ក្រេឌីត) មុខវិជ្ជាឯកទេស (៣០ក្រេឌីត) និងការសរសេរសារណាបញ្ចប់ការសិក្សា (៣០ក្រេឌីត)។

(៥) គរុសិស្សទទួលបានសមត្ថភាព ចំណេះដឹង និងការយល់ដឹងពីវិធីសាស្រ្តស្រាវជ្រាវក្នុងវិស័យអប់រំ រួមមានៈ បំណិនទ្រឹស្តីដើម្បីយកទៅអនុវត្តក្នុងការបង្រៀននិងរៀន និងការគ្រប់គ្រងសាលារៀនក្នុងបរិបទថ្មី។

### ២.៤.២ កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា

ប្រទេសកម្ពុជា បានចូលជាសមាជិកអាស៊ាន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ដើម្បីរួបរួមគ្នាក្រោមបាវចនា អាស៊ាន (មាត្រា៣៦) គឺ **ចក្ខុវិស័យតែមួយ** (One Vision) **អត្តសញ្ញាណតែមួយ** (One Identity) និង**សហគមន៍មួយ** (One Community) ដែលរួមរស់ជាមួយគ្នាប្រកបដោយសុភមង្គល (ASEAN Charter, 2008)។ រដ្ឋធម្មនុញ្ញអាស៊ាន (២០០៨) បានបញ្ជាក់ពីគោលបំណងរបស់អាស៊ានត្រង់ចំណុចទី១០ គឺ ការអភិវឌ្ឍធនធានមនុស្ស ការអប់រំ និងការសិក្សាពេញមួយជីវិត វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងពង្រឹងសមាគមអាស៊ាន។ ដើម្បីឆ្លើយតបនឹងគោលបំណងរបស់អាស៊ាន ប្រទេសកម្ពុជាបានធ្វើកំណែ

ទម្រង់ (សៀង សុវណ្ណា, ២០២១) រួមមាន៖ (១) និន្នាការសកលប្តូរការអប់រំសម្រាប់ទាំងអស់គ្នាទៅការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយគុណភាព (SDG4) (២) ប្រទេសក្នុងតំបន់អាស៊ានបង្កើនគុណវុឌ្ឍិគ្រូបង្រៀនស្តង់ដារបណ្តុះបណ្តាលតាមប្រព័ន្ធ ១២+២ (ហង់ជួន ណារ៉ុន, ២០២១) (៣) កម្ពុជាត្រូវការពលរដ្ឋពេញលេញដែលពោពេញដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា (៤) យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាលើកំណើនការងារ សមធម៌ និងប្រសិទ្ធភាព (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨) (៥) ប្រទេសកម្ពុជាមានមហិច្ឆតាប្រែក្លាយប្រទេសទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨)។

គុណភាពអប់រំ គឺគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលា (ហង់ជួន ណារ៉ុន, ២០១៥) តាមសសរស្តម្ភនៃកំណែទម្រង់អប់រំទាំង៥ គឺ៖ (១) កំណែទម្រង់គ្រូបង្រៀន (២) កំណែទម្រង់កម្មវិធីសិក្សា (៣) កំណែទម្រង់ប្រព័ន្ធអធិការកិច្ច (៤) កំណែទម្រង់ការវាយតម្លៃលទ្ធផលសិក្សា និង (៥) កំណែទម្រង់ឧត្តមសិក្សា។ យោងឯកសាររបស់បណ្ឌិត សិត សេង (២០២១) ស្តីអំពី**កំណែទម្រង់ការអប់រំគ្រូបង្រៀនឆ្ពោះទៅសម្រេចបានគ្រូបង្រៀនប្រកបដោយគុណសម្បទាសតវត្សទី២១** បានបង្ហាញថា ក្នុងឆ្នាំ ២០២០-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវអាទិភាពកំណែទម្រង់ចំនួន ៤ គឺ៖

(១) ការអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន៖ ការបង្កើតវិទ្យាស្ថានគរុកោសល្យ

(២) ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖ កម្រិតបរិញ្ញាបត្រ

(៣) ការចូលរួមក្នុងក្របខណ្ឌតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអន្តរជាតិ (Program for International Student Assessment, PISA)

(៤) ការពង្រឹងការគ្រប់គ្រងតាមសាលារៀន៖ ការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល (School Based Management, SBM)។

តាមយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០២០-២០២៣ គ្រឹះស្ថានបណ្តុះ-បណ្តាលគ្រូបង្រៀន (សិត សេង, ២០២១) ត្រូវ៖

(១) កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន៖ ប្រើវិធីសាស្ត្របង្រៀនថ្មីៗ និងការប្រើបច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការរៀននិងបង្រៀន

(២) បញ្ចូលវិធីសាស្ត្របង្រៀនថ្មីៗ៖ ការរៀនសូត្រសកម្ម ការរៀនបែបស្ថាបនា បែបដោះស្រាយបញ្ហា បែបស្រាវជ្រាវ បែបរិះរក និងការគ្រប់គ្រងថ្នាក់រៀន ក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន

(៣) បណ្តុះបណ្តាលគ្រូឧទ្ទេសផ្តោតលើបញ្ហាសកល

(៤) បណ្តុះបណ្តាលគរុនិស្សិតឱ្យក្លាយជាពលរដ្ឋសាកល។

កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា (សៀង សុវណ្ណា, ២០២១) ឆ្ពោះទៅសម្រេចបានគ្រូបង្រៀនប្រកបដោយគុណសម្បទាសតវត្សទី២១ (សិត សេង, ២០២១) ដូចខាងក្រោម៖

តារាងទី 2៖ ប្រព័ន្ធនៃការបណ្តុះបណ្តាលគ្រូនៅបណ្តាប្រទេសក្នុងអាស៊ាន

| **ប្រទេស** | **ប្រព័ន្ធអប់រំគ្រូបង្រៀន** | **ការបណ្តុះ-បណ្តាលគ្រូបឋមសិក្សា** | **ការបណ្តុះ-បណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ** | **ការបណ្តុះ-បណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ** |
|---|---|---|---|---|
| សឹង្ហបុរី | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សាបន្ទាប់ពីចំណេះទូទៅ) | ១២+២ និង ១២+៤ | ១២+៤ +១ | ១២+៤ +១ |
| ម៉ាឡេស៊ី | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សាបន្ទាប់ពីចំណេះទូទៅ) និងបរិញ្ញាបត្រជាន់ខ្ពស់ | ១២+៤ | ១២+៤ | ១២+៤ |
| ប្រ៊ុយណេ | | ១២+៤ | ១២+៤ | ១២+៤ |
| ថៃ | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សា+១ឆ្នាំកម្មសិក្សាបន្ទាប់ពីចំណេះទូទៅ | ១២+៤ +១ | ១២+៤ +១ | ១២+៤ +១ |

| | | | | |
|---|---|---|---|---|
| ឥណ្ឌូណេស៊ី | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សា បន្ទាប់ពីចំណេះទូទៅ) | ១២+៤ | ១២+៤ | ១២+៤ |
| ហ្វីលីពីន | | ១២+៤ | ១២+៤ | ១២+៤ |
| វៀតណាម | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សា បន្ទាប់ពីចំណេះទូទៅ) | ១២+៣ | ១២+៣ | ១២+៤ |
| ឡាវ | កម្រិតបណ្ឌុះបណ្ដាល (២ឆ្នាំ សិក្សា បន្ទាប់ពីចំណេះទូទៅ) និង កម្រិតបរិញ្ញាបត្រ (៤ឆ្នាំ សិក្សា) | ១២+៣ | ១២+៣ | ១២+៤ |
| ភូមា | | ១២+២ | ១២+៤ | ១២+៤ |
| កម្ពុជា | កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សា បន្ទាប់ពីចំណេះទូទៅ) នៅTECs កម្រិតបណ្ដុះបណ្ដាល (២ឆ្នាំ សិក្សា បន្ទាប់ពីចំណេះទូទៅ) នៅRTTCs កម្រិតបរិញ្ញាបត្រ (៤ឆ្នាំសិក្សា បន្ទាប់ពីចំណេះទូទៅ) នៅTECs កម្រិតបណ្ដុះបណ្ដាល (២ឆ្នាំ សិក្សា បន្ទាប់ពីចំណេះទូទៅ) នៅ PTTCs | ១២+២ | ១២+២ | ១២+៤ |

*ប្រភព៖ ឯកសាររបស់ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា (២០២១); ឯកឧត្តមបណ្ឌិត សិត សេង (២០២១);*

*Sot, V., et al. (2019)*

### ២.៤.៣ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន មិនមែនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀន ដើម្បីចាត់ជាគ្រូល្អ ឬគ្រូខ្សោយនោះទេ គឺដើម្បីកលើកស្ទួយការបង្រៀននិងរៀនរបស់គ្រូបង្រៀន សម្របសម្រួលការសិក្សារបស់សិស្សទទួលបានលទ្ធផលសិក្សាដែលមានកម្រិតសមស្របអាចទទួលយកបាន។ បញ្ញត្តិស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ក្រសួងអយក, ២០១០, ២០១៦) មាន ៣ គឺ៖ (១) ភាពច្បាស់លាស់នូវទិដ្ឋភាពដែលគ្រូបង្រៀនត្រូវយល់ដឹងនិងធ្វើ (២) សកម្មភាពរបស់គ្រូបង្រៀនអាចអនុវត្តបានហើយមានឥទ្ធិពលទៅលើសិស្ស (៣) ឧបករណ៍សម្រាប់វាស់សមត្ថភាពគ្រូបង្រៀន។ ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យត្រូវបានបែងចែកជា៦សមាសភាគ (ក្រសួងអយក, ២០១០) រួមមាន៖ (១) ភាពជាអ្នកដឹកនាំ (២) ការងាររដ្ឋបាល (៣) សកម្មភាពសិក្សា (៤) អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ (៥) សម្ភាររូបវន្ត (៦) សីលធម៌វិជ្ជាជីវៈ។

កំណែទម្រង់កម្មវិធីសិក្សា (ហង់ជួន ណារ៉ុន, ២០២០) មាន ៣ គឺ (១) លើកកម្ពស់ការយល់ដឹងពីកំណែទម្រង់កម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀនថ្មី (២) បញ្ជ្រាបកម្មវិធីសិក្សាថ្មីនេះដល់សាលាគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំ (៣) ដើម្បីលើកកម្ពស់វប្បធម៌ការសិក្សារបស់សិស្សគ្រប់កម្រិតស្តីពីការអប់រំបែបឌីជីថលសតវត្សរ៍ទី២១។ ការកែលម្អកម្មវិធីសិក្សា ដើម្បីឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ និងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងចំណូលកម្រិតខ្ពស់ត្រឹមឆ្នាំ២០៥០។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) បានដាក់ចេញស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានកំណត់ជា៤សមាសភាគ គឺ៖ (១) ចំណេះដឹងវិជ្ជាជីវៈ (២) ការប្រតិបត្តិវិជ្ជាជីវៈ (៣) ការសិក្សាគន្លងអាជីព (៤) សីលធម៌វិជ្ជាជីវៈ។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះមានប្រយោជន៍៖ (១) កែលម្អការបង្រៀន និងរៀន (២) ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (៣) កែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (៤) ការរៀបចំផែនការអភិវឌ្ឍសាលារៀន (៥) ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុងការស្វែងរកសេវាការងារធ្វើទាំងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន (៦) បង្កើន

សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យប្រហាក់ប្រហែលប្រទេសក្នុងតំបន់ (៧) ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីឡើងឋានន្តរសក្តិ។

តាមឯកសាររបស់បណ្ឌិត ឈូក ច័ន្ទធាយា (២០២២) កំណែទម្រង់ការភិវឌ្ឍគ្រូបង្រៀន រួមមានៈ (១) កម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន (២) ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងគុណភាពគ្រូឧទ្ទេស (៣) ការកែលម្អធនធានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធ (៤) ភាពជាអ្នកដឹកនាំ (៥) ការផ្សារភ្ជាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសាលាអនុវត្តន៍ (៦) ការធានាគុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) បានដាក់ចេញគោលនយោបាយ ស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ មានចក្ខុវិស័យកសាងប្រព័ន្ធឧត្តមសិក្សាប្រកបដោយគុណភាព អភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបនឹងយុគ្គសម័យនៃសកលភាវូបនីយកម្ម និងសង្គមពុទ្ធិ ក្នុងនោះមានគោលបំណងៈ (១) អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អដើម្បីធានានិស្សិតមានសមត្ថភាព (២) បង្កើតកម្មវិធីសមធម៌ និងការចូលរៀនឱ្យបានគ្រប់ជ្រុងជ្រោយនៅឧត្តមសិក្សានិងបញ្ចប់ដោយគុណភាព និងគុណធម៌ខ្ពស់ (៣) ភាពឆ្លើយតបដើម្បីផ្តល់ឱ្យនិស្សិតនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា ដែលជួយពួកគេចូលរួមចំណែកពេញលេញដល់តម្រូវការនៃការអភិវឌ្ឍជាតិ និងទីផ្សារការងារ។

## ២.៤.៤ ស្តង់ដានាយកសាលារៀននៅកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានរៀបចំស្តង់ដានាយកសាលារៀន ស្របតាមក្របខណ្ឌសមត្ថភាពនាយកសាលារៀននៅក្នុងតំបន់ដោយកំណត់គោលការណ៍លក្ខណៈវិនិច្ឆ័យ និងនីតិវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ។ ស្តង់ដានាយកសាលារៀនមានគោលដៅ (ក្រសួងអយក, ២០១៧) រួមមានៈ (១) ផ្តល់ឱកាសឱ្យនាយកសាលារៀនមានគុណវុឌ្ឍិ និងសមត្ថភាពពេញលេញដើម្បីឆ្លើយតបនឹងបរិបទថ្មីឆ្ពោះទៅរកគុណភាពអប់រំ (២) ពង្រឹងស្វ័យវាយតម្លៃសាលារៀនប្រកបដោយគុណភាពប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (៣) ប្រែក្លាយសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំប្រកបដោយបំណិនក្នុងការដោះស្រាយបញ្ហាចំពោះមុខ (៤) បង្កើនការទំនាក់ទំនងជាមួយអាជ្ញាធរ សហគមន៍ និងមាតា

បិតា អ្នកអាណាព្យាបាលសិស្ស ដើម្បីអភិវឌ្ឍន៍សាលារៀនប្រកបដោយនិរន្តភាព (៥) ពង្រឹងសក្តានុពលអប់រំក្នុងសាលារៀន ដោយផ្តល់សិទ្ធិអំណាចឱ្យនាយក នាយិកាសាលារៀនចាត់ចែងហេដ្ឋារចនាសម្ព័ន្ធ។

ស្តង់ដានាយកសាលារៀនមាន៦ស្តង់ដា (ក្រសួងអយក, ២០១៧) រួមមាន៖ (១) កម្រិតវប្បធម៌និងបទពិសោធន៍ការងារ (២) សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន (៣) បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ (៤) ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន (៥) ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន (៦) ការផ្សារភ្ជាប់សាលារៀន និងសហគមន៍។

## ២.៥ ក្របខណ្ឌធានាគុណភាពអប់រំ

ការធានាគុណភាពអប់រំ សំដៅលើដំណើរការដែលបានគ្រោងទុក និងលក្ខណៈជាប្រព័ន្ធ ដើម្បីធ្វើឱ្យផ្នែកគុណភាពត្រូវបានបំពេញហើយអង្គភាពនោះត្រូវបានផ្តល់នូវផលិតផលដែលល្អបំផុត មានន័យថា ធ្វើឱ្យកុមារ សិស្ស និស្សិតទាំងអស់ទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ ជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ និងភាសាជាតិ។ សមាសភាពសំខាន់ៗនៃការធានាគុណភាពអប់រំ (ក្រសួងអយក, ២០១៥b) រួមមាន (១) ការពិនិត្យតាមដាននិងការត្រួតពិនិត្យសកម្មភាពផ្អែកលើលទ្ធផលជាស្ថិតិ (២) ការវិភាគប្រើប្រាស់ទិន្នន័យដែលប្រមូលបានទាំងអស់ធ្វើការសន្និដ្ឋានលើដំណើរការពិនិត្យតាមដាន និងការត្រួតពិនិត្យ (៣) សេចក្តីសន្និដានធ្វើការសម្រេចចិត្តនូវចំណុចល្អ ចំណុចពុំទាន់បានល្អ ហើយត្រូវបង្កើតវិធានការដើម្បីកែលម្អ (៤) វិធានការថ្មីដោយផ្តល់គណនេយ្យភាពផ្អែកលើការវាយតម្លៃ និងកំណត់ផ្អែកធ្វើការវាយតម្លៃ។

តាមព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខេមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រង់មាត្រា២៣ បានចែងថា ការធានាគុណភាពអប់រំ ជាមធ្យោបាយសម្រាប់ធ្វើឱ្យគ្រឹះស្ថានសិក្សាអាចបញ្ជាក់ថា ស្តង់ដាទាំងឡាយដែលខ្លួនបានកំណត់ត្រូវធានាធ្វើឱ្យប្រសើរឡើងជាលំដាប់ មាន ២ គឺ (១) ការវាយតម្លៃផ្ទៃក្នុង(មាត្រា២៤)៖ ការពិនិត្យឡើងវិញយ៉ាងទៀងទាត់នូវស្តង់ដាប្រចាំដើម្បីធានាថាទិសដៅនៃការបង្រៀន និងការស្រាវជ្រាវនិងទិសដៅផ្សេងទៀតត្រូវបានបំពេញតាមការកំណត់ និង (២) ការវាតម្លៃផ្លូវការពីខាងក្រៅ(មាត្រា២៥)៖ ត្រូវធ្វើឡើងផ្អែកលើរបាយការណ៍

នៃគ្រឹះស្ថានជូនទៅគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) ពីវឌ្ឍនភាពឈានទៅសម្រេចគោលបំណងរបស់គ្រឹះស្ថានសិក្សានោះ និងឈានទៅកែលម្អកែលម្អចំណុចខ្វះខាតទាំងឡាយដែលកត់សម្គាល់ដោយ គ.ទ.ក នៅក្នុងដំណើរការនៃការទទួលទទួលស្គាល់គុណភាពអប់រំ។

រូបភាពទី 5៖ ប្រព័ន្ធធានាគុណភាពអប់រំ




*ប្រភព៖ Haruni J. Machumu & Sipora H. Kisanga (2014)*

ប្រព័ន្ធធានាគុណភាពអប់រំដែលមានដំណើរការល្អនៅកម្រិតមូលដ្ឋាន គឺជាការធានាសកម្មភាពជាបន្តបន្ទាប់សម្រាប់ឱ្យមានការកែលម្អ ហើយស្វ័យវាយតម្លៃបានដើរតួយ៉ាងសំខាន់ក្នុងប្រព័ន្ធធានាគុណភាពអប់រំ។ ប្រព័ន្ធធានាគុណភាពអប់រំ ត្រូវបានបែងចែកជា៣កម្រិត ទៅតាមកម្រិតសមត្ថភាព៖ (១) ការកែលម្អគុណភាពកម្មវិធីសិក្សា (២) ការពង្រឹងសមត្ថភាពគ្រប់គ្រង ការកសាងនិងចាប់អនុវត្តប្រព័ន្ធគាំទ្រ និងការកែលម្អគុណភាពកម្មវិធីសិក្សា (៣) ការពង្រឹងអភិបាលកិច្ច ការគ្រប់គ្រង និងអន្តរកម្មប្រព័ន្ធទាំងអស់របស់គ្រឹះស្ថានសិក្សា (ក្រសួងអយក, ២០២១)។

តាមន័យអធិការកិច្ច (ក្រសួងអយក, ២០១៥c) បានបង្ហាញថា ការធ្វើអធិការអប់រំ គឺជាយន្តការត្រួតពិនិត្យនិងតាមដានគ្រឹះស្ថានសិក្សាបានសម្រេចតម្រូវការរបស់ខ្លួនកម្រិតណា។ អធិការកិច្ចផ្ទៃក្នុង គឺផ្អែកលើការធ្វើស្វ័យវាយតម្លៃរបស់គ្រឹះស្ថានសិក្សាដែលអនុវត្តដោយនាយក និងបុគ្គលិកអប់រំ ដែលទាក់ទងនឹងគុណភាពផ្ទៃក្នុង ប្រើប្រាស់ធនធានផ្ទៃក្នុង ឬធនធានមូលដ្ឋាន ត្រូវអនុវត្តជាប្រចាំ។ ដើម្បីរួមចំណែកដល់ការលើកកម្ពស់ជំរុញដល់ការធានាគុណភាពអប់រំ ដែលអាចទទួលយកបានក្នុងការងារអប់រំអ្នកពាក់ព័ន្ធជួយបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនតាមការចាំបាច់តាមរាជធានីខេត្ត។ ការធានាគុណភាពអប់រំ ដោយធ្វើការអធិការកិច្ច ធ្វើការតេស្តវាយតម្លៃ ឱ្យតម្លៃខ្ពស់ថាមាតួនាទី និងភារកិច្ចសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍សង្គមជាតិ និងសកលលោក។ នាយកសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំធ្វើការស្វ័យវាយតម្លៃអង្គភាពរបស់ខ្លួនប្រកបដោយជោគជ័យ តែងតែផ្តោតលើកិច្ចខិតខំប្រឹងប្រែងរបស់គាត់លើវត្ថុបំណងទូទៅចំនួន ៤ គឺ (១) លើកកម្ពស់យ៉ាងខ្លាំងក្លាលើដំណើរការបង្រៀន និងរៀន (២) បណ្តុះគំនិតសហគមន៍ឱ្យចូលរួមយ៉ាងខ្លាំងក្លា (៣) ផ្តល់តម្លៃ និងពង្រីកសមាមាត្រស្ថានភាពសង្គមសេដ្ឋកិច្ចរបស់អ្នកសិក្សា (៤) លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវប្បធម៌អប់រំរបស់គ្រួសារ។

យោងតាមសៀវភៅណែនាំប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ សម្រាប់រាជធានីខេត្ត (ក្រសួងអយក, ២០២១) បានបង្ហាញថា សាលាគរុកោសល្យ និងវិក្រឹតការ មានតួនាទី៖ (១) ជួយគាំទ្រដល់ការប្រជុំបច្ចេកទេសនៅតាមកម្រងសាលារៀន និងកម្មវិធីជួយគ្រូបង្រៀនតាមកម្រងដើម្បីធ្វើឱ្យមានទំនាក់ទំនងរវាងការបណ្តុះបណ្តាល ជាមួយនឹងការបង្រៀន និងរៀននៅកម្រិតសាលារៀន (២) ចុះតាមដាននិងវាយតម្លៃគរុសិស្សដែលបានបញ្ចប់ការសិក្សា ដើម្បីវាស់វែងសមត្ថភាពនិងតម្រូវការថ្មីទាក់ទងដល់ការធ្វើវិក្រឹតការគ្រូបង្រៀន និងការកែលម្អកម្មវិធីបណ្តុះបណ្តាល (៣) សហការជាមួយនឹងការិយាល័យជំនាញមន្ទីរអប់រំ ដើម្បីគាំទ្រនិងពង្រឹងសមត្ថភាពក្រុមគ្រូប្រឹក្សាតាមកម្រងពីប្រសិទ្ធភាពនៃការបង្រៀននិងរៀន (Effectiveness of Teaching and Learning) នៅកម្រិតកម្រងសាលារៀន។

រាជរដ្ឋាភិបាលកម្ពុជា (២០២២) សម្រេចដាក់ចេញឱ្យប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣។ សារលិខិត**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា២០២១-២០២២ បានដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពនិងប្រយ័ត្នប្រយែង ព្រមទាំងអាចកត់ត្រាទុកនិងរៀនសូត្រជាមេរៀនបទពិសោធសម្រាប់ការអនុវត្ត "**គន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ**" រួមមាន៖ (១) ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការសុវត្ថិភាព សុខភាពសម្រាប់បុគ្គលិកអប់រំនិងសិស្សានុសិស្ស នៅគ្រឹះស្ថានសិក្សាស្របតាមគោលការណ៍ "**៣កុំ ៣ការពារ**" (២) ការបន្តជំរុញ "**ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ**" ឱ្យបានទាន់សភាពការណ៍ជាតិ តំបន់ និងសកលលោក (៣) ការអភិវឌ្ឍសមត្ថភាពនិងវិជ្ជាជីវៈជាប្រចាំដល់អ្នកគ្រប់គ្រង នាយកសាលា និងគ្រូបង្រៀន (៤) ការយកចិត្តទុកដាក់លើការអប់រំឆ្លើយតបទៅនឹងទីផ្សារការងារដោយអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗក្នុងសតវត្សទី២១ និងការផ្តោតលើការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដែលនឹងបណ្តុះបណ្តាលបាននូវអ្នកជំនាញចាំបាច់ក្នុងយុគសម័យឌីជីថល និងសេដ្ឋកិច្ចឌីជីថល (៥) ការរៀបចំប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំងវគ្គវិក្រឹតការតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពរបស់គ្រូបង្រៀនគ្រប់កម្រិត ជាពិសេស ការបង្រៀននិងរៀនតាមបែបបច្ចេកវិទ្យាទំនើប។

យោងតាម United Nations Institute for Training and Research (២០១៧) បានកំណត់ថាក្របខណ្ឌធានាគុណភាព (Quality Assurance Framework) រួមមាន៖ (១) ការបង្កើតគណៈកម្មការធានាគុណភាព (Quality Assurance Committee) (២) ស្តង់ដាធានាគុណភាពនិងគោលការណ៍ណែនាំ (Quality Assurance Standards and Guideline) (៣) ការវាយតម្លៃជាប្រចាំ (Self-Assessment and Review Process)។

### ២.៥.១ គោលការណ៍នៃការធានាគុណភាពអប់រំ

យោងតាម The ET2020 Working Group (2018) បានពិនិត្យមើលការវិវឌ្ឍន៍គោលនយោបាយដែលទទួលបានជោគជ័យ សក្តានុពលថ្មីនៅក្នុងអភិបាលកិច្ចនៃប្រព័ន្ធអប់រំដែលអាចគាំទ្រ និងកែលម្អគុណភាព ការដាក់បញ្ចូល និងការច្នៃប្រឌិត។ សមត្ថភាពសម្រាប់ការផ្លាស់ប្តូរជាប្រព័ន្ធ មាន ៤ គឺ៖ (១) ការធានាគុណភាពសម្រាប់ការអភិវឌ្ឍន៍សាលារៀន (២) ការបន្តនិងការផ្លាស់ប្តូរសម្រាប់ការអភិវឌ្ឍអ្នកសិក្សា (៣) គ្រូនិងអ្នកដឹកនាំសាលារៀន និង (៤) ការទំនាក់ទំនង (បណ្តាញ)។ គោលការណ៍ទាំង៨នៃការអភិវឌ្ឍន៍គោលនយោបាយ ស្តីពីការធានាគុណភាពក្នុងវិស័យអប់រំសម្រាប់ការអភិវឌ្ឍន៍សាលារៀនរួមមាន៖ (១) ការសហការគ្នា(Coherence) (២) សហគមន៍សិក្សាវិជ្ជាជីវៈ(Professional Learning Communities, PLC) (៣) ការជឿទុកចិត្តនិងការទទួលខុសត្រូវរួម(Trust And Shared Accountability) (៤)គាំទ្រការបង្កើតថ្មី(Support Innovation) (៥) ការចែករំលែកការយល់ដឹងនិងការពិភាក្សា(Shared Understanding And Dialogue) (៦) បណ្តាញ(Networks) (៧) ការកសាងសមត្ថភាពសម្រាប់ទិន្នន័យ(Building Capacity For Data) (៨) ទិន្នន័យផ្សេងគ្នាសម្រាប់ទិដ្ឋភាពសមតុល្យ (Different Data For Balanced View)។

### ២.៥.២ ការធានាគុណភាពអប់រំក្នុងការផ្តល់គុណវឌ្ឍិ

តាមគោលការណ៍ណែនាំអាស៊ាន (អាស៊ាន, ២០១៦b) ស្តីពីការការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវឌ្ឍិសមត្ថភាព បានបង្ហាញថា ប្រទេសជាសមាជិកអាស៊ាននីមួយៗបានអនុវត្តដំណើរការផ្តល់ការធានាគុណភាពសំខាន់ៗតាមវិធីផ្សេងៗ (១) ការអភិវឌ្ឍសមត្ថភាពស្តង់ដា (២) សមត្ថភាពអ្នកវាយតម្លៃ (៣) សមត្ថភាពអ្នកផ្តល់សេវា (៤) ការវាយតម្លៃសមត្ថភាព (៥) ទំនុកចិត្តក្នុងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាព។

ការផ្តល់គុណវុឌ្ឍិ រួមមាន៖ ការចេញវិញ្ញាបនបត្រ សញ្ញាបត្រ ឬបញ្ជីលទ្ធផលសិក្សាដែលជាសក្ខីកម្មបញ្ជាក់ថា បេក្ខជនត្រូវបានទទួលការវាយតម្លៃសមត្ថភាព និងផ្តល់គុណភាពដោយស្ថាប័ន។

ក្នុងឯកសារគោលការណ៍ណែនាំអាស៊ាន (អាស៊ាន, ២០១៦c) បានបង្ហាញពីការស្រាវជ្រាវថ្មីៗ (សេចក្តីព្រាងរបស់ក្រុមស្រាវជ្រាវធនាគារពិភពលោក ឆ្នាំ២០១៥) ការអប់រំ និងបណ្តុះបណ្តាលសមត្ថភាព ដែលមានស្រាប់នៅក្នុងប្រទេសជាសមាជិកអាស៊ាន ដូចខាងក្រោមៈ

តារាងទី 3៖ និយមន័យនៃវាក្យសព្ទសមត្ថភាព

| ប្រទេស | និយមន័យ |
|---|---|
| កម្ពុជា | ស្តង់ដាជំនាញ "ការតម្រូវការប្រតិបត្តិកិច្ចការប្រកបដោយប្រសិទ្ធភាពនៅកន្លែងការងារ ជាលក្ខខណ្ឌតម្រូវចំណេះដឹង ជំនាញ និងឥរិយាបថជាក់លាក់ ដែលកម្រិតប្រតិបត្តិរបស់ពលករជំនាញនៅក្នុងមុខរបរជាក់លាក់មួយ ដែលត្រូវតែសម្រេចបាន"។ |
| ថៃ | វិស័យវិជ្ជាជីវៈ និងជំនាញ៖ សមត្ថភាព គឺជាកម្រិតនៃការរំពឹងទុក និងការទទួលយកតាមការតម្រូវលើគុណភាពនៃដំណើរការ ឬផលិតផលនៃការសម្តែងរបស់បុគ្គល ឬ/និង ការដោះស្រាយបញ្ហា ការបង្ហាញការអនុវត្តដោយដៃនូវសមត្ថភាពរបស់ពួកគាត់បន្ទាប់ពីការសិក្សាបទពិសោធការងារ។<br>វិស័យវិជ្ជាជីវអាជីព៖ សមត្ថភាព គឺជាការអនុវត្តចំណេះដឹង និងបទពិសោធន៍ការងារ។ |
| ភូមា (មីយ៉ាន់ម៉ា) | ចំណេះដឹង ជំនាញ និងភាពប៉ិនប្រសប់។ |
| ម៉ាឡេស៊ី | សមត្ថភាព ត្រូវបានកត់សម្គាល់ថា ជាលទ្ធភាពដែលទទួលបាន និងបានអនុវត្តប្រកបដោយភាពប៉ិនប្រសប់លើកិច្ចការ ឬមុខរបរណាមួយ។ |
| វៀតណាម | សមត្ថភាព គឺជាចំណេះដឹង ជំនាញ និងឥរិយាបថដ៏សំខាន់សម្រាប់ការបំពេញការងារកិច្ចការនៃមុខរបរមួយ។ |
| សឹង្ហបុរី | សមត្ថភាព គឺជាសំណុំនៃចំណេះដឹង ជំនាញ និងឥរិយាបថដែលអាចវាស់វែង |

| | |
|---|---|
| | បានដែលជំរុញឱ្យការបំពេញការងាររបស់បុគ្គលម្នាក់ៗអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។ |
| ហ្វីលីពីន | សមត្ថភាពត្រូវបានកត់សម្គាល់ថាជា "ភាពអាចធ្វើបាន ឬភាពប៉ិនប្រសប់ និងផ្ដោតចំពោះការអនុវត្ត ចំណេះដឹង ជំនាញ និងឥរិយាបថដែលត្រូវការបំពេញសមត្ថភាពក្នុងលំដាប់នៃបរិបទ និងបរិស្ថាន ចំពោះស្តង់ដាដែលរំពឹងទុកនៅកន្លែងធ្វើការងារ"។ |
| ឡាវ | សមត្ថភាព គឺជាចំណេះដឹង ជំនាញ និងឥរិយាបថពាក់ព័ន្ធដែលត្រូវអនុវត្តចំពោះស្តង់ដាប្រតិបត្តិដែលរំពឹងទុកនៅកន្លែងការងារ។ សមត្ថភាពត្រូវបានពណ៌នាពីកិច្ចការនៃមុខរបរនៅក្នុងតួនាទីការងារនៃមុខរបរណាមួយជាក់លាក់។ |
| ឥណ្ឌូនេស៊ី | សមត្ថភាពភាពផ្នែកចំណេះដឹង ជំនាញ និងឥរិយាបថដែលត្រូវអនុវត្តនៅកន្លែងការងារ។ |

*ប្រភព៖ គោលការណ៍ណែនាំអាស៊ាន (អាស៊ាន, ២០១៦) ទំព័រ២០*

សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា (ក្រសួងអយក, ២០២២) បានដាក់ចេញទិសដៅការងារបណ្តុះបណ្តាលនិងវិក្រឹតការ៖ (១) ផ្តល់មន្ត្រីផ្នែកបច្ចេកទេស ICT ដើម្បីធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គលិក និងគរុសិស្ស នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (២) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមស្តង់ដា និងបច្ចេកទេសជំនាន់ថ្មីនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (៣) អភិវឌ្ឍសមត្ថភាពបុគ្គលិក គ្រូឧទ្ទេស និងគណៈគ្រប់គ្រងសាលាគរុកោសល្យឱ្យមានគុណសម្បទា សតវត្សទី២១ (៤) កែលម្អកម្មវិធីសិក្សាបណ្តុះបណ្តាលឱ្យទៅជាប្រព័ន្ធក្រេឌីត ឯកសារបណ្តុះ-បណ្តាល និងវិធីសាស្ត្របង្រៀនថ្មីតាមបែបចម្រុះឱ្យមានភាពស៊ីគ្នា នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត និងឆ្លើយតបទៅនឹងជំនាញសតវត្សទី២១ (៥) បន្តពង្រឹងសមត្ថភាពជូននាយកនាយករងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះ

ទូទៅ ស្តីពី ការគ្រប់គ្រងតាមសាលារៀន (៦) ពង្រឹងការធានាគុណភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

### ២.៥.៣ ការធានាគុណភាពអប់រំសម្រាប់គ្រឹះស្ថានមានវិជ្ជាជីវៈដំបូង

តាមសៀវភៅប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា (២០២១) បានបង្ហាញថា ដើម្បីកែលម្អគុណភាពអប់រំមានវិជ្ជាជីវៈដំបូងត្រូវអនុវត្តដូចខាងក្រោម៖

(១) ដំបូង គឺមានការវាយតម្លៃពីភាពត្រៀមរួចជាសម្រេចរបស់គ្រឹះស្ថានក្នុងការរៀបចំយុទ្ធសាស្ត្រ។

(២) ក្រោយពីគ្រឹះស្ថានមានយុទ្ធសាស្ត្រហើយ គ្រឹះស្ថានសិក្សាត្រូវរៀបចំ គ្រប់គ្រង និងអនុវត្តកម្មវិធីសិក្សាលើការបង្រៀន និងការស្រាវជ្រាវ។

(៣) ការវាយតម្លៃការសម្រេចទាំងផ្នែកគុណភាព និងបរិមាណពីការអនុវត្តយុទ្ធសាស្ត្រ។

### ២.៥.៤ កំណែទម្រង់សាលាគរុកោសល្យ

យោងតាមបាថកថា ស្តីពីការសម្រួចអាទិភាពកំណែទម្រង់វិស័យអប់រំតាមរយៈការគ្រប់គ្រងផ្អែកលើលទ្ធផលដើម្បីកសាងមូលធនមនុស្សនៅកម្ពុជា (ហង់ជួន ណារ៉ុន, ២០២២) មាន៨អាទិភាព ដែលក្នុងនោះអាទិភាពទី៦ គឺ "**កំណែទម្រង់សាលាគរុកោសល្យ**" មាន៦ចំណុច៖

**ទី១. កម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ៖** គរុសិស្សប្រតិបត្តិគុណសម្បទា និងបំណិនសតវត្សទី២១ មានគុណវុឌ្ឍិអនុលោមតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ក្រសួងអយក, ២០១៦)។

**ទី២. សមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស៖** (១) ខ្លឹមសារមេរៀន (២) គរុកោសល្យ ជាពិសេសវិធីសាស្ត្រសម្បូរបែបតាមបែសកម្ម (៣) បច្ចេកវិទ្យា។

**ទី៣. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** បំពាក់បរិក្ខារៀន ស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ សម្ភារឧបទេស ឯកសារៀននិងបង្រៀនទំនើប សម្បូរបែប។

**ទី៤. ភាពជាអ្នកដឹកនាំគ្រប់គ្រង៖** (១) គ្រប់គ្រងការរៀននិងបង្រៀន (២) គ្រប់គ្រងរដ្ឋបាល (៣) គ្រប់គ្រងហិរញ្ញវត្ថុ (៤) គ្រប់គ្រងបុគ្គលិក និងធានធាន។

**ទី៥. ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ៖** (១) ពង្រឹងគុណភាពកម្មសិក្សាគរុកោសល្យ។

**ទី៦. ការធានាគុណភាពអប់រំ៖** ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ ការវាយតម្លៃ។

## ២.៦ ការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានសិក្សា

យោងតាមគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC, ២០១៦) បានបង្ហាញថា ការធានាគុណភាពអប់រំ គឺគ្រប់សកម្មភាពដែលផ្តល់អំណះអំណាងថា សេវានៃការអប់រំ និងការបណ្តុះ-បណ្តាលរបស់គ្រឹះស្ថានសិក្សា ត្រូវបានផ្តល់ឱ្យប្រកបដោយប្រសិទ្ធភាពជាប់ជានិច្ចទៅតាមតម្រូវការស្តង់ដា និងស្របតាមគោលដៅនិងគោលបំណងដែលបានផ្សព្វផ្សាយ។ ការធានាគុណភាពអប់រំមានរូបភាពពីរគឺ ការវាយវាយតម្លៃផ្ទៃក្នុងផង និងការវាយតម្លៃផ្លូវការពីខាងក្រៅផង។ ដំណើរការធានាគុណភាពអប់រំមាន ការចូលរួម និងសហការពីគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ រួមទាំង បុគ្គលិក គរុសិស្ស និងភាគីពាក់ព័ន្ធ។

យោងតាម ACC (២០១៦) បានបង្ហាញថា ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានសិក្សា មាន៣កម្រិត រួមមាន (១) ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ (២) ការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន និង (៣) ការទទួលស្គាល់គុណភាពអប់រំជាបេក្ខភាព។

តាមទំព័របណ្តាញហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០២១) បានដកស្រង់ប្រសាសន៍របស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ថា «***ចំណេះដឹងមានអត្ថប្រយោជន៍ លុះត្រាតែគ្រូបង្រៀនចេះប្រើប្រាស់ចំណេះដឹងនេះ ដើម្បីបង្កើនគុណភាពបង្រៀន បង្កើតបរិយាកាសអំណោយផលសម្រាប់ការសិក្សា ប្រើវិធីសាស្ត្របង្រៀនសមស្របដើម្បីកែលម្អលទ្ធផលសិក្សាសិស្សប្រសើរជាងមុន និងលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំ ដើម្បីមនុស្សជាតិទាំងមូល***» ។

ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា របស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) បានដាក់ចេញផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ព្រមទាំង

បច្ចេកទេសវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាព ការងារស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម។

គោលដៅនៃកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គឺបង្កើនគុណភាពការបណ្តុះបណ្តាលគ្រូបង្រៀនតាមស្តង់ដាសតវត្សរ៍ទី២១ (4Cs) (ហង់ជួន ណារ៉ុន, ២០២០)៖ (១) ការបង្កើតថ្មី (Creativity) (២) ការសហការ(Collaboration) (៣) ការត្រិះរិះពិចារណា(Critical thinking) (៤) ការទំនាក់ទំនងនិងប្រាស្រ័យទាក់ទង(Communication)។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) បានដាក់ចេញគោលនយោបាយ ស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ផងដែរ ដើម្បីជានាអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ សមធម៌និងការចូលរៀនរបស់និស្សិតក្នុងកម្មវិធីប្រកបដោយគុណភាពដែលមានសមត្ថភាពនៅឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស ដែលឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងទីផ្សារកាងារ តម្រូវឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់អនុវត្តនិងបំពេញឱ្យបានតាមស្តង់ដាអប្បបរមាទាំង៩។ ស្តង់ដាអប្បបរមាទាំង៩ ដែលបានកំណត់ (ACC, 2016, 2019) រួមមាន៖

១. **ចក្ខុវិស័យ បេសកកម្ម និងគោលដៅ៖** (១) ការកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលបំណង (២) ការពិនិត្យ និងកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង (៣) ផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងគោលបំណង។

២. **អភិបាលកិច្ច និងការគ្រប់គ្រង៖** (១) រចនាសម្ព័ន្ធនៃអភិបាលកិច្ចនិងការគ្រប់គ្រង (២) ក្រុមប្រឹក្សាភិបាល (៣) សង្គតិភាពរវាងផែនការអភិវឌ្ឍន៍ជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលបំណង (៤) គុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍នៃបុគ្គលិកគ្រប់គ្រង (៥) វិសមភាពនៃតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងរដ្ឋបាល (៦) ការវាយតម្លៃប្រសិទ្ធភាពការងារនៃក្រុមប្រឹក្សាភិបាល។

៣. **បុគ្គលិកអប់រំ៖** (១) គុណវុឌ្ឍិ និងបទពិសោធន៍គ្រូបង្រៀន (២) ធនធានគ្រូបង្រៀនពេញម៉ោង (៣) ការជ្រើសរើស ការអភិវឌ្ឍ ការវាយតម្លៃ ការលើកទឹកចិត្ត និងការរក្សាបុគ្គលិកអប់រំ

(៤) ការរក្សាទុកឯកសាររបស់បុគ្គលិកអប់រំ (៥) ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ (៦) កញ្ចប់ថវិកាគាំទ្រការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកអប់រំ (៧) ការវាយតម្លៃបុគ្គលិកអប់រំ (៩) ការប្រើប្រាស់លទ្ធផលវាយតម្លៃបុគ្គលិកអប់រំ (១០) យុទ្ធសាស្ត្រគាំទ្រការស្រាវជ្រាវ និងសកម្មភាពប្រាជ្ញាភិវឌ្ឍន៍ (១១) ការផ្សព្វផ្សាយគោលនយោបាយ និងនីតិវិធីស្រាវជ្រាវ។

៤. **កម្មវិធីអប់រំ៖** (១) គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា (២) ភាពឆ្លើយតបនៃកម្មវិធីសិក្សាទៅនឹងគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ និងតម្រូវការសង្គម (៣) ប្លង់មុខវិជ្ជាលម្អិត (៤) យន្តការកំណត់ក្រេឌីត និងគោលការណ៍ផ្ទេរក្រេឌីត (៥) លទ្ធផលសិក្សា (៦) គោលការណ៍និងវិធីសាស្ត្រវាយតម្លៃការសិក្សា (៧) ការពិនិត្យនិងកែលម្អកម្មវិធីអប់រំ។

៥. **សេវានិស្សិត ឬគរុសិស្ស៖** (១) គោលនយោបាយឬគោលការណ៍ ស្តីពីការជ្រើសរើសសិស្ស និស្សិត គរុសិស្សចូលរៀន (២) គុណវុឌ្ឍិ និងបទពិសោធន៍របស់អ្នកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិ (៣) សេវាប្រឹក្សា សេវាសុខភាព និងកម្មវិធីអប់រំសុខភាព (៤) គោលនយោបាយឬគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍ (៥) ការណែនាំឬតម្រង់ទិសនិស្សិត គរុសិស្សចូលរៀនថ្មី (៦) ប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា (៧) គោលនយោបាយឬគោលការណ៍ស្តីពីការផ្ទេរក្រេឌីត (៨)សកម្មភាពបន្ថែមលើការសិក្សា និងកម្មវិធីហាត់ការងារ (៩) ការអភិវឌ្ឍន៍អាជីព និងជួយរកការងារឱ្យនិស្សិត-គរុសិស្ស (១០) ការស្រាវជ្រាវអំពីលទ្ធផលនិស្សិត គរុសិស្ស បញ្ចប់ការសិក្សា (១១) សេវាជួយសហគមន៍ និងសកម្មភាពជួយសង្គមផ្សេងៗ (១២)គោលនយោបាយឬគោលការណ៍ និងនីតិវិធីដោះស្រាយបណ្តឹងតវ៉ារបស់និស្សិត គរុសិស្ស (១៣)គោលការណ៍ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិតគរុសិស្ស និងអត្រាបញ្ចប់ការសិក្សា។

៦. **ធនធានសិក្សា៖** (១) បរិយាកាស និងភាពអំណោយផលរបស់បណ្ណាល័យ (២) ធនធានសៀវភៅនៅក្នុងបណ្ណាល័យ (៣) បណ្ណារក្សានិងបុគ្គលិកបម្រើការ (៤) ពេលវេលាបម្រើការសេវាកម្មរបស់បណ្ណាល័យ (៥) ការណែនាំ និងតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ (៦) ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក (E-library) (៧) ការធ្វើ

ផែនការបណ្ណាល័យ (៨) បន្ទប់ពិសោធន៍ទូទៅ និងឯកទេស (៩) ផែនការអភិវឌ្ឍបន្ទប់ពិសោធន៍ អនុវត្តន៍ (១០) ការបណ្តុះបណ្តាលបុគ្គលិកទីពិសោធន៍ អនុវត្តន៍ (១១) គោលនយោបាយ ឬគោលការស្តីពីសុវត្ថិភាព (១២) ធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិត (១៣) វគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា (១៤) ការបណ្តុះបណ្តាលបុគ្គលិកផ្នែកបច្ចេកវិទ្យា។

៧. **ធនធានរូបវន្តៈ** (១) ភាពគ្រប់គ្រាន់នៃធនធានរូបវន្តសម្រាប់កម្មវិធីអប់រំ (២) ផាសុកភាពនិងសុវត្ថិភាពនៃបរិស្ថាន (៣) ការផ្សព្វផ្សាយ អនុវត្ត វាយតម្លៃប្រចាំពីបញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខ (៤) ប្រសិទ្ធភាពនៃដំណោះស្រាយគ្រាមានអាសន្ន (៥) គោលនយោបាយ ឬគោលការណ៍សុវត្ថិភាពស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធព័ត៌មានអេឡិចត្រូនិក (៦) ផែនការអភិវឌ្ឍន៍ធនធានរូបវន្ត។

៨. **ធនធានហិរញ្ញវត្ថុៈ** (ស្ថិរភាពហិរញ្ញវត្ថុសម្រាប់ចំណាយលើបុគ្គលិក ប្រតិបត្តិការ និងដើមទុន (២) រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (៣) ការរៀបចំផែនការថវិកាប្រចាំឆ្នាំ (៤) ការចូលរួមពីថ្នាក់ដឹកនាំ និងផ្នែកពាក់ព័ន្ធក្នុងការរៀបចំផែនការថវិកា (៥) សវនកម្មហិរញ្ញវត្ថុ។

៩. **ការធានាគុណភាពអប់រំផ្ទៃក្នុងៈ** (១) ការពិនិត្យតាមដាន និងវាយតម្លៃអភិបាលកិច្ច និងដំណើរការការបណ្តុះបណ្តាលគ្រប់កម្រិត (២) ការប្តេជ្ញាចិត្ត ការប្រឹងប្រែង និងការចូលរួមពីក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិកអប់រំ បុគ្គលិករដ្ឋបាល និស្សិត គរុសិស្ស និងសមាជិករបស់គ្រឹះស្ថានសិក្សា។

### ២.៦.១ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់នាយកសាលាគរុកោសល្យ

ក្រសួងអប់រំ យុវជន និងកីឡា (២០១០) បានដាក់ចេញស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យក្នុងគោលបំណងៈ (១) លើកម្ពស់សមត្ថភាពក្នុងការងារគ្រប់គ្រង និងដឹកនាំឱ្យកាន់តែប្រសើរឡើងក្នុងសមាសភាគទាំង៦ (២) អភិវឌ្ឍកម្មវិធីសិក្សាបណ្តុះបណ្តាលការងារបង្រៀននិងរៀនរបស់គ្រូឧទ្ទេស និងគរុសិស្សឱ្យបានសម្រេចលទ្ធផលល្អ និងត្រឹមត្រូវតាមដល់កម្រិតស្តង់ដា (៣) អភិវឌ្ឍ

ផែនការកម្មវិធីបណ្តុះបណ្តាលគ្រូនិងផែនការស្វ័យសិក្សារបស់បុគ្គលិកអប់រំ (៤) ធ្វើឱ្យប្រសើរពីទំនាក់ទំនងជាវិជ្ជមានជាមួយសហគមន៍ជាតិ និងអន្តរជាតិដើម្បីចីរភាពក្នុងគម្រោងអភិវឌ្ឍស្ថាប័ន។

ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ (ក្រសួងអប់រំ, ២០១០) រួមមាន៖

**១. ភាពជាអ្នកដឹកនាំ៖** (១) ការកសាងផែនការ (២) ការទំនាក់ទំនងសហគមន៍ (៣) ការលើកទឹកចិត្ត។

**២. ការងាររដ្ឋបាល៖** (១) និយភាពការងារ (២) ការផ្សព្វផ្សាយ។

**៣. សកម្មភាពសិក្សា៖** (១) ការងារប្រតិបត្តិ (២) ការតាមដាន និងវាយតម្លៃ។

**៤. អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ៖** (១) ការកសាងផែនការអភិវឌ្ឍវិជ្ជាជីវៈ (២) ការអនុវត្តផែនការ។

**៥. សម្ភាររូបវន្ត៖** (១) ការគ្រប់គ្រងសម្ភារសង្ហារឹម និងឧបករណ៍បម្រើការបង្រៀន និងរៀន (២) បរិស្ថានក្នុងស្ថាប័នបណ្តុះបណ្តាល (៣) សេវាកម្មនានា និងសុវត្ថិភាព។

**៦. សីលធម៌វិជ្ជាជីវៈ៖** (១) ការបង្ហាញពីភាពសមធម៌ និងការយកចិត្តទុកដាក់ដល់បុគ្គលិកអប់រំដើម្បីជានាមានការរីកចម្រើនក្នុងអង្គភាព និងសង្គម (២) អនុវត្តន៍ កិច្ចការប្រកបដោយភាពយុត្តិធម៌ ស្មោះត្រង់ និងតម្លាភាព ជាមួយសហសេវិក ឬបុគ្គលិកទាំងអស់ព្រមទាំងសមាជិកសហគមន៍ផ្សេងៗ។

គុណភាពអប់រំ គឺគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន (ក្រសួងអយក, ២០១៧)។ សមត្ថភាពនិង គុណសម្បត្តិរបស់នាយកសាលារៀន គំនិតត្រិះរិះពិចារណានិងនវានុវត្តន៍ ភាពជាអ្នកដឹកនាំគ្រប់គ្រង រដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន និងការផ្សារភ្ជាប់សាលារៀននិងសហគមន៍ ស្របតាមក្របខណ្ឌសមត្ថភាពនាយកសាលារៀននៅក្នុងតំបន់ និងឧបករណ៍វង្វាយតម្លៃនាយកសាលារៀនល្អ (ប្រកាសលេខ៧៦១អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកំណត់គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងនិតីវិធីនៃការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ)។ ការពិនិត្យឡើងវិញលើអត្រាគ្រូតថ្នាក់ ផលធៀបរវាងចំនួនគ្រូបង្រៀននិងចំនួនសិស្ស ការបណ្តុះបណ្តាលគ្រូបង្រៀន ជាសូចនាករនៃគុណភាពអប់រំ (VSO, UNESCO, NEP, 2014)។

យោងតាមឯកសាររបស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** (២០២០) ស្តីពីកំណែទម្រង់សាលារៀននៅកម្ពុជា បានបញ្ជាក់ថា ភាពជាអ្នកដឹកនាំ គឺជាដំណើរការមានឥទ្ធិពល ផ្នែកសង្គមដែលបុគ្គលម្នាក់អាចទាក់ទាញអ្នកផ្សេងទៀតឱ្យជួយ និងគាំទ្រខ្លួនក្នុងការបំពេញភារកិច្ចរួម ហើយអ្នកដឹកនាំផ្តោតលើការផ្លាស់ប្តូរ ការដឹកនាំអ្នកក្រោមបង្គាប់ឱ្យបំពេញការងារ បង្ហាញផ្លូវដែលត្រូវដើរ គៀរគរមនុស្ស និងជំរុញលើកទឹកចិត្ត (ហង់ជួន ណារ៉ុន ២០២០; Martin M. Chemers, 1997) ។

គុណសម្បត្តិនាយកក្នុងយុគ្គសម័យឌីជីថល (ហង់ជួន ណារ៉ុន, ២០២១) មានៈ (១) បំណិនគមនាគមន៍ (Communications) (២) ទំនាក់ទំនងសាធារណៈជាមួយសហគមន៍ (Public relations) (៣) បំណិនបង្កើតម៉ាក (Branding) (៤) បង្កលក្ខណៈឱ្យសិស្ស និស្សិតរៀន (Student engagement or learning) (៥)បង្កលក្ខណៈឱ្យគ្រូអភិវឌ្ឍជំនាញវិជ្ជាជីវៈ (Professional growth or development) (៦) ចេះច្នៃប្រឌិតបរិស្ថានសិក្សាដែលទាក់ទាញដល់ការរៀននិងបង្រៀនដោយប្រើវិធីនវានុវត្តន៍ (Re-envisioning learning spaces and environments) (៧) ចេះចាប់យកនិងផ្តល់ឱកាស (Opportunity)។

យោងតាម ROTHA Leadership (២០២០) បានដកស្រង់ប្រសាសន៍របស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា ដើម្បីក្លាយខ្លួនជាអ្នកដឹកនាំឆ្នើម ត្រូវមានគោលការណ៍៤គឺៈ (១) បុគ្គលគោរពពេលវេលា (២) បុគ្គលមានឥរិយាបថទន់ភ្លន់ តែម៉ឺងម៉ាត់ (៣) រៀនស្តាប់រៀនគិត រៀនសួរ រៀនឆ្លើយ និងរៀននិយាយ (៤) រៀនធ្វើសង្គមទទួលស្គាល់និងសង្គមត្រូវការ ។

ភាពជាអ្នកដឹកនាំ គឺមានទស្សនវិស័យវែងឆ្ងាយ ជាសមត្ថភាពការបណ្តុះ ផ្តល់សិទ្ធិអំណាច គៀរគរធនធាន និងជំរុញលើកទឹកចិត្ត បុគ្គលិកទាំងអស់ឱ្យមានការរីកចម្រើន ធ្វើការតាមបែបច្នៃប្រឌិត មានឆន្ទៈក្នុងការគិតរកគំនិតល្អៗដែលនាំឱ្យកុមារទាំងអស់រៀនបានប្រកបដោយជោគជ័យ (ក្រសួងអយក, ២០១៦; ជា សុលីន ២០១៩)។ តាមលោក John C. Maxwell (2011) បានលើកឡើងថា ភាពជាអ្នកដឹកនាំ គឺជាសកម្មភាពទាក់ទងការងារជាមួយមនុស្សប្រកបដោយសក្តានុពលដែលពួកគេបានកំពុងអនុវត្ត

ឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់នៅក្នុងអង្គភាព។ ភាពជាអ្នកដឹកនាំពិតប្រាកដមិនមែនជារឿងទទួលបានតួនាទីនោះទេ វាគ្រាន់តែជាជំហានដំបូងដែលគេប្រគល់តួនាទីមួយដល់អ្នក។ ដើម្បីក្លាយជាអ្នកដឹកនាំ អ្នកត្រូវមានជំនាញ សមត្ថភាពក្នុងការជំរុញលើកទឹកចិត្តមនុស្សបង្កើតសមិទ្ធផលនិងកសាងការងារដើម្បីសម្រេចគោលដៅ។ លោក John C. Maxwell (2011) បានកំណត់ភាពជាអ្នកដឹកនាំមាន៥កម្រិតគឺ (១) ឋានៈតួនាទី(Position) ២) ការចូលចិត្ត(Permission) (៣) សមិទ្ធផល(Production) (៤) អភិវឌ្ឍមនុស្ស(People Development) និង (៥) ភាពឧត្តុងឧត្តម(Pinnacle)។

តាមឯកសាររបស់**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** (២០២១) ស្តីពី**កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា** បានបង្កើតក្របខណ្ឌកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ មាន៤ចំណុចៈ (១) កែលម្អក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីលម្អិត វិធីសាស្ត្របង្រៀន ឯកសារបង្រៀននិងរៀន (២) អភិវឌ្ឍធនធានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឱ្យឆ្លើយតបនឹងកម្មវិធីបណ្តុះបណ្តាលនិងស្តង់ដាសាលាគរុកោសល្យជំនាន់ថ្មី (៣) អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំដល់គ្រូឧទ្ទេសគណៈគ្រប់គ្រងនិងមន្ត្រី (៤) ប្រែក្លាយវិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ។ (ប្រភព៖ AMS EDUCATION, 2021)។

តាមឯកសាររបស់**ឯកឧត្តមបណ្ឌិត សិត សេង** (២០២១) បានបង្ហាញថាពីកាលានុវត្តភាពនៃ**កំណែទម្រង់ការអប់រំគ្រូបង្រៀនឆ្ពោះទៅសម្រេចបានគ្រូបង្រៀនប្រកបដោយគុណសម្បទាសតវត្សទី២១** របស់វិទ្យាស្ថានគរុកោសល្យ រួមមាន៖ (១) ជាអាទិភាពនៃកំណែទម្រង់ (២) ដំឡើងកម្រិតជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញដែលមានមហាវិទ្យាល័យចំណុះ (៣) ពង្រីកកម្មវិធីអប់រំគ្រូបង្រៀនគ្រប់មុខវិជ្ជាឯកទេសសម្រាប់ផ្គត់ផ្គង់នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ (៤) គាំទ្រដល់គ្រឹះស្ថានបណ្តុះ-បណ្តាលគ្រូបង្រៀនផ្សេងទៀតក្នុងប្រទេសកម្ពុជា (៥) ពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាដៃគូអភិវឌ្ឍក្នុងនិងក្រៅប្រទេស។

យោងតាមសារណារបស់លោក ឈុំ សារ៉ាត់ (២០១៩) និក្ខេបបទរបស់លោក ចាន់ សុភាព (២០២១) ឯកសាររបស់SEAMEO INNOTECH (២០១៦) បានបង្ហាញពីក្របខណ្ឌសមត្ថភាពនាយកសាលានៅអាស៊ីអាគ្នេយ៍ជាគោលចំនួន៥ រួមមាន៖ (១) គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្ត (២) ភាពជាអ្នកដឹកនាំគ្រប់គ្រង (៣) ភាពជាអ្នកដឹកនាំការបង្រៀននិងរៀន (៤) ឧត្តមភាពផ្ទាល់ខ្លួន និង (៥) ការចូលរួមពីភាគីពាក់ព័ន្ធ។

### ២.៦.២ មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេស

ក្រសួងអប់រំ យុវជន និងកីឡា (២០២២) បានកំណត់មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេសមានមូលដ្ឋានគ្រឹះសំខាន់ៗ ៣ គឺ៖ (១) អភិវឌ្ឍវិជ្ជាជីវៈគ្រូឧទ្ទេសខ្លួន (២) អភិវឌ្ឍសមត្ថភាពគរុសិស្សលើគរុកោសល្យនិងវិធីសាស្ត្របង្រៀន (៣) អភិវឌ្ឍសមត្ថភាពគរុសិស្សលើខ្លឹមសារមុខវិជ្ជានិងរបៀបរៀនរបស់គរុសិស្ស។ ឯកសាររបស់**ឯកឧត្តមបណ្ឌិត សិត សេង** (២០២១) បានបង្ហាញថាស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ការអប់រំគ្រូបង្រៀននៅវិទ្យាស្ថានគរុកោសល្យ (១) ចំណេះដឹងវិជ្ជាជីវៈ (២) ការប្រតិបត្តិវិជ្ជាជីវៈ (៣) ការអភិវឌ្ឍវិជ្ជាជីវៈ (៤) សីលធម៌វិជ្ជាជីវៈ (៥) ការស្រាវជ្រាវអប់រំ (៦) ការអភិវឌ្ឍកម្មវិធីអប់រំ។

ឯកសាររបស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** (២០២១) ស្តីពីនវានុវត្តន៍ និងទិសដៅកំណែទម្រង់វិស័យអប់រំឆ្ពោះទីកាន់ការអប់រំឌីជីថល បានបង្ហាញថា វិធីបង្រៀនបំណិនសតវត្សទី២១ សំបូរបែបស្របតាមបរិបទ រួមមាន៖

(១) **វិធីសាស្ត្របង្រៀនដោយផ្ទាល់** (Direct Instruction Model)៖ វិធីនេះគ្រូដឹកនាំសិស្សឱ្យចេះគិតរៀនដោយខ្លួនឯងប្រើចំណេះដឹងខ្លួនមាន។

(២) **វិធីសាស្ត្របង្រៀនឱ្យចេះបង្កើតបញ្ញត្តិ** (Concept Development Model)៖ វិធីសិស្សមជ្ឈមណ្ឌលឱ្យសិស្សយល់បញ្ញត្តិតាមរយៈអនុមានរួម ចេះគិតទូលាយ និងចេះសំយោគសរុប។

(៣) **វិធីសាស្ត្របង្រៀនបែបរិះរក** (Inquiry Model)៖ វិធីបង្រៀនសិស្សឱ្យមានបំណិន ចំណេះដឹងសម្រាប់ការដោះស្រាយបញ្ហាក្នុងជីវភាពប្រចាំថ្ងៃ។

(៤) **វិធីសាស្ត្របង្រៀនបែបសហការ** (Cooperative Learning Model)៖ វិធីនេះជួយសិស្សឱ្យសិស្សចេះធ្វើការងារជាក្រុម និងចេះប្រាស្រ័យទាក់ទងគ្នា។

(៥) **វិធីសាស្ត្របង្រៀនបែបបញ្ចូលគ្នា** (Integrative Model)៖ វិធីនេះជួយសិស្សរៀនដោយឯករាជ្យ ត្រិះរិះពិចារណា វិភាគ ធ្វើការតស៊ូមតិ និងសន្ទនា។

កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សផ្នែកឌីជីថលធ្វើយ៉ាងណាឱ្យអ្នកពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យា ដែលនឹងចែករំលែកបន្តទៅដល់

សិស្សានុសិស្ស គរុសិស្ស ដែលជាធនធានមនុស្សជំនាន់ថ្មីចូលរួមក្នុងការប្រកួតប្រជែងក្នុងទីផ្សារការងារ ហង់ជួន ណារ៉ុន (២០២១)។

យោងតាម Laura M. Desimone (2009) បានកំណត់ពីគុណតម្លៃនៃការអភិវឌ្ឍសមត្ថភាពរួមមាន (១) គ្រូបង្រៀនមានបទពិសោធអភិវឌ្ឍវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព (Teacher experience effective professional development) (២) ការអភិវឌ្ឍបង្កើនសមត្ថភាពគ្រូបង្រៀនប្រកបដោយវិជ្ជាជីវៈ (The professional development increases teacher's competency) (៣) គ្រូបង្រៀនប្រើប្រាស់វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងជំនឿ ដើម្បីកែលម្អខ្លឹមសារវិធីសាស្ត្រគរុកោសល្យ (Teacher use their new knowledge, skills, attitudes and beliefs to improve their content on their pedagogy approach) (៤) ការផ្លាស់ប្តូរការបង្រៀននិងលទ្ធផលសិក្សារបស់សិស្សរីកចម្រើន (The instructional changes foster increased student learning)។ (Sok Serey, 2021) ។

រូបភាពទី 6៖ គោលការណ៍ការអភិវឌ្ឍសមត្ថភាពប្រកបដោយវិជ្ជាជីវៈលើគ្រូបង្រៀន និងសិស្ស




*ប្រភព៖ Laura M. Desimone (2009), Sok Serey (2021) (NIE, 2021)*

យោងតាមអង្គការចៃកា (JICA, ២០២២) បានផ្ដល់នូវគម្រោងខ្លះៗដល់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការក្នុងការឆ្លើយតបទៅនឹងការកំណែទម្រង់ការអប់រំគ្រូបង្រៀនដែលជាចំណុចអាទិភាពរបស់ប្រទេសជាតិ ជាពិសេសសម្រាប់មុខវិជ្ជាស្ទែម (STEM[2]) សម្រាប់ការកសាងនូវសមត្ថភាពដែលជាស្នូលរបស់វិទ្យាស្ថានគរុកោសល្យ ដូចជាកម្មវិធីសិក្សាលម្អិតសម្រាប់ការអប់រំ រយៈពេលបួនឆ្នាំ និងយុទ្ធសាស្ត្រសម្រាប់កាត់ឡើងគុណវុឌ្ឍិគ្រូបង្រៀន។

យោងតាមឯកសារស្ដីពីបំណិនផ្ដល់ព័ត៌មានត្រឡប់ របស់នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ (២០១៦, p.2) បានបង្ហាញពីលក្ខណៈសម្បត្តិរបស់គ្រូឧទ្ទេសដើម្បីដឹកនាំកម្មសិក្សាគរុកោសល្យឱ្យបានល្អប្រសើរ ដូចខាងក្រោម៖

(១) **ធ្វើជាគំរូល្អ៖** ជាមនុស្សដែលមានការគោរព ស្រឡាញ់ពីអ្នកដទៃ ជាគំរូល្អដល់មនុស្សទូទៅដោយស្ដែងចេញពីអាកប្បកិរិយា និងឥរិយាបថរបស់ខ្លួន។

(២) **ស្ដាប់ដោយសកម្ម៖** ជាអ្នកស្ដាប់សកម្ម ស្ដាប់មតិអ្នកដទៃ និងស្វែងយល់បញ្ហារបស់កម្មសិក្សាការី ការិនី ដោយយកចិត្តទុកដាក់ផ្ដល់ឱកាសដល់កម្មសិក្សាការី ការិនី បញ្ចេញមតិយោបល់។

(៣) **កំណត់បែបបទការងារបានច្បាស់លាស់៖** ធានាថាកម្មសិក្សាការី ការិនី អនុវត្តបែបបទការងារបានត្រឹមត្រូវតាមបទបញ្ញត្តិកម្មសិក្សាគរុកោសល្យ។

(៤) **មានបំណិនក្នុងការវិភាគ៖** គ្រូណែនាំត្រូវចេះធ្វើការវិភាគខ្លឹមសារមេរៀន និងឥរិយាបថរបស់កម្មសិក្សាការី ការិនី ព្រមទាំងផ្ដល់ព័ត៌មានត្រឡប់ដោយភាពជាក់លាក់ និងស្មោះត្រង់។

(៥) **មានការតាំងចិត្តក្នុងតួនាទីជាអ្នកផ្ដល់ព័ត៌មានត្រឡប់៖** គ្រូណែនាំត្រូវមានការតាំងចិត្តក្នុងការយកចិត្តទុកដាក់លើសុខុមាលភាព និងការអភិវឌ្ឍវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី អាចអភិវឌ្ឍសមត្ថភាព។

---

[2] ក្រសួងអប់រំបានដាក់ចេញគោលនយោបាយ ស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (Science, Technology, Engineering, and Mathematics, STEM) ដើម្បីជំរុញកម្ពុជាឱ្យសម្រេចបាននូវចក្ខុវិស័យ ២០៣០ និង ២០៥០ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា (ក្រសួងអយក, ២០១៦)។

(៦) **ទទួលយកកម្មសិក្សាការី ការិនី ដោយពេញចិត្ត៖** គ្រូណែនាំបង្ហាញការយកចិត្តទុកដាក់ទៅកាន់កម្មសិក្សាការី ការិនី វាអាចបង្កើតនូវបរិយាកាសកក់ក្តៅដល់គរុសិស្សពីគ្រូណែនាំ។

(៧) **មានបំណិនគាំទ្រផ្នែកគរុកោសល្យ៖** គ្រូណែនាំជាគ្រូដែលមានបទពិសោធន៍ និងមានឆន្ទៈក្នុងការចែករំលែកនូវអ្វីដែលខ្លួនបានដឹងដល់អ្នកដទៃ។

(៨) **ធ្វើជាគំរូជាអ្នករៀនពេញមួយជីវិត៖** គ្រូណែនាំបង្ហាញថា ខ្លួនជាអ្នកមានចំណង់ចំណូលចិត្តក្នុងការរៀនសូត្របន្ត ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងឆ្លុះបញ្ចាំងពីដំណើការបង្រៀនរបស់ខ្លួនឱ្យបានល្អប្រសើរជាប្រចាំ។

(៩) **ផ្តល់សង្ឃឹម និងគំនិតសុទិដ្ឋិនិយម៖** លើកទឹកទឹកចិត្តដើម្បីឱ្យកម្មសិក្សាការី ការិនី មានការអភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈ។

### ២.៦.៣ ការចូលរួមពីភាគីពាក់ព័ន្ធវិស័យអប់រំ

យោងតាមក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ការពង្រឹងតម្លាភាពការចូលរួមរបស់សហគមន៍ រួមមាន៖ (១) តម្លាភាពក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (២) តម្លាភាពក្នុងការធ្វើផែនការ សាលារៀននិងការគ្រោងថវិកា (៣) តម្លាភាពក្នុងការចំណាយ ការរកមូលនីធិ ការផ្សព្វផ្សាយទិន្នន័យហិរញ្ញវត្ថុ (៤) តម្លាភាពក្នុងការអនុវត្តនិងប្រតិបត្តិសាលារៀន (៥) តម្លាភាពពីលទ្ធផលសិក្សា (៦) តម្លាភាពក្នុងការបង្កើតគៈកម្មការសាងសង់និងជួសជុលសាលារៀន និង (៧) តម្លាភាពការកសាងសមត្ថភាពសាលារៀន។

យោងតាមសារណារបស់ ឈុំ សារ៉ាត់ (២០១៩) ការចូលរួមពីភាគីពាក់ព័ន្ធដើម្បី៖ (១) លើកកម្ពស់ការទទួលខុសត្រូវ និងចែករំលែកសម្រាប់កែលម្អសាលារៀន (កសាងទំនុកចិត្ត ពង្រឹងអំណាចសហគមន៍ក្នុងការលើកកម្ពស់សាលារៀន) (២) គ្រប់គ្រងកិច្ចសហប្រតិបត្តិការ និងបណ្តាញអប់រំ (សម្រាបសម្រួលជាមួយដៃគូ ជាមួយសហគមន៍) (៣) រក្សានិរន្តភាព ទំនាក់ទំនងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ (គាំទ្រកម្មវិធីសិក្សា ផ្សព្វផ្សាយការបំពេញការងារសាលារៀន)។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប**" អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ និងបែបគុណវិស័យ ដើម្បីឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ និងបង្ហាញឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប។ វិធីសាស្ត្រតាមបែបបរិមាណវិស័យ គឺប្រើកម្រងសំណួរដើម្បីប្រមូលទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេសគរុសិស្ស នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប និងរកឱ្យឃើញនូវលទ្ធផលជាចំនួនជាក់លាក់នៃកម្រិតចង្អុលបង្ហាញអត្រាពិន្ទុពីទាបបំផុត "១" ដល់ខ្ពស់បំផុត "៥" និងតម្លៃមធ្យមភាគនៃកម្រិតអត្រាពិន្ទុពីកម្រងសំណួរ និងវិធីសាស្ត្រតាមបែបគុណវិស័យដើម្បីទទួលបានទស្សនៈយល់ឃើញរបស់ថ្នាក់ដឹកនាំគ្រប់គ្រងអប់រំ និងភាគីពាក់ព័ន្ធ។

## ៣.១ គម្រោងស្រាវជ្រាវ

គម្រោងស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ និងតាមបែបគុណវិស័យ។

អ្នកសិក្សាស្រាវជ្រាវបានការពារគម្រោងស្រាវជ្រាវនិក្ខេបបទ នាថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០២២ ការវាយតម្លៃតម្រង់ទិសរបស់គណៈកម្មការ និងការឯកភាពប្រធានបទពីគ្រូណែនាំគោល គ្រូណែនាំរង។

អ្នកសិក្សាស្រាវជ្រាវបានចាប់ផ្ដើមចុះប្រមូលទិន្នន័យពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ដោយយោងតាមលិខិតលេខ ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតលេខ ៥៩៦ អយក.ផក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។

### ៣.១.១ វិធីសាស្ត្របែបបរិមាណវិស័យ

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចុះប្រមូលទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេសគរុសិស្ស ដោយចែកជាពីរផ្នែក៖ ផ្នែកទី១ ព័ត៌មានទូទៅ ផ្នែកទី២ស្ថានភាពនៃការធានាគុណភាពអប់រំ។

### ៣.១.២ វិធីសាស្ត្រវែបគុណវិស័យ

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់សំណួរសម្ភាសន៍ប្រមូលទិន្នន័យបន្ថែមពីភាគីពាក់ព័ន្ធ រួមមាន៖ (១) បុគ្គលិកគ្រប់គ្រងអបរំនៃមន្ទីរអប់រំ (២) អ្នកជំនាញឯកទេសគ្រប់គ្រងអប់រំ ដើម្បីទទួលបានទស្សនៈយល់ឃើញសំខាន់ៗ និងផ្ទៀងផ្ទាត់ខ្លឹមសារតម្លៃមធ្យមភាគពិន្ទុជាមួយនឹងទិន្នន័យដែលបានប្រមូលតាមរយៈកម្រងសំណួរ ដើម្បីលើកយកមកពិភាក្សា។

## ៣.២ ការប្រមូលទិន្នន័យ

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេសជាមួយគ្រូណែនាំគោល គ្រូណែនាំរង ពីជំពូក១ដល់ជំពូក៣ នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ដើម្បីប្រមូលទិន្នន័យចម្បងបានគ្រប់គ្រាន់ អ្នកសិក្សាស្រាវជ្រាវបានអនុវត្តដំណើរការតាមដំណាក់កាលនីមួយៗដោយយកលិខិតលេខ ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈវិទ្យាស្ថានជាតិអប់រំ (NIE) ជម្រាបជូនថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ហើយបានស្នើសុំគោលការណ៍ពីលោកប្រធានមន្ទីរអប់រំចេញលិខិតជម្រាបមកនាយកសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តសៀមរាប និងអង្គភាពពាក់ព័ន្ធដើម្បីគោរពជូនជ្រាបជាព័ត៌មាន តាមលិខិតលេខ ៥៩៦ អយកខ.ផក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។ អ្នកសិក្សាស្រាវជ្រាវបានថតចម្លង(ត្រឹមត្រូវតាមច្បាប់ដើម) លិខិតអនុញ្ញាតពីមន្ទីរអប់រំជម្រាបជូនលោកនាយកដោយផ្ទាល់ និងតាមប្រព័ន្ធតេលេក្រាម (Telegram Application) ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យព្រមទាំងបានពន្យល់ពីគោលបំណងនៃការចុះស្រាវជ្រាវនាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឆ្លើយតបតាមលិខិតលេខ ២៣៤២ អយក.វជអ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ពីកាលបរិច្ឆេទជាក់លាក់នៃការចុះប្រមូលទិន្នន័យចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរដោយផ្ទាល់មានរយៈពេលមួយថ្ងៃ គឺថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ដោយយោងតាមលិខិតលេខ ១៩៧ សគវ.សរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ របស់សាលាគុរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប។ អ្នកសិក្សាស្រាវជ្រាវបានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតបតាមពេលកំណត់ជាក់លាក់។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវក៏បានសម្ភាសន៍ជាមួយអ្នកជំនាញគ្រប់គ្រងអប់រំបន្ថែមទៀត នាថ្ងៃទី១១ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យទៅនឹងលទ្ធផលទទួលបានពីកម្រងសំណួរ។ ចំពោះទិន្នន័យមានស្រាប់ អ្នកសិក្សាស្រាវជ្រាវបានដកស្រង់ខ្លឹមសារទាំងអត្ថន័យពីឯកសារ ឬរបាយការណ៍ដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនេះតាមការឯកភាពពីគ្រូណែនាំគោល និងគ្រូណែនាំរង។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

### ៣.៣.១ ការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ

ទិន្នន័យជាបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវបានដកស្រង់សូចនាករចេញពីស្តង់ដាជាតិអប្បបរមាទាំង៩ (ACC, 2016, 2019) ដែលបានកំណត់ក្នុងការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានសិក្សាដើម្បីរៀបចំកម្រងសំណួរស្រាវជ្រាវឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ និងសំណួរស្រាវជ្រាវសម្រាប់ប្រមូលទិន្នន័យតាមចំនួនសំណាកមកធ្វើការវិភាគ។

#### ៣.៣.១.១ កម្រិតអត្រាពិន្ទុចង្អុលបង្ហាញ

យោងតាម Diane R. Edmondson (2005); Zainudin Awang, Asyraf Afthanorhan, Mustafa Mamat បានបង្ហាញកម្រិតចង្អុលបង្ហាញមាន៥កម្រិត (a 5-level Likert scale)។ គោលការណ៍ និងនីតិវិធីនៃការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ (ACC, 2016, 2019) ការផ្តល់ពិន្ទុលើសូចនាករសម្រាប់ស្តង់ដានីមួយៗតាមអត្រាពិន្ទុមាន៥កម្រិត ពីទាបបំផុត "១" ទៅខ្ពស់បំផុត "៥" (Pen Sithol, 2015); (Vagias, Wade M, 2006) ដូចខាងក្រោម៖

**កម្រិតអត្រាពិន្ទុចង្អុលបង្ហាញ៖**

**៥** = បានអនុវត្តសូចនាករពេញលេញតាមតម្រូវការ (Accreditation Status)

៤ = បានអនុវត្តសូចនាករស្មើតែពេញលេញតាមតម្រូវការ ( Average Score for all Standards )

៣ = បានអនុវត្តសូចនាករជាមធ្យម ឬ លើសពីកម្រិតមធ្យម ធៀបនឹងតាមតម្រូវការ ( The Average for Each Standard )

២ = បានអនុវត្តសូចនាករក្រោមមធ្យមធៀបនឹងតាមតម្រូវការ ( Rating Scale for Each Standard )

១ = បានអនុវត្តសូចនាករបានបន្តិចបន្តួចតាមតម្រូវការ ( The Rating Scale for Each Indicator )។

### ៣.៣.១.២ ការគណនាពិន្ទុសរុបសម្រាប់ស្តង់ដាទាំង៩ និងលទ្ធផលនៃការវាយតម្លៃ

យោងតាម ACC ( 2016 ) បានបង្ហាញពីរបៀបគណនាពិន្ទុសរុបសម្រាប់ស្តង់ដាទាំង៩៖

(ក) ការគណនាពិន្ទុមធ្យមភាគសម្រាប់ស្តង់ដានីមួយៗ ដោយយកពិន្ទុសរុបរួមទាំងអស់នៃសូចនាករ ចែកនឹងចំនួនសូចនាករដែលមាននៅក្នុងស្តង់ដានីមួយៗ។

(ខ) ការគណនាពិន្ទុមធ្យមភាគសម្រាប់ស្តង់ដាទាំង៩ ដើម្បីសម្រេចយកលទ្ធផលចុងក្រោយត្រូវធ្វើឡើងដោយយកពិន្ទុមធ្យមភាគសម្រាប់ស្តង់នីមួយៗ គុណនឹង មេគុណនៃស្តង់ដានីមួយៗរួចចែកនឹងផលបូកមេគុណសរុប ( ៣០ ) ដូចតារាងខាងក្រោម៖

តារាងទី 4៖ តារាងគណនាពិន្ទុសរុប

| លរ | ស្តង់ដា * | ពិន្ទុមធ្យមភាគ | មេគុណ | ផលគុណ |
|---|---|---|---|---|
| ១ | ចក្ខុវិស័យ បេសកកម្ម និងគោលដៅ<br>Vision, Mission and Goals<br>*( ៣ សូចនាករ )* | | ១ | |
| ២ | អភិបាលកិច្ច និងការគ្រប់គ្រង<br>Governance and Management<br>*( ៦ សូចនាករ )* | | ២ | |
| ៣ | បុគ្គលិកអប់រំ Academic Staff<br>*( ១១ សូចនាករ )* | | ៥ | |

| | | | | |
|---|---|---|---|---|
| ៤ | កម្មវិធីអប់រំ Academic Program<br>*(៧ សូចនាករ)* | | ៥ | |
| ៥ | សេវាគុស្សិស្ស និស្សិត<br>Student Services<br>*(១៣ សូចនាករ)* | | ៣ | |
| ៦ | ធនធានសិក្សា Learning Resources<br>*(១៤ សូចនាករ)* | | ៤ | |
| ៧ | ធនធានរូបវន្ត Physical Resources<br>*(៦ សូចនាករ)* | | ៣ | |
| ៨ | ធនធានហិរញ្ញវត្ថុ<br>Financial Resources<br>*(៦ សូចនាករ)* | | ៤ | |
| ៩ | ការធានាគុណភាពផ្ទៃក្នុង<br>Internal Quality Assurance<br>*(៦ សូចនាករ)* | | ៣ | |
| | | | **ផលគុណសរុប** | |
| | | | **ពិន្ទុមធ្យមភាគសរុប** | |

*ប្រភព៖ ACC (2016); Pen Sithol (2015)     ( * សរុបស្តង់ដា ចំនួន៩ = ៧២ សូចនាករ)*

តារាងទី 5៖ តារាងពិន្ទុមធ្យមភាគស្តង់ដានីមួយៗ

| **មធ្យមភាគ** | **និទ្ទេស** | **អត្ថន័យ** |
|---|---|---|
| ៤.៥០ - ៥.០០ | **ល្អណាស់** | បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិទាំងអស់ |

| | | |
|---|---|---|
| ៣.៥០ - ៤.៤៩ | **ល្អ** | បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិភាគច្រើន |
| ២.៥១ - ៣.៤៩ | **ល្អបង្គួរ** | បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិលើសពីកម្រិតមធ្យម |
| ២.៥០ | **មធ្យម** | បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិកម្រិតមធ្យម |
| ១.០០ - ២.៤៩ | **ខ្សោយ** | បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិបានកម្រិតតិចតួច ឬក្រោមមធ្យម |

*ប្រភព៖ ACC (2016)*

តារាងទី 6៖ តារាងលទ្ធផលនៃការវាយតម្លៃ

| **លរ** | **ពិន្ទុមធ្យមសរុប** | **ការទទួលស្គាល់គុណភាពអប់រំ** |
|---|---|---|
| ១ | ៣.៥០ ដល់ ៥.០០ | ពេញសិទ្ធិ (៥ឆ្នាំ) |
| ២ | ២.៥០ ដល់ ៣.៤៩ | បណ្តុះអាសន្ន (៣ឆ្នាំ) |
| ៣ | ១.០០ ដល់ ២.៤៩ | បេក្ខភាព (២ឆ្នាំ) |

*ប្រភព៖ ACC (2016)*

### ៣.៣.១.៣ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

**ផ្នែកទី១៖ ព័ត៌មានទូទៅ៖** មាន៦សំណួរទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស បង្រៀនមុខវិជ្ជា។

**ផ្នែកទី២៖ ស្ថានភាពនៃការធានាគុណភាពអប់រំ៖** មាន៧២សំណួរនៃខ្លឹមសារនីមួយៗតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំមាន៩ គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវានិស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨)ធនធានហិរញ្ញវត្ថុ (៩)ការធានាគុណភាពអប់រំផ្ទៃក្នុង។

### ៣.៣.១.៤ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស

**ផ្នែកទី១៖ ព័ត៌មានទូទៅ៖** មាន៦សំណួរទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស បង្រៀនមុខវិជ្ជា។

**ផ្នែកទី២៖ ស្ថានភាពនៃការធានាគុណភាពអប់រំ៖** មាន៧២សំណួរនៃខ្លឹមសារនីមួយៗតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំមាន៩ គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥)សេវានិស្សិត (៦)ធនធានសិក្សា (៧) ធនធានរូបវន្ត (៨)ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

### ៣.៣.១.៥ កម្រងសំណួរសម្រាប់គរុសិស្ស

**ផ្នែកទី១៖ ព័ត៌មានទូទៅ៖** មាន៨សំណួរទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន ភេទ អាយុ កម្រិតវប្បធម៌ កម្រិតថ្នាក់របស់គរុសិស្ស(ឆ្នាំទី២) ស្ថានភាពគ្រួសារ កត្តាជំរុញឱ្យចូលរៀននៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងបទពិសោធន៍ធ្លាប់បង្រៀនសិស្ស។

**ផ្នែកទី២៖ ស្ថានភាពនៃការធានាគុណភាពអប់រំ៖** មាន៧២សំណួរនៃខ្លឹមសារនីមួយៗតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំមាន៩ គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវាគរុសិស្ស/និស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨) ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

## ៣.៣.២ ការសិក្សាស្រាវជ្រាវបែបគុណវិស័យ

### ៣.៣.២.១ អ្នកចូលរួមសម្ភាសន៍

អ្នកសិក្សាស្រាវជ្រាវប្រមូលទិន្នន័យបន្ថែមតាមរយៈការសម្ភាសន៍ (Semi-Structured Interview) ជាមួយអ្នកចូលរួមកិច្ចសម្ភាសន៍សរុបចំនួន៦នាក់ ស្រី១នាក់ ទៅលើបុគ្គលិកអប់រំភាគីពាព័ន្ធ៖ (១)ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត (២)ថ្នាក់ដឹកនាំការិយាល័យជំនាញនៃមន្ទីរអប់រំខេត្ត ដើម្បីឱ្យលទ្ធផលការស្រាវជ្រាវឆ្លើយតបនឹងគោលបំណងនៃការស្រាវជ្រាវ និងផ្ទៀងផ្ទាត់លទ្ធផលទៅនឹងកម្រងសំណួរដែលបានប្រើប្រាស់បែបបរិមាណវិស័យ។ សំណួរសម្ភាសន៍ជាប្រភេទសំណួរទម្រង់បើកដើម្បីសួរទៅកាន់ភាគីពាក់ព័ន្ធចូលរួមសម្ភាសន៍ផ្តល់ទិន្នន័យតាមបទពិសោធន៍ ការពិភាក្សាស៊ីជម្រៅទៅលើបញ្ហាដែលជាឧបស័គ្គនៃការធានាគុណភាពអប់រំដែលទាក់ទងនឹងប្រធានបទដែលបានយកមកសិក្សាស្រាវជ្រាវ។ អ្នកសិក្សាស្រាវជ្រាវសម្ភាសន៍

អ្នកចូលរួមតាមពេលវេលាសមស្របដោយប្រើភាសាខ្មែរក្នុងកិច្ចសម្ភាសន៍ និងការសង្កេត (Observation Protocol) ក្នុងពេលសម្ភាសន៍។

**លក្ខខណ្ឌសម្រាប់អ្នកចូលរួមកិច្ចសម្ភាសន៍ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត៖**

- បំពេញការងារក្នុងមុខតំណែងជាថ្នាក់ដឹកនាំគ្រប់គ្រងអប់រំក្នុងមន្ទីរអប់រំ
- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់
- មានបទពិសោធការងារក្នុងវិស័យអប់រំចាប់ពី២០ឆ្នាំឡើងទៅ
- មានបទពិសោធការងារក្នុងការងារដឹកនាំគ្រប់គ្រងនៅមន្ទីរអប់រំចាប់ពី៦ឆ្នាំឡើងទៅ
- មានបទពិសោធក្នុងការងារដឹកនាំគ្រប់គ្រង គ្រូឧទ្ទេស ការងារអប់រំចុះអធិការកិច្ចជួយនាយក លោកគ្រូអ្នកគ្រូបង្រៀនតាមកម្រិតភូមិសិក្សានៅសាលារៀន ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុងស្រុកទាំង១២ក្នុងខេត្តសៀមរាប
- មានបទពិសោធចូលរួមជាប្រតិភូទស្សនកិច្ចសិក្សាក្រៅប្រទេស។

**លក្ខខណ្ឌសម្រាប់អ្នកចូលរួមកិច្ចសម្ភាសន៍ពីអតីតនាយកសាលាតំណាងសហគមន៍៖**

- បំពេញការងារក្នុងមុខតំណែងជាអ្នកដឹកនាំគ្រប់គ្រងនៅសាលាសាធារណៈ ឬសាលាឯកជន
- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់
- មានបទពិសោធការងារក្នុងវិស័យអប់រំចាប់ពី២០ឆ្នាំឡើងទៅ
- មានបទពិសោធក្នុងការងារដឹកនាំគ្រប់គ្រង គ្រូឧទ្ទេស ការងារអប់រំចុះជួយនាយកសាលា លោកគ្រូអ្នកគ្រូបង្រៀននៅសាលារៀនក្នុងក្រុងស្រុកទាំង១២ក្នុងខេត្តសៀមរាប
- មានបទពិសោធចូលរួមជាប្រតិភូទស្សនកិច្ចសិក្សាក្រៅប្រទេស។

### ៣.៣.២.២ នីតិវិធីនៃការសម្ភាសន៍

អ្នកសិក្សាស្រាវជ្រាវប្រើសំណួរសម្ភាសន៍ ដោយផ្តោតលើខ្លឹមសារស្រង់ចេញពីកម្រងសំណួរតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំទាំង៩ (ACC, 2016, 2019) រួមមាន៖ (១) ចក្ខុវិស័យ បេសកកម្ម

និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវាគុសិស្ស/និស្សិត (៦)ធនធានសិក្សា (៧)ធនធានរូបវន្ត (៨)ធនធានហិរញ្ញវត្ថុ (៩)ការធានាគុណភាពអប់រំផ្ទៃក្នុង។

#### ៣.៣.២.៣ ការប្រមូលទិន្នន័យបែបគុណវិស័យ

អ្នកសិក្សាស្រាវជ្រាវប្រមូលទិន្នន័យតាមបែបគុណវិស័យ គឺប្រើប្រាស់ការសម្ភាសន៍ផ្ទាល់ដែលមានសំណួរគោលសំខាន់ៗទាក់ទងនឹងការធានាគុណភាពអប់រំ។ អ្នកសិក្សាស្រាវជ្រាវជ្រើសរើសអ្នកចូលរួមដោយជម្រាបជូនព័ត៌មានច្បាស់លាស់ យោងលិខិតលេខ ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈវិទ្យាស្ថានជាតិអប់រំ (NIE) និងលិខិតលេខ ៥៩៦ អយកខ.ផក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ដោយកំណត់កាលបរិច្ឆេទពេលវេលាសមស្រប។ មុននឹងសម្ភាសន៍តាមសំណួរនីមួយៗ អ្នកសិក្សាស្រាវជ្រាវគោរពថ្លែងអំណរគុណចំពោះក្រុមគោលដៅបានចូលរួមដោយបានចំណាយពេលវេលាដ៏មានតម្លៃក្នុងកិច្ចសម្ភាសន៍ ព្រមទាំងប្រាប់ពីគោលបំណងនៃការស្រាវជ្រាវនេះផងដែរដោយផ្តោតលើប្រធានបទស្រាវជ្រាវ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំការអនុញ្ញាតថតសំឡេងលើដំណើរការនៃការសម្ភាសន៍ដោយសួរសំណួរតាមលំដាប់លំដោយនៃសំណួរសម្ភាសន៍ ទុកសម្រាប់ធ្វើការវិភាគទិន្នន័យ។

### ៣.៤ ការជ្រើសរើសភាគសំណាក

អ្នកសិក្សាស្រាវជ្រាវចុះប្រមូលទិន្នន័យតាមភាគសំណាកនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្ថិតនៅក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

ទិន្នន័យប្រមូលពីសាលាគរុកោលសល្យ និងវិក្រឹតការខេត្ត (Taro Yamane, 1967)៖

ទិន្នន័យប្រមូលពីនាយក/រង គ្រូឧទ្ទេស គរុសិស្ស (Taro Yamane, 1967) តាមរូបមន្ត៖ $n = \frac{N}{1 + N*(e)^2}$ ដែល៖ n = Sample size (ទំហំ ឬ ចំនួនសំណាក) N = Population size (ទំហំ ឬ ចំនួនប្រជាករ) e = Sampling error (0.10=10%, 0.07=7%, 0.05=5% កម្រិតនៃភាពខុសឆ្គងក្នុងការជ្រើសរើសសំណាក)។

តារាងទី 7៖ ចំនួនសំណាកទិន្នន័យប្រមូលពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស

| ល.រ | ឈ្មោះក្រុង | ឈ្មោះគ្រឹះស្ថានសិក្សា | ចំនួនគណៈគ្រប់គ្រង | ចំនួនគ្រូឧទ្ទេស | ចំនួនគរុសិស្ស | សរុបរួម |
|---|---|---|---|---|---|---|
| ១ | សៀមរាប | សាលាគរុកោសល្យ និងវិក្រឹតការ ខេត្តសៀមរាប | ៣ | ៤៤ | ១២៩ | **១៧៦** |

ទិន្នន័យប្រមូលពីថ្នាក់ដឹកនាំអង្គភាពគ្រប់គ្រងអប់រំ (ចៃដន្យ Random)៖

តារាងទី ៨៖ ចំនួនសំណាកផ្តល់កិច្ចសម្ភាសន៍

| ល.រ | ថ្នាក់ដឹកនាំអង្គភាព | ចំនួន |
|---|---|---|
| ១ | ប្រធាន/អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | ១ |
| ២ | ប្រធាន/អនុប្រធានការិយាល័យបឋមសិក្សា | ១ |
| ៣ | ប្រធាន/អនុប្រធានការិយាល័យមធ្យមសិក្សា | ១ |
| ៤ | ប្រធាន/អនុប្រធានការិយាល័យអធិការកិច្ច | ១ |
| ៥ | ប្រធាន/អនុប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល | ១ |
| ៦ | ប្រធាន/អនុប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | ១ |
| **សរុប** | | **៦** |

## ៣.៥ ការវិភាគទិន្នន័យ

### ៣.៥.១ ការវិភាគទិន្នន័យបែបបរិមាណវិស័យ

អ្នកសិក្សាស្រាវជ្រាវបានវិភាគទិន្នន័យផ្តោតលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែកតាមកម្រិតអត្រាពិន្ទុចង្អុលបង្ហាញក្នុងកម្រងសំណួរបែបទម្រង់បិទ។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យដែលប្រមូលបានពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស និង

អ្នកពាក់ព័ន្ធតាមប្រព័ន្ធកុំព្យូទ័រដោយប្រើកម្មវិធី Microsoft Excel ដើម្បីផ្ទុកទិន្នន័យដែលប្រមូលពីកម្រង សំណួរហើយធ្វើការបកស្រាយដោយប្រើកម្មវិធី Microsoft Word ដូចខាងក្រោម៖

### ៣.៥.១.១ ភាគរយ

ភាគរយ (The Percentage) ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$\% = \frac{f}{\mathrm{N}} x\ 100$ ដែល៖

% ជំនួយ ភាគរយ (Percentage)

$f$ ជំនួស ប្រេកង់ដែលត្រូវការប្រែជាភាគរយ

N ជំនួស ទំហំ ឬ ចំនួនប្រជាករ (Population size)។

### ៣.៥.១.២ មធ្យមភាគ

មធ្យម (The Mean) ដោយប្រើរូបមន្ត (John W. Best, James V. Kahn, 1998; Olive Jean Dunn, Virginia A. Clark, 2009) ដូចខាងក្រោម៖

$\overline{X} = \frac{\sum X}{N}$ (មានន័យថា $\overline{X}$ = $(X_1+X_2+X_3+\ldots+X_n)/N$) ដែល៖

$\overline{X}$ ជំនួស មធ្យមភាគ (X-bar)

$\Sigma$ ជំនួស លទ្ធផលរួមរបស់ទិន្នន័យ ឬ កម្រិតអត្រាពិន្ទុ (sum of)

$X$ ជំនួស ទិន្នន័យ ឬ កម្រិតអត្រាពិន្ទុ (score in a distribution)

N ជំនួស ចំនួនទិន្នន័យនៃកម្រិតអត្រាពិន្ទុ (number of scores)។

### ៣.៥.១.៣ គម្លាតស្តង់ដា

គម្លាតស្តង់ដា (The Standard Deviation) ដោយប្រើរូបមន្ត (John W. Best, James V. Kahn, 1998; Olive Jean Dunn, Virginia A. Clark, 2009) ដូចខាងក្រោម៖

$\mathrm{S} = \frac{\sqrt{\Sigma(X - \overline{X})^2}}{\mathrm{n} - 1}$ ដែល៖

S ជំនួស តម្លៃគម្លាតស្តង់ដា

$\sum X^2$ ជំនួស លទ្ធផលរួមរបស់ទិន្នន័យ ឬ កម្រិតអត្រាពិន្ទុនីមួយៗ

n ជំនួស ចំនួនភាគសំណាក (Sample size)។

### ៣.៥.២ ការវិភាគទិន្នន័យតាមបែបគុណវិស័យ

ក្រោយពីបានប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២២ រួចមក ទិន្នន័យតាមបែបគុណវិស័យត្រូវបានរៀបចំវិភាគ។ អ្នកសិក្សាស្រាវជ្រាវបានកត់ត្រារាល់ពាក្យសំដីដែលអ្នកចូលរួមកិច្ចសម្ភាសន៍ ហើយទិន្នន័យទាំងនោះអ្នកស្រាវជ្រាវធ្វើការវិភាគដោយប្រុងប្រយ័ត្នដោយកំណត់យកគោលគំនិតរួមសំខាន់ៗ (Themes) តាមរយៈការវិភាគដោយផ្អែកលើស្ថានភាពនៃការជានាគុណភាពអប់រំ។

### ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានប្រកាន់ខ្ជាប់នូវក្រមសីលធម៌នៃការស្រាវជ្រាវ ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវស្របតាមគោលការណ៍ រួមមាន៖ ភាពស្មោះត្រង់ គណនេយ្យភាព សុវជីវធម៌វិជ្ជាជីវៈ សុចន្ទៈដោយឈរលើមូលដ្ឋានបើកចំហ ពង្រឹងសមត្ថភាពជាប្រចាំ និងមានវិជ្ជាជីវៈខ្ពស់។ ចំពោះស្ថាប័នស្រាវជ្រាវសំដៅដល់នីតិបុគ្គលមានតួនាទី និង/ឬចូលរួមចំណែកដល់ការបង្កើតឱ្យមានចំណេះដឹងថ្មីៗដល់សហគមន៍ស្រាវជ្រាវ និងការជ្រោមជ្រែងឱ្យមានភាពស្របច្បាប់សម្រាប់អ្នកស្រាវជ្រាវដែលបានបង្កើតឡើងក្នុងកម្រិតស្ថាប័ន (MISTI, ២០២២)។

អ្នកសិក្សាស្រាវជ្រាវបានយកលិខិតលេខ ២៣៤១ អយក.វជអ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំគោលការណ៍ថ្នាក់ដឹកនាំតាមឋានានុក្រមមន្ទីរអប់រំ តាមលិខិតលេខ ៥៩៦ អយក៦.ផក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ព្រមទាំងបានស្នើសុំការអនុញ្ញាតពីថ្នាក់ដឹកនាំគ្រប់គ្រងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប បង្ហាញពីគោលបំណងជាក់លាក់ក្នុងការចុះប្រមូលទិន្នន័យដល់អ្នកពាក់ព័ន្ធក្នុងការបំពេញកម្រងសំណួរ តាមលិខិតលេខ១៩៧ សគវ.សរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០២២ របស់សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ដើម្បីមានភាពជឿជាក់ប្រកបដោយស្មារតីទទួល

ខុសត្រូវ សាមគ្គីភាព និងសហការដល់ការចុះប្រមូលទិន្នន័យនេះបានលទ្ធល្អដោយរលូននិងសម្រេចបានជោគជ័យ។ ចំពោះទិន្នន័យដែលទទួលបានពីអ្នកឆ្លើយតបត្រូវបានរក្សាសម្ងាត់ និងយកមកប្រើសម្រាប់តែការស្រាវជ្រាវតែប៉ុណ្ណោះ។

**ក្រមសីលធម៌ស្រាវជ្រាវ**

ក្រមសីលធម៌ស្រាវជ្រាវមានគោលការណ៍សំខាន់ៗ ៥ យ៉ាង (ក្រសួងអយក, ២០២០)៖

(១) **មិនបង្ខិតបង្ខំ៖** អ្នកស្រាវជ្រាវគោរពសិទ្ធិភាពផ្ទាល់ខ្លួន តម្លៃសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួម។

(២) **ការទទួលបានការព្រមព្រៀង៖** អ្នកស្រាវជ្រាវប្រតិបត្តិខ្លួនជាបុគ្គលអាចជឿទុកចិត្ត មានតម្លាភាពនិងមានភាពស្មោះត្រង់។

(៣) **ការរក្សាការសម្ងាត់និងមិនបញ្ចេញឈ្មោះ៖** ការមិនបញ្ចេញឈ្មោះធ្វើឱ្យអ្នកចូលរួមឆ្លើយសំណួរ អ្នកផ្តល់ការសម្ភាសន៍ បានដោយសេរី ពីព្រោះអត្តសញ្ញាណអ្នកចូលរួមត្រូវបានរក្សាការសម្ងាត់។

(៤) **ការជៀសវាងការបោកបញ្ឆោត៖** អ្នកស្រាវជ្រាវមិនត្រូវផ្តល់ព័ត៌មានមិនពិតដោយចេតនាដល់អ្នកចូលរួមលើទិដ្ឋភាពណាមួយនៃការស្រាវជ្រាវឡើយ។

(៥) **សិទ្ធិក្នុងការដកខ្លួន៖** អ្នកចូលរួមមានសិទ្ធិដកខ្លួននៅគ្រប់ដំណាក់កាលណាមួយចេញពីការស្រាវជ្រាវ និងមិនត្រូវមានផលអវិជ្ជមានដល់អ្នកចូលរួមឡើយ។

# ជំពូក ៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូក ៤ ៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សា បានរកឃើញតាមរយៈការបំពេញកម្រងសំណួរពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស លើប្រធានបទ **"ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប"**។ ការវិភាគនិងសំយោគនេះស្របតាមគោលបំណងនៃការសិក្សាស្រាវជ្រាវចំនួន ២ គឺ (១) **ឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប** (២) **បង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**។

## ៤.១ ឧបករណ៍វិភាគទិន្នន័យ

អ្នកសិក្សាស្រាវជ្រាវវិភាគទិន្នន័យដោយប្រើកម្មវិធី Microsoft Excel ជាឧបករណ៍បច្ចេកវិទ្យាលក្ខណៈវិទ្យាសាស្ត្រមួយដែលអាចធានាបានក្នុងការបញ្ចូលទិន្នន័យនិងវិភាគទន្នន័យស្រាវជ្រាវនេះ។

## ៤.២ ការវិភាគទិន្នន័យរបស់អ្នកឆ្លើយសំណួរលើកម្រងសំណួរ

### ៤.២.១ ផ្នែកទី១ ព័ត៌មានទូទៅ

#### ៤.២.១.១ ទិន្នន័យតាមភេទ គណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស

ក្រាហ្វទី 1៖ ទិន្នន័យតាមភេទរបស់គណៈគ្រប់គ្រងបានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង (n=3)*

ក្រាហ្វទី១ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងប្រុសចំនួន២នាក់ ស្រីចំនួន១នាក់ (២/១) សរុបចំនួន៣នាក់។ គណៈគ្រប់គ្រងជាប្រុសមាន៦៦,៦៧ភាគរយ ស្រីមាន៣៣,៣៣ភាគរយ។ ប្រការនេះបង្ហាញថាការលើកកម្ពស់យេនឌ័រក្នុងការចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ។

ក្រាហ្វទី 2៖ ទិន្នន័យតាមភេទរបស់គ្រូឧទ្ទេសបានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គ្រូឧទ្ទេស (n=44)*

ក្រាហ្វទី២ខាងលើបានបង្ហាញថា គ្រូឧទ្ទេសប្រុសចំនួន៣២នាក់ ស្រីចំនួន១២នាក់ (៣២/១២) សរុបចំនួន៤៤នាក់។ គ្រូឧទ្ទេសប្រុសមាន៧២,៧៣ភាគរយ ស្រីមាន២៧.២៧ភាគរយ។

ក្រាហ្វទី 3៖ ទិន្នន័យតាមភេទរបស់គរុសិស្សបានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គរុសិស្ស (n=129)*

ក្រាហ្វទី៣ខាងលើបានបង្ហាញថា គរុសិស្សប្រុសចំនួន៣១នាក់ ស្រីចំនួន៩៨នាក់ (៣១/៩៨) សរុបចំនួន១២៩នាក់។ គរុសិស្សប្រុសមាន២៤,០៣ភាគរយ ស្រីមាន៧៥.៩៧ភាគរយ។ ប្រការនេះបង្ហាញថាការលើកកម្ពស់គរុសិស្សស្រីទទួលបានការបណ្តុះបណ្តាលខ្ពស់ក្នុងវិស័យអប់រំ។

តាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ (SDG-4) (អយក, ២០១៩; ODC, 2019)៖ (១) ការអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប (២) ការអប់រំគាំទ្រសមិទ្ធផលសមភាពយេនឌ័រ តាមរយៈការផ្តល់សិទ្ធិអំណាចដល់ស្ត្រីការបង្កើតភាពធន់នៃបរិស្ថាននៅក្នុងសង្គមមួយ។ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចែងក្នុងមាត្រា១១ ត្រង់ចំណុចទី៦ ថា បេក្ខជនទាំងពីរភេទជាជនជាតិ

ភាគតិច បេក្ខជននៅតំបន់ដាច់ស្រយាល និងបេក្ខជននារីភេទអាចត្រូវបានផ្តល់អាទិភាពនិងភាពងាយស្រួលឱ្យចូលធ្វើការក្នុងក្របខណ្ឌរាជការ (ព្រះរាជក្រមលេខ០៦ ន.ស.៩៤, ១៩៩៤)។

### ៤.២.១.២ ទិន្នន័យតាមអាយុ គណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស

ក្រាហ្វទី 4៖ ទិន្នន័យតាមអាយុរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេសបានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44)*

ក្រាហ្វទី៤ផ្អែកតាមក្រុមអាយុ គណៈគ្រប់គ្រងមានអាយុលើសពី៥០ឆ្នាំមាន៦៦,៦៧ភាគរយ មានអាយុចន្លោះពី៤១ដល់៥០ឆ្នាំមាន៣៣,៣៣ភាគរយ មានអាយុចន្លោះពី៣១ដល់៤០ឆ្នាំមាន០ភាគរយ មានអាយុចន្លោះពី២០ដល់៣០ឆ្នាំមាន០ភាគរយ ក្នុងចំណោម៣នាក់បានបំពេញកម្រងសំណួរ។ ចំណែកគ្រូឧទ្ទេសមានអាយុលើសពី៥០ឆ្នាំមាន៤,៥៥ភាគរយ មានអាយុចន្លោះពី៤១ដល់៥០ឆ្នាំមាន៣៤,០៩ភាគរយ មានអាយុចន្លោះពី៣១ដល់៤០ឆ្នាំមាន៥០,០០ភាគរយ មានអាយុចន្លោះពី២០ដល់៣០ឆ្នាំមាន១១,៣៦ភាគរយ ក្នុងចំណោម៤៤នាក់បានបំពេញកម្រងសំណួរ។

ក្រាហ្វទី 5៖ ទិន្នន័យតាមអាយុរបស់គរុសិស្សបានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គរុសិស្ស (n=129)*

ក្រាហ្វទី៥ផ្អែកតាមក្រុមអាយុ គរុសិស្សមានអាយុលើសពី២៥ឆ្នាំប្រុសមាន៤,៦៥ភាគរយ ស្រីចំនួន ២,៣៣ភាគរយ គរុសិស្សមានអាយុចន្លោះពី២៣ដល់២៥ឆ្នាំប្រុសមាន៨,៥៣ភាគរយ ស្រីមាន២៦,៣៦ ភាគរយ គរុសិស្សមានអាយុចន្លោះពី១៨ដល់២២ឆ្នាំប្រុសមាន១០,៨៥ភាគរយ ស្រីមាន៤៥,៧៤ភាគរយ គរុសិស្សមានអាយុក្រោម១៨ឆ្នាំ ប្រុសមាន០ភាគរយ ស្រីមាន១,៥៥ ភាគរយ ក្នុងចំណោម១២៩នាក់បាន បំពេញកម្រងសំណួរ។ ប្រការនេះបង្ហាញថា គរុសិស្សស្រីច្រើនជាងគរុសិស្សប្រុសមានចន្លោះអាយុពី១៨ ដល់២៥ឆ្នាំ។

### ៤.២.១.៣ ទិន្នន័យតាមកម្រិតវប្បធម៌ គណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស

ក្រាហ្វទី 6៖ ការប្រៀបធៀបកម្រិតវប្បធម៌របស់គណៈគ្រប់គ្រង និងគ្រូឧទ្ទេស (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44)*

ក្រាហ្វទី៦ខាងលើបានបង្ហាញថា កម្រិតវប្បធម៌គណៈគ្រប់គ្រងមាន0%ទាបជាងបរិញ្ញាបត្រមាន 0%មានបរិញ្ញាបត្រ មាន១០០ភាគរយមានបរិញ្ញាបត្រជាន់ខ្ពស់ មាន0%ខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់ ក្នុងចំណោម៣នាក់បានបំពេញកម្រងសំណួរស្រាវជ្រាវ។ កម្រិតវប្បធម៌គ្រូឧទ្ទេសមាន២,២៧ភាគរយទាប ជាងបរិញ្ញាបត្រ មាន៦១,៣៦ភាគរយមានបរិញ្ញាបត្រ មាន៣៤,០៩ភាគរយមានបរិញ្ញាបត្រជាន់ខ្ពស់ មាន ២,២៧ភាគរយខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់ ក្នុងចំណោម៤៤នាក់បានបំពេញកម្រងសំណួរស្រាវជ្រាវ។

ប្រការនេះបង្ហាញថាគណៈគ្រប់គ្រងមានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់។ ចំណែកកម្រិតវប្បធម៌របស់គ្រូឧទ្ទេសភាគច្រើនមានបរិញ្ញាបត្រ មានបរិញ្ញាបត្រជាន់ខ្ពស់ពាក់កណ្ដាលនៃគ្រូឧទ្ទេសមានបរិញ្ញាបត្រ។

ក្រាហ្វទី 7៖ កម្រិតវប្បធម៌របស់គរុសិស្ស (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គរុសិស្ស (n=129)*

ក្រាហ្វទី៧ខាងលើបានបង្ហាញទិន្នន័យថា កម្រិតវប្បធម៌គរុសិស្សក្រោមថ្នាក់ទី១២មាន០ភាគរយ ថ្នាក់ទី១២មាន៨,៥៣ភាគរយ មធ្យមសិក្សាទុតិយភូមិមាន៧៣,៦៤ភាគរយ បរិញ្ញាបត្រមាន១៧,០៥ភាគរយ ផ្សេងៗមាន០,៧៨ភាគរយ ។ ប្រការនេះបង្ហាញថា គរុសិស្សមានចំណេះដឹងទូទៅសមស្របនៅកម្រិតមធ្យមសិក្សាចំណេះទូទៅតាមរយៈកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់គុណភាពអប់រំ។ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** (២០១៣-២០១៤) បានកំណត់ជាពាក្យស្លោកថា "**អ្នកចេះ គឺជាប់**"។

គរុសិស្សនៅលីវមាន៨១,៤០ភាគរយ គរុសិស្សរៀបការមាន១៨,៦០ភាគរយ គរុសិស្សរស់នៅជាមួយឪពុកម្ដាយមាន៧៧,៥២ភាគរយ គរុសិស្សនៅជាមួយបងប្អូនមាន៣,១០ភាគរយ គរុសិស្សនៅម្នាក់ឯងមាន៦,២០ភាគរយ គរុសិស្សនៅមួយគ្រួសារខ្លួនឯងមាន១៣,១៨ភាគរយ គរុសិស្សមានដែលគ្រួសារលើកទឹកចិត្តដើម្បីក្លាយជាគ្រូបង្រៀនមាន៣,១០ភាគរយ គរុសិស្សមានបំណងផ្ទាល់ខ្លួនដើម្បីក្លាយជាគ្រូបង្រៀនមាន៩១,៤៧ភាគរយ គរុសិស្សធ្លាប់ជាគ្រូបង្រៀនជាប់កិច្ចសន្យាមាន៣៤,១១ភាគរយ គរុសិស្សមិនធ្លាប់បង្រៀនមាន៥៨,៩១ភាគរយ ហើយគរុសិស្សធ្លាប់បង្រៀននៅសាលារៀនឯកជនមាន

៦,៩៨ភាគរយ ។ ប្រការនេះអាចសន្និដ្ឋានបានថា គរុសិស្សទាំងពីរភេទមានចំណាប់អារម្មណ៍ចង់ក្លាយជាអ្នកអប់រំដើម្បីចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សជូនសង្គមជាតិ ឱ្យឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ផ្តោតយកចិត្តទុកដាក់ដោយតម្កល់ "**មនុស្ស**" ជាអាទិភាពទី១នៃវិស័យអាទិភាព៤ ដែលចតុកោណទី១ គឺ**ការអភិវឌ្ឍធនធានមនុស្ស**។

### ៤.២.១.៤ បទពិសោធន៍ គណៈគ្រប់គ្រង គ្រូឧទ្ទេស

ក្រាហ្វទី ៨៖ ការប្រៀបធៀបបទពិសោធន៍ការងាររបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44)*

ក្រាហ្វទី៨ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងមានបទពិសោធន៍ការងារចន្លោះពី១ដល់៥ឆ្នាំមាន០ភាគរយ ចន្លោះពី៦ដល់១០ឆ្នាំមាន០ភាគរយ ចន្លោះពី១១ដល់១៥ឆ្នាំមាន០ភាគរយ ចន្លោះពី១៦ដល់២០ឆ្នាំមាន៥០,០០ភាគរយ លើស២០ឆ្នាំមាន៥០,០០ភាគរយ។ រីឯបទពិសោធន៍របស់គណៈគ្រប់គ្រងក្នុងការគ្រប់គ្រងដឹកនាំ ចន្លោះពី៦ដល់១០ឆ្នាំមាន៦៦,៦៧ភាគរយ លើស២០ឆ្នាំមាន៣៣,៣៣ភាគរយ ក្នុងចំណោម៣នាក់បានបំពេញកម្រងសំណួរស្រាវជ្រាវ។ ចំណែកគ្រូឧទ្ទេសមានបទពិសោធន៍ការងារ ចន្លោះពី១ដល់៥ឆ្នាំមាន២,៣ភាគរយ ចន្លោះពី៦ដល់១០ឆ្នាំមាន៣៦,៣៦ភាគរយ ចន្លោះពី១១ដល់១៥ឆ្នាំមាន១៨,១៨ភាគរយ ចន្លោះពី១៦ដល់២០ឆ្នាំមាន១៥,៩១ភាគរយ លើស២០ឆ្នាំមាន២៧,២៧ភាគរយ ក្នុងចំណោម៤៤នាក់បានបំពេញកម្រងសំណួរស្រាវជ្រាវ។ ប្រការនេះអាចសន្និដ្ឋានបានថា

គណៈគ្រប់គ្រង គ្រូឧទ្ទេសភាគច្រើនមានបទពិសោធន៍ច្រើន ការយល់ដឹងពីការងារ ការគ្រប់គ្រងដឹកនាំ និងការបង្រៀននិងរៀន ជាពិសេសរក្សាបាននូវសុខុមនីយកម្មការងាររបស់បុគ្គលិកអប់រំ និងការសិក្សារបស់គរុសិស្ស។

## ៤.២.២ ផ្នែកទី២ ស្ថានភាពនៃការធានាគុណភាពអប់រំ

### ៤.២.២.១ ទិន្នន័យតាមបែបបរិមាណវិស័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានលើកយកសូចនាករស្រេបតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំទាំង៩ (ACC, 2016, 2019) ឆ្លើយតបនឹងគោលបំណងនៃការស្រាវជ្រាវដើម្បីឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ និងបង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ។

ក្រាហ្វទី 9៖ ការអនុវត្តស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី៩ខាងលើបានកត់សម្គាល់ថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា១ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០០ គម្លាតស្តង់ដា=០,៦៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងគោលបំណង បានទូលំទូលាយដល់ភាគីពាក់ព័ន្ធតាមរយៈការបោះពុម្ព និងគេហទំព័ររបស់សាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣៣ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាពិនិត្យកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង ក្នុងអំឡុងពេលមួយទៀងទាត់ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍសាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៧ គម្លាតស្តង់ដា=០,៥៨)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា១ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣.៨០ គម្លាតស្តង់ដា=០.៧៥)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ចក្ខុវិស័យ បេសកកម្ម និងគោលបំណងមានការឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដោយរួមបញ្ចូលទាំងកិច្ចការពារ និងថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩០ គម្លាតស្តង់ដា=០,៧៧)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាពិនិត្យកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង ក្នុងអំឡុងពេលមួយទៀងទាត់ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍសាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦១ គម្លាតស្តង់ដា=០,៦៩)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា១ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៤ គម្លាតស្តង់ដា=០,៦៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាពិនិត្យកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង ក្នុងអំឡុងពេលមួយទៀងទាត់ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍសាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១២ គម្លាតស្តង់ដា=០,៨២)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ចក្ខុវិស័យ បេសកកម្ម និងគោលបំណងមានការឆ្លើយតបទៅនឹងតម្រូវ

ការថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដោយរួមបញ្ចូលទាំងកិច្ចការពារ និងថែរក្សាវប្បធម៌ និង អត្តសញ្ញាណជាតិ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩៨ គម្លាតស្តង់ដា=០,៨៧)។

ក្រាហ្វទី 10៖ ការអនុវត្តស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១០ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា២ អភិបាលកិច្ច និងការគ្រប់គ្រង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤.២២ គម្លាតស្តង់ដា=០,៩២)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៦៧ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ផែនការការអភិវឌ្ឍន៍របស់សាលាមានសង្គតិភាព

ជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០០ គម្លាតស្តង់ដា=១,០០)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា២ អភិបាលកិច្ច និងការគ្រប់គ្រង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩៧ គម្លាតស្តង់ដា=១,៥៤)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាកំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមអភិបាលច្បាស់លាស់ដោយអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១៤ គម្លាតស្តង់ដា=១,០០)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ក្រុមប្រឹក្សាភិបាលវាយតម្លៃប្រសិទ្ធភាពនៃការងាររបស់ខ្លួនដោយទៀងទាត់" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៦ គម្លាតស្តង់ដា=០,៨៥)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា២ អភិបាលកិច្ច និងការគ្រប់គ្រង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១៥ គម្លាតស្តង់ដា=០,៥០)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៥៣ គម្លាតស្តង់ដា=០,៧១)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតមានពីរគឺ (១)"ផែនការការអភិវឌ្ឍន៍របស់សាលាមានសង្គតិភាពជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩១ គម្លាតស្តង់ដា=០,៩៣)។

**ទស្សនវិស័យ**

យើងមានជំនឿទៅលើសេវាបណ្តុះបណ្តាលកាន់តែល្អប្រសើរព្រមទាំងមានកម្រិតខ្ពស់បំផុត។ យើងខិតខំប្រឹងប្រែងដើម្បីឧត្តមភាព និងសម្រាប់វិបុលភាព។

**ចក្ខុវិស័យ**

សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការប្តេជ្ញាចិត្តខ្ពស់ ដើម្បីក្លាយជាសាលាបណ្តុះបណ្តាលឈានមុខគេនៅក្នុងតំបន់លើផ្នែកគុណភាព សេចក្តីថ្លៃថ្នូរ និងប្រកបដោយវិជ្ជាជីវៈដើម្បីចូលរួមចំណែកយ៉ាងសកម្ម និងមានប្រសិទ្ធិភាពក្នុងការអភិវឌ្ឍន៍សង្គម។

*(ប្រភព៖ PTTC-SR, 2022)*

ក្រាហ្វទី 11៖ ការអនុវត្តស្តង់ដារ៣៖ បុគ្គលិកអប់រំ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១១ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដា៣ បុគ្គលិកអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩៧ គម្លាតស្តង់ដា=១,១៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានការរក្សាទុកឯកសាររបស់គ្រូឧទ្ទេសពេញម៉ោង វេលាការ និងបុគ្គលិកត្រឹមត្រូវ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៦៧ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានបញ្ចប់ថវិកាសមរម្យសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូឧទ្ទេស និងបុគ្គលិក" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៧ គម្លាតស្តង់ដា=២,៣១)។

គ្រូឧទ្ទេសបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដា៣ បុគ្គលិកអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៦ គម្លាតស្តង់ដា=០,៦៥)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានការរក្សាទុកឯកសាររបស់គ្រូឧទ្ទេសពេញម៉ោង វេលាការ និងបុគ្គលិកត្រឹមត្រូវ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២៧ គម្លាតស្តង់ដា=០,៩២)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានបញ្ចប់ថវិកាសមរម្យសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូឧទ្ទេស និងបុគ្គលិក" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=២,៩១ គម្លាតស្តង់ដា=១,០៧)។

គរុសិស្សបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដា៣ បុគ្គលិកអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣០ គម្លាតស្តង់ដា=០,៤១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "គ្រូឧទ្ទេសបង្រៀនពេញម៉ោងមានចំនួនគ្រប់គ្រាន់ ដើម្បីធានាប្រសិទ្ធភាពនៃការបង្រៀន និងណែនាំគរុសិស្ស" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៥៧ គម្លាតស្តង់ដា=០,៦១)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាផ្ដល់ប្រាក់បៀវត្ស និងផលប្រយោជន៍នានាសម្រាប់ទាក់ទាញ និងរក្សាគ្រូឧទ្ទេសដែលមានសមត្ថភាពខ្ពស់ឱ្យនៅបម្រើការក្នុងសាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៥ គម្លាត ស្តង់ដា=១,២១)។

ក្រាហ្វទី 12៖ ការអនុវត្តស្តង់ដា៤៖ កម្មវិធីអប់រំ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១២ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៤ កម្មវិធីអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៩៥ គម្លាតស្តង់ដា=១,០៨)។ សូចនាករ ដែលទទួលបាន

ពិន្ទុខ្ពស់បំផុតមានបីគឺ (១)"កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣៣ គម្លាតស្តង់ដា=១,១៥) (២)"គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុសិស្សដោយបញ្ជាក់ពីចំណេះដឹង ជំនាញ និង/ឬ អាកប្បកិរិយា ដែលគរុសិស្សនឹងទទួលបាន" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣៣ គម្លាតស្តង់ដា=១,១៥) និង(៣)"សាលាប្រើវិធីសាស្ត្រនិងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុសិស្សដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣៣ គម្លាតស្តង់ដា=១,១៥)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=២,៦៧ គម្លាតស្តង់ដា=០,៥៨)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៤ កម្មវិធីអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨១ គម្លាតស្តង់ដា=០,៧៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០០ គម្លាតស្តង់ដា=០,៨៦)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាពិនិត្យនិងកែលម្អកម្មវិធីសិក្សាអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣.៥៩ គម្លាតស្តង់ដា=១,១១)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៤ កម្មវិធីអប់រំ** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៥០ គម្លាតស្តង់ដា=០,៤០)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានយន្តការកំណត់ចំនួនក្រេឌីតសិក្សា និងគោលការណ៍នៃការផ្ទេរក្រេឌីតសមស្របតាមបទបញ្ញត្តិជាធរមាន" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៧២ គម្លាតស្តង់ដា=០,៧២)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាពិនិត្យ និងកែលម្អកម្មវិធីសិក្សាអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២៥ គម្លាតស្តង់ដា=០,៧៨)។

ក្រាហ្វទី 13៖ ការអនុវត្តស្តង់ដា៥៖ សេវាគរុសិស្ស/និស្សិត (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១៣ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៥ សេវាគរុសិស្ស/និស្សិត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៥ គម្លាតស្តង់ដា=១,២១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "គោលនយោបាយ ឬគោលការណ៍ ស្តីពីការជ្រើសរើសគរុសិស្សចូលរៀនបានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៦៧ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានគោលនយោបាយ ឬគោលការណ៍ ស្តីពីអាហារូបករណ៍ដោយមានចែងលក្ខខណ្ឌច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៧ គម្លាតស្តង់ដា=២,៣១)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៥ សេវាគរុសិស្ស/និស្សិត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៨ គម្លាតស្តង់ដា=០,៧២)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានគោលនយោបាយ ឬគោលការណ៍ ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សាគរុសិស្ស និងអត្រាបញ្ចប់ការសិក្សា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១៦ គម្លាតស្តង់ដា=០,៧៥)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាជួយគរុសិស្សក្នុងការធ្វើផែនការអភិវឌ្ឍអាជីព និងជួយរកការងារឱ្យគរុសិស្ស ព្រមទាំងតាមដានលទ្ធផលការងាររបស់គរុសិស្ស" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,២៥ គម្លាតស្តង់ដា=១,១៤)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៥ សេវាគរុសិស្ស/និស្សិត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២៦ គម្លាតស្តង់ដា=០,៤២)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "គរុសិស្សទទួលបានឱកាសក្នុងការចូលរួមសកម្មភាពបន្ថែមលើការសិក្សា និងកម្មវិធីហ្វឹកហាត់ការងារ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៥៧ គម្លាតស្តង់ដា=០,៦៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាជួយគរុសិស្សក្នុងការធ្វើផែនការអភិវឌ្ឍអាជីព និងជួយរកការងារឱ្យគរុសិស្ស ព្រមទាំងតាមដានលទ្ធផលការងាររបស់គរុសិស្ស" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៣ គម្លាតស្តង់ដា=១,១៩)។

ក្រាហ្វទី 14៖ ការអនុវត្តស្តង់ដា៦៖ ធនធានសិក្សា (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១៤ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៦ ធនធានសិក្សា** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១២ គម្លាតស្តង់ដា=១,១១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សានិងស្រាវជ្រាវ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៦៧ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានបន្ទប់ពិសោធន៍ទូទៅ និងឯកទេស ប្រដាប់ដោយបរិក្ខារពេញលេញសម្រាប់គាំទ្រដល់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៣៣ គម្លាតស្តង់ដា=១,៥៣)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៦ ធនធានសិក្សា** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧២ គម្លាតស្តង់ដា=០,៧៥)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ចំនួនម៉ោងបើកបម្រើសេវារបស់បណ្ណាល័យស្របទៅនឹងតម្រូវការរបស់គរុសិស្ស និងគ្រូឧទ្ទេស" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៧ គម្លាតស្តង់ដា=០,៩៧)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "បណ្ណាល័យមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រផែនការរយៈពេលវែង និងរយៈពេលខ្លី ដើម្បីអភិវឌ្ឍន៍បណ្ណាល័យឱ្យកាន់តែប្រសើរឡើង" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,២០ គម្លាតស្តង់ដា=០,៩៨)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៦ ធនធានសិក្សា** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣២ គម្លាតស្តង់ដា=០,៤៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សានិងស្រាវជ្រាវ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៧១ គម្លាតស្តង់ដា=០,៦៥)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "បណ្ណាល័យ មានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រផែនការរយៈពេលវែង និងរយៈពេលខ្លី ដើម្បីអភិវឌ្ឍន៍បណ្ណាល័យឱ្យកាន់តែប្រសើរឡើង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៦ គម្លាតស្តង់ដា=០,៨៦)។

ក្រាហ្វទី 15៖ ការអនុវត្តស្តង់ដា៧៖ ធនធានរូបវន្ត (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១៥ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៧ ធនធានរូបវន្ត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៩ គម្លាតស្តង់ដា=១,០៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣៣ គម្លាតស្តង់ដា=០,៥៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានគោលនយោបាយ ឬគោលការណ៍សុវត្ថិភាព ស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធព័ត៌មានអេឡិចត្រូនិកផ្លូវការ

រួមទាំងឃ្លាំងការពារអគ្គិភ័យនិងការថតចម្លងទុក" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ= ៣,៣៣ គម្លាតស្តង់ដា=១,១៥)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៧ ធនធានរូបវន្ត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៥៣ គម្លាតស្តង់ដា=០,៧៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២៣ គម្លាតស្តង់ដា=០,០៣)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានការសាកល្បងជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រាមានអាសន្ន" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ= ២,៩៨ គម្លាតស្តង់ដា=១,៣៩)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៧ ធនធានរូបវន្ត** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៩ គម្លាតស្តង់ដា=០,៥៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៧១ គម្លាតស្តង់ដា =០,៥៤)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាមានការសាកល្បងជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រាមានអាសន្ន" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,២៣ គម្លាតស្តង់ដា =០,១៦)។

**បេសកកម្ម**

- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ គ្រូបង្រៀនប្រកបដោយគុណភាពតាមរយៈការបំពេញបំណិន និងបទពិសោធន៍សម្បូរបែបដែលផ្តោតលើបំណិនជីវិត គុណតម្លៃ និងសីលធម៌ ការយល់ដឹងលើវប្បធម៌ទៅវិញទៅមក ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍធនធានមនុស្សជាចម្បង
- ពង្រឹងការគ្រប់គ្រងតាមបែបចូលរួមដើម្បីធ្វើឱ្យប្រសើរឡើងនូវការបណ្តុះបណ្តាល និងតម្រូវ ការអភិវឌ្ឍន៍ក្នុងការឈានឆ្ពោះទៅជាសាលាឈានមុខគេមួយលើការបណ្តុះបណ្តាល
- លើកទឹកចិត្ត និងជំរុញឥរិយាបថទទួលខុសត្រូវ និងភាពជាអ្នកដឹកនាំចំពោះបុគ្គលរដ្ឋបាល ។

*(ប្រភព៖ PTTC-SR, 2022)*

ក្រាហ្វទី 16៖ ការអនុវត្តស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១៦ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី***ស្តង់ដា៨ ធនធានហិរញ្ញវត្ថុ*** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៤៤ គម្លាតស្តង់ដា=០,៨២)។ សូចនាករដែល

ទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាធ្វើសវនកម្មជាប្រចាំដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬគណៈកម្មការមានឋានៈស្មើ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៥,០០ គម្លាតស្តង់ដា=០,០០)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលាបង្ហាញអំពីស្ថិរភាពហិរញ្ញវត្ថុដោយផ្តល់ភស្តុតាងលើភាពគ្រប់គ្រាន់នៃថវិកា ដើម្បីបំពេញតម្រូវការចំណាយលើបុគ្គលិក ប្រព័ន្ធប្រតិបត្តិការ និងដើមទុនក្នុងការគាំទ្រដល់កម្មវិធីអប់រំរបស់សាលា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៧ គម្លាតស្តង់ដា=១,៥៣)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៨ ធនធានហិរញ្ញវត្ថុ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៦ គម្លាតស្តង់ដា=០,៧៥)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាបានបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅក្រសួងអប់រំ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមកាលបរិច្ឆេទកំណត់" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១១ គម្លាតស្តង់ដា=០,៦៩)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "តំណាងមកផ្នែកពាក់ព័ន្ធផ្សេងៗរបស់សាលាមានឱកាសចូលរៀបចំផែនការថវិកា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៥ គម្លាតស្តង់ដា=០,៨៧)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៨ ធនធានហិរញ្ញវត្ថុ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០២ គម្លាតស្តង់ដា=០,៦៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលាមានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប ដែលត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំទទួលបន្ទុកជាប្រចាំ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៤០ គម្លាតស្តង់ដា =០,៩២)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "តំណាងមកផ្នែកពាក់ព័ន្ធផ្សេងៗរបស់សាលាមានឱកាសចូលរៀបចំផែនការថវិកា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧១ គម្លាតស្តង់ដា =០,៩៦)។

ក្រាហ្វទី 17៖ ការអនុវត្តស្តង់ដា៩៖ ការធានាគុណភាពអប់រំផ្ទៃក្នុង




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី១៧ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៩ ការធានាគុណភាពអប់រំផ្ទៃក្នុង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣.៧៨ គម្លាតស្តង់ដា=១,៥៥)។

សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតមានពីរគឺ (១)"សាលាផ្តល់ធនធានគ្រប់គ្រាន់សម្រាប់បង្កើត និងគាំទ្រប្រព័ន្ធធានាគុណភាពអប់រំប្រកបដោយប្រសិទ្ធភាព" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០០ គម្លាតស្តង់ដា=១,៧៣) និង(២)"សាលារៀបចំចងក្រងសៀវភៅស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០០ គម្លាតស្តង់ដា=១,៧៣) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ដំណើរការគុណភាពអប់រំមានការចូលរួម និងសហការពីគណៈគ្រប់គ្រង គ្រប់ជាន់ថ្នាក់រួមទាំងបុគ្គលិក គរុសិស្ស និងភាគីពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៦៧ គម្លាតស្តង់ដា =១,៥៣)។

គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៩ ការធានាគុណភាពអប់រំផ្ទៃក្នុង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៥៩ គម្លាតស្តង់ដា=០,៨៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ដំណើរការគុណភាពអប់រំមានការចូលរួម និងសហការពីគណៈគ្រប់គ្រង គ្រប់ជាន់ថ្នាក់រួមទាំងបុគ្គលិក គរុសិស្ស និងភាគីពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧០ គម្លាតស្តង់ដា=០,៩៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលារៀបចំចងក្រងសៀវភៅស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុង" ក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៤៨ គម្លាតស្តង់ដា=១,០២)។

គរុសិស្សបានផ្តល់ទិន្នន័យសរុបពី**ស្តង់ដា៩ ការធានាគុណភាពអប់រំផ្ទៃក្នុង** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣២ គម្លាតស្តង់ដា=០,៤៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ដំណើរការគុណភាពអប់រំមានការចូលរួម និងសហការពីគណៈគ្រប់គ្រង គ្រប់ជាន់ថ្នាក់រួមទាំងបុគ្គលិក គរុសិស្ស និងភាគីពាក់ព័ន្ធ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៤៧ គម្លាតស្តង់ដា=០,៦១)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "សាលារៀបចំចងក្រងសៀវភៅស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១៣ គម្លាតស្តង់ដា =០,៨៦)។

### ៤.២.២.២ ទិន្នន័យតាមបែបគុណវិស័យ

វិស័យអប់រំ ជាកត្តាគន្លឹះមួយក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) បានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀន

ដើម្បីធានាឱ្យគ្រូបង្រៀនមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណធម៌ និងកាយសម្បទា ប្រកបដោយសីលធម៌ ជំនាញ និងសមត្ថភាពអនុវត្តវិជ្ជាជីវៈតាមរយៈការបណ្តុះបណ្តាលមុនពេលចេញទៅបំពេញការងារនិងកំពុងពេលបំពេញការងារ។ គុណភាពអប់រំ គឺជាគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន (ក្រសួងអយក, ២០១៧)។

អ្នកសិក្សាស្រាវជ្រាវទទួលទិន្នន័យបានពីការសម្ភាសន៍ជាមួយនឹងថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងអ្នកជំនាញឯកទេសផ្នែកអប់រំ ភាគច្រើនបានលើកឡើងថា៖

"...ការងារអប់រំគឺសំខាន់ណាស់វិនិយោគលើការអភិវឌ្ឍធនធានមនុស្សឱ្យទទួលផលនៃវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណសម្បទា និងកាយសម្បទា តាមស្តង់ដាប្រកបដោយគុណភាព តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀនដោយគ្រូបង្រៀនចេះប្រើប្រាស់បំណិនផ្នែកបច្ចេកវិទ្យា និងអនុវត្តការអប់រំសុខភាព..."

*(EXPERT#1,2,3,5,6)*

"...ការរៀបចំកំណែទម្រង់គ្រឹះស្ថានសិក្សា ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង មានទស្សនៈវិស័យទូលាយ គោលបំណង បេសកកម្ម សកម្មភាព ឱ្យទាន់កាលៈទេសៈ និងនវានុវត្តបែបសតវត្សទី២១ ជំរុញការសិក្សាថ្នាក់តំបន់ឱ្យរីកចម្រើនឱ្យឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រដ្ឋាភិបាលកម្ពុជា និងកំណែទម្រង់វិស័យអប់រំរបស់ដែលកំណត់ថាប្រទេសកម្ពុជាមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០..."

*(EXPERT#1,2,3,4,5,6)*

"...យុទ្ធសាស្ត្រដើម្បីធានាគុណភាពអប់រំទាមទារការការពង្រឹងវិធីសាស្ត្របង្រៀន លើកទឹកចិត្តដល់គ្រូឧទ្ទេស និងគរុសិស្ស បង្កើនសមត្ថភាពបន្ថែមបែបពហុជំនាញផ្នែកICT ភាសាអង់គ្លេស និងការស្រាវជ្រាវប្រតិបត្តិឱ្យឆ្លើយតបនឹងការអប់រំបែបសតវត្សទី២១ ផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្ត។ ការអនុត្តដោយផ្អែកលើលក្ខណៈ៤គឺ (១)គ្រប់គ្រង ដឹកនាំ ប្រកបដោយក្រមសីលធម៌ (២)ការបង្រៀននិងរៀន (៣)លទ្ធផលសិក្សារបស់សិស្ស និង(៤)សហគមន៍ចូលរួម..."

*(EXPERT#1,2,3,4,5,6)*

"...ការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពទាមទារការចុះអធិការកិច្ច ដើម្បីពង្រឹងពង្រឹងគុណភាពអប់រំបន្ថែម។ គ្រូបង្រៀនចេញថ្មីជាធនធានមនុស្សដំបូងដែលទទួលបានចំណេះដឹងថ្មី វិធីសាស្ត្របង្រៀនលក្ខណៈវិទ្យាសាស្ត្រ ជាក្បួនខ្នាតមួយដើម្បីអប់រំកុមារនៅតាមគ្រឹះស្ថានមូលដ្ឋាន..."

*(EXPERT#1,2,5)*

"...គ្រូឧទ្ទេសអនុវត្តតាមបំណែងចែកភារកិច្ចរបស់គណៈគ្រប់គ្រង មានបំណិនបង្រៀនតាមបែបចិត្តគរុកោសល្យ ទេពកោសល្យ យល់ដឹងពីកម្មវិធីអប់រំបែបសតវត្សទី២១ បង្កើតវប្បធម៌ចែករំលែកចំណេះដឹង វិធីសាស្ត្របង្រៀនថ្មីៗ បទពិសោធន៍ល្អៗ បណ្តុះឆន្ទៈស្មារតីដល់គរុសិស្សស្រឡាញ់វប្បធម៌ជាតិដែលជាព្រលឹងរបស់ជាតិជាគំរូល្អដល់គរុសិស្សយកទៅអនុវត្តអប់រំដល់កុមារ..."

*(EXPERT#1,2,3,4,5,6)*

"...ជាធម្មតាក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគឺមានឧត្តមានុវត្តទាំងការអភិវឌ្ឍ ការដឹកនាំគ្រប់គ្រង ទាំងការបង្រៀននិងរៀន ទោះបីយ៉ាងណាក៏មានចំណុចប្រឈមមួយចំនួនតូចផងដែរ ដោយហេតុថវិកាអង្គភាពពុំគ្រប់គ្រាន់តាមតម្រូវការរៀបចំបែបទំនើបកម្ម គុណវុឌ្ឍិគ្រូឧទ្ទេសពុំទាន់ស្មើគ្នានៃកម្រិតក្របខណ្ឌ គរុសិស្សមានចំណេះដឹងពុំស្មើគ្នា ស្ថានភាពការសិក្សាខុសគ្នា (តំបន់ទីប្រជុំជន តំបន់ជនបទ)។ គម្លាតរវាងគោលនយោបាយអប់រំនិងអ្នកអនុវត្តគោលនយោបាយអប់រំដែលធ្វើឱ្យគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្សមានការលំបាកប្រតិបត្តិឱ្យបានល្អប្រសើរ..."

*(EXPERT#1,3,4,5,6)*

"...បរិបទក្រសួងអប់រំមានវិធីសាស្ត្រថ្មី(លឿន)ទាមទារការស្រាវជ្រាវបន្ថែម ការបញ្ច្រាបតេស្តស្តង់ដាថ្នាក់ជាតិ ថ្នាក់តំបន់ (អាស៊ាន SEMEO) និងថ្នាក់អន្តរជាតិ (PISA)... "

*(EXPERT#1,2)*

"...ការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ១២+២ មានលក្ខណៈល្អប្រសើរសម្រាប់ពេលបច្ចុប្បន្នអាចឆ្លុះបញ្ចាំងពីសមត្ថភាពគរុសិស្សទៅបង្រៀននៅកម្រិតបឋមសិក្សា។ ទោះបីសាលាគរុកោសល្យ និងវិក្រឹតការពុំទាន់មានកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ១២+៤ នៅឡើយក៏ដោយ សាលាគរុកោសល្យអាចយកឱកាសបណ្តុះបណ្តាលជាប្រព័ន្ធក្រេឌីតឱ្យក្លាយជាមជ្ឈមណ្ឌលរៀបចំកម្មវិធីកាន់តែខ្ពស់ដោយបំប៉នគ្រូបង្រៀនផ្នែកគ្រូបច្ចេកទេស..."

*(EXPERT#1,2,4)*

## ៤.៣ លទ្ធផលនៃការស្រាវជ្រាវលើស្ថានភាពនៃការធានាគុណភាពអប់រំ

### ៤.៣.១ ទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស តាមរយៈកម្រងសំណួរ

អ្នកសិក្សាស្រាវជ្រាវបានប្រមូលទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស ដែលបានចូលរួមបំពេញកម្រងសំណួរ (**n=176**) ដូចខាងក្រោម៖

ក្រាហ្វទី 18៖ ទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេស គរុសិស្ស បានបំពេញកម្រងសំណួរ (គិតជា%)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ N=198, n=176, P-value (P<.06)*

ក្រាហ្វទី១៨បានបង្ហាញថាអ្នកឆ្លើយដែលបានចូលរួមបំពេញកម្រងសំណួរ សរុបចំនួន១៧៦នាក់ (n=176) ស្មើ១០០ភាគរយ ប្រុសចំនួន៦៥នាក់ស្មើ៣៦,៩៣ភាគរយ ស្រី១១១នាក់ស្មើ៦៣,០៧ភាគរយ។ ក្នុងនោះគណៈគ្រប់គ្រងចំនួន៣នាក់ស្មើ១០០ភាគរយ (ប្រុស២នាក់ស្មើ៦៦,៦៧ភាគរយ

ស្រី១នាក់ស្មើ៣៣,៣៣ភាគរយ។ គ្រូឧទ្ទេសចំនួន៤៤នាក់ស្មើ១០០ភាគរយ (ប្រុស៣២នាក់ស្មើ ៧២,៧៣ភាគរយ ស្រី១២នាក់ស្មើ២៧,២៧ភាគរយ)។ គរុសិស្សចំនួន១២៩នាក់ស្មើ១០០ភាគរយ (ប្រុស៣១នាក់ស្មើ២៤,០៣ភាគរយ ស្រី៩៨នាក់ស្មើ៧៥,៩៧ភាគរយ)។

### ៤.៣.២ ទិន្នន័យពីថ្នាក់ដឹកនាំគ្រប់គ្រងអប់រំតាមរយៈផ្តល់កិច្ចសម្ភាសន៍

អ្នកសិក្សាស្រាវជ្រាវបានប្រមូលទិន្នន័យបន្ថែមពីថ្នាក់ដឹកនាំអង្គភាពគ្រប់គ្រងអប់រំ ដែលបានចូលរួមផ្តល់កិច្ចសម្ភាសន៍ (**n=6**) ដូចខាងក្រោម៖

ក្រាហ្វទី 19៖ ទិន្នន័យពីថ្នាក់ដឹកនាំគ្រប់គ្រងអប់រំបានចូលរួមផ្តល់កិច្ចសម្ភាសន៍ (គិតជា%)




*ចំនួនអ្នកចូលរួមផ្តល់កិច្ចសម្ភាសន៍៖ គណៈគ្រប់គ្រងអប់រំមន្ទីរអប់រំ (n=1), គណៈគ្រងអប់ការិល័យនៃមន្ទីរអប់រំ (n=5)*

ទិន្នន័យរបស់អ្នកផ្តល់កិច្ចសម្ភាសន៍ សរុបចំនួន៦នាក់ (n=6) ស្មើ១០០ភាគរយ ជាប្រុសចំនួន ៥នាក់ស្មើ៨៣,៣៣ភាគរយ ស្រី១នាក់ស្មើ១៦,៦៧ភាគរយ។ ក្នុងនោះគណៈគ្រប់គ្រងមន្ទីរអប់រំចំនួន ១នាក់ស្មើ១០០ភាគរយ (ប្រុស០នាក់ស្មើ០,០០ភាគរយ ស្រី១នាក់ស្មើ១០០ភាគរយ)។ គណៈគ្រប់គ្រងការិយាល័យនៃមន្ទីរអប់រំចំនួន៥នាក់ស្មើ១០០ភាគរយ (ប្រុស៥នាក់ស្មើ១០០ភាគរយ ស្រី០នាក់ស្មើ ០,០០ភាគរយ)។

### ៤.៣.៣ ការអនុវត្តស្តង់ដារទាំង៩នៃការធានាគុណភាពអប់រំ

គោលបំណងនៃការស្រាវជ្រាវ គឺដើម្បីឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ។ ការអនុវត្តស្តង់ដាជាតិនៃការធានាគុណភាពអប់រំទាំង៩ (ACC, 2016, 2019) ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការរៀបចំ

គោលនយោបាយ គោលការណ៍ និតីវិធី បទបញ្ជាផ្ទៃក្នុង ក្រុមគណៈកម្មការ ការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍ ផែនការថវិកា ការអភិវឌ្ឍនិងអនុវត្តកម្មវិធីអប់រំ ការគ្រប់គ្រងនិងលើកទឹកចិត្តបុគ្គលិកអប់រំ ការរៀបចំនិងផ្តល់សេវាគរុសិស្ស ធនធានសិក្សានិងធនធានរូបវន្តសម្រាប់ដំណើរការសេវាអប់រំ សំដៅលើការលើកកម្ពស់គុណភាពអប់រំ និងនិរន្តរភាពរបស់គ្រឹះស្ថានអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ឆ្ពោះទៅកាន់ឆ្នាំ២០៣០ គឺការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត និងផែនការសកម្មភាពការអភិវឌ្ឍសាលាគរុកោសល្យ (ហង់ជួន ណារ៉ុន, ២០២០)។

ក្រាហ្វទី 20៖ ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ (គិតជាមធ្យមភាគ)




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី២០ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដាទាំង៩ ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៥ គម្លាតស្តង់ដា =១,០៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ធនធានហិរញ្ញវត្ថុ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៤៤ គម្លាតស្តង់ដា=០,៨២) និង "អភិបាលកិច្ច និងការគ្រប់គ្រង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២២ គម្លាតស្តង់ដា=០,៩២)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ការធានាគុណភាពអប់រំផ្ទៃក្នុង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៨ គម្លាតស្តង់ដា =១,៥៥)។

គ្រូឧទ្ទេសបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដាទាំង៩ ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៩ គម្លាតស្តង់ដា=០,៨៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "អភិបាលកិច្ច និងការគ្រប់គ្រង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ =៣.៩៧ គម្លាតស្តង់ដា=១,៥៤) និង "កម្មវិធីអប់រំ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ =៣,៨១ គម្លាតស្តង់ដា=០,៧៦)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ធនធានរូបវន្ត" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៥៣ គម្លាតស្តង់ដា =០,៧៦)។

គរុសិស្សបានផ្ដល់ទិន្នន័យសរុបពី**ស្តង់ដាទាំង៩ ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២០ គម្លាតស្តង់ដា=០,៥០)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "កម្មវិធីអប់រំ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៥០ គម្លាតស្តង់ដា =០,៤០) និង "ធនធានសិក្សា" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,៣២ គម្លាតស្តង់ដា =០.៤៣)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ធនធានរូបវន្ត" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៩ គម្លាតស្តង់ដា =០,៥៦)។

## ៤.៤ ការពិភាក្សានៃការអនុវត្តស្តង់ដាទាំង៩ពីស្ថានភាពនៃការធានាគុណភាពអប់រំ

ក្រាហ្វទី 21៖ លទ្ធផលសរុបនៃការអនុវត្តស្តង់ដាទាំង៩ពីស្ថានភាពនៃការធានាគុណភាពអប់រំ




*ចំនួនអ្នកចូលរួមឆ្លើយសំណួរ៖ គណៈគ្រប់គ្រង *(n=3), គ្រូឧទ្ទេស *(n=44), គរុសិស្ស *(n=129)*

ក្រាហ្វទី២១ខាងលើបង្ហាញថា **ការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាព អប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគសរុបកម្រិតអត្រាពិន្ទុ=៤,០១)។ ស្តង់ដាដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "ស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,១១) និង "ស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ" ក្នុងកម្រិត "ល្អ" ស្តង់ដាដែលទទួលបានពិន្ទុខ្ពស់គឺ "ស្តង់ដា៤៖ កម្មវិធីអប់រំ" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៩)។ ស្តង់ដាដែលទទួលបានពិន្ទុទាបគឺ "ស្តង់ដា៩៖ ការធានាគុណភាពអប់រំផ្ទៃក្នុង" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៨៩) ស្តង់ដាដែលទទួលបានពិន្ទុទាបបំផុតគឺ "ស្តង់ដា៧៖ ធនធានរូបវន្ត" ក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៧)។

លទ្ធផលសរុបនៃការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ គឺក្នុងកម្រិត "ល្អ" (មធ្យមភាគសរុបកម្រិតអត្រាពិន្ទុ=៤,០១)។ ប្រការនេះបង្ហាញថាសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប បានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិភាគច្រើន។

យោងតាម ACC (2016, 2019) បានបង្ហាញពីលទ្ធផលនៃការវាយតម្លៃសម្រាប់ការទទួលស្គាល់គុណភាពអប់រំថា មានពិន្ទុមធ្យមភាគសរុបចាប់ពី១,០០ ដល់២,៤៩ ការទទួលស្គាល់គុណភាពអប់រំក្នុងកម្រិត "បេក្ខភាព" ក្នុងរយៈពេល២ឆ្នាំ មានពិន្ទុមធ្យមភាគសរុបចាប់ពី២,៥០ ដល់៣,៤៩ ការទទួលស្គាល់គុណភាពអប់រំក្នុងកម្រិត "បណ្តោះអាសន្ន" ក្នុងរយៈពេល៣ឆ្នាំ មានពិន្ទុមធ្យមភាគសរុបចាប់ពី ៣,៥០ ដល់៥,០០ ការទទួលស្គាល់គុណភាពអប់រំក្នុងកម្រិត "ពេញសិទ្ធិ" ក្នុងរយៈពេល៥ឆ្នាំ។

## ៤.៥ ឧត្តមានុវត្តន៍ក្នុងការអនុវត្តការធានាគុណភាពអប់រំ

### ៤.៥.១ គណៈគ្រប់គ្រង និងអតីតគណៈគ្រប់គ្រង

សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប បានកសាងអភិវឌ្ឍធនធានមនុស្សរីកចម្រើនជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន គឺអាស្រ័យ ការគាំទ្រ ការចូលរួម ការលើកទឹកចិត្ត ពីថ្នាក់ដឹកនាំគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។ សមិទ្ធិផលស្នាដៃទាំងអស់នេះទទួលបានពីការដឹកនាំ ការគ្រប់គ្រង របស់អតីតគណៈគ្រប់គ្រង និងគណៈគ្រប់គ្រងបន្តវេន គិតចាប់ពីឆ្នាំ១៩៨០ ដល់បច្ចុប្បន្ន (PTTC, ២០២២)៖

(១) ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩០ លោក ទុំ ព្រឿង (ប្រធាន) លោក ទេព ទិត្យ (អនុប្រធានទី១) លោកស្រី ស៊ិន ណម [3] (អនុប្រធានទី២)។

(២) ចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៨ លោក ទេព ទិត្យ [4] (នាយក) លោក អ៊ុង សិរីឌី [5] (នាយករង) លោក ឆេង ទុយ (នាយករង)។

---

[3] **លោកស្រី ស៊ិន ណម** ជាអតីតអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប តាមប្រកាសលេខ ១២០៧ អយក៥.ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ របស់ក្រសួងអប់រំ យុវជន និងកីឡា។ បច្ចុប្បន្ន **លោកជំទាវ ស៊ិន ណម** ជាសមាជិកក្រុមប្រឹក្សាខេត្តសៀមរាប តាមសេចក្តីសម្រេចលេខ ១២៣ សសរ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាខេត្តសៀមរាប (សាលាខេត្តសៀមរាប, ២០១៥)។

[4] **លោក ទេព ទិត្យ** ត្រូវបានផ្ទេរពីនាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ឱ្យបម្រើការនៅការិយាល័យអធិការកិច្ច ជាបណ្តោះអសន្ន តាមលិខិតឧទ្ទេសនាមលេខ ២១០ អយក៥.បលប ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩ របស់មន្ទីរអប់រំ យុវជន

(៣) ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ លោក ទេព ទិត្យ (នាយក) លោក លាវ ឌិរ៉ា (នាយករង) លោក ឆេង ទុយ (នាយករង)។

(៤) ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៦ លោក លាវ ឌិរ៉ា [6] (នាយក) លោក អន ឈុត [7] (នាយករង) លោក ឈត់ ធៀង (នាយករង)។

(៥) ចាប់ពីឆ្នាំ២០១៦ ដល់បច្ចុប្បន្ន លោក ឈត់ ធៀង [8] (នាយក) លោកស្រី ហ៊ុន មករា [9] (នាយិការង) លោក វ៉ៃ ចយ [10] (នាយករង)។

## ៤.៥.២ ឧត្តមានុវត្តន៍ទូទៅ

សាលាគរុកោសល្យ និងវិក្រឹតការខេត្ត បាន៖

---

និងកីឡា តាមលិខិតលេខ១១៨ អយកខ.បលប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប (មន្ទីរអេយក, ២០០០)។

[5] **លោក អ៊ុង សិរីឌី** ជាអតីតអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប តាមប្រកាសលេខ១២០៧ អយក.ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ របស់ក្រសួងអប់រំ យុវជន និងកីឡា។ ជាអតីតប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប តាមប្រកាសលេខ២៤៨ អយក.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រោយប្រកាសចូលនិវត្តន៍ **លោក អ៊ុង សិរីឌី** ត្រូវបានតែងតាំងជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា មានឋានៈស្មើប្រធាននាយកដ្ឋាន តាមអនុក្រឹត្យលេខ ១២៦៧ អនក្រ.តត ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា។

[6] **លោក លាវ ឌិរ៉ា** ត្រូវបានបង្គាប់ការពីអធិការបឋម ជានាយកដឹកនាំរួម ជាបណ្ដោះអាសន្ន សាលាគរុកោសល្យ និងវិក្រឹតការខេត្ត តាមលិខិតបង្គាប់ការលេខ ១១៨ អយកខ.បលប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប (មន្ទីរអេយក, ២០០០)។ បន្ទាប់មក **លោក លាវ ឌិរ៉ា** ត្រូវបានតែងតាំងជា "នាយក" សាលាគរុកោសល្យ និងវិក្រឹតការខេត្ត តាមប្រកាសលេខ ៩៧ អយក.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងអប់រំ យុវជន និងកីឡាខេត្តសៀមរាប (ក្រសួងអយក, ២០០៤)។ **លោក លាវ ឌិរ៉ា** ជាប្រធានកិត្តិយស (លេខ ៤៤៧ សគវ.សរ, ២០២១)

[7] **លោក អន ឈុត** គ្រូមធ្យមសិក្សាទុតិយភូមិ ជានាយករងទទួលបន្ទុកគ្រប់គ្រងបច្ចេកទេស ជាបណ្ដោះអាសន្ន សាលាគរុកោសល្យ និងវិក្រឹតការខេត្ត តាមលិខិតបង្គាប់ការលេខ១១៨ អយកខ.បលប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប (មន្ទីរអេយក, ២០០០)។

[8] **លោក ឈត់ ធៀង** បានទទួលបានប័ណ្ណសរសើរពីក្រសួងអប់រំ យុវជន និងកីឡា ដែលអនុវត្តបានជា "គ្រូល្អ" ក្នុងការងារផ្សព្វផ្សាយសិទ្ធិកុមារនៅសាលាគោលដៅនៃខេត្តសៀមរាប (ក្រសួងអយក, ២០០៧)។ បន្ទាបមក **លោក ឈត់ ធៀង** ត្រូវបានតែងតាំងជានាយករងសាលាគរុកោសល្យវិក្រឹតការខេត្ត តាមប្រកាសលេខ៩៧ អយក.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងអប់រំ យុវជន និងកីឡាខេត្តសៀមរាប។ បន្ទាប់មកទៀត **លោក ឈត់ ធៀង** ត្រូវបានតែងតាំងជា "**នាយក**" សាលាគរុកោសល្យវិក្រឹតការខេត្តយោងដីកាលេខ ០៤៦/១៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ របស់អភិបាលនៃគណៈអភិបាលខេត្តសៀមរាប។

[9] **លោកស្រី ហ៊ុន មករា** ត្រូវបានតែងតាំងជា "**នាយិការង**" សាលាគរុកោសល្យវិក្រឹតការខេត្ត តាមដីកាលេខ ០៤៦/១៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ របស់អភិបាល នៃគណៈអភិបាលខេត្តសៀមរាប។

[10] **លោក វ៉ៃ ចយ** ត្រូវបានតែងតាំងជា "**នាយករង**" សាលាគរុកោសល្យវិក្រឹតការខេត្ត តាមដីកាលេខ ០៤៦/១៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ របស់អភិបាល នៃគណៈអភិបាលខេត្តសៀមរាប។

(១) ចូលរួមអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនដែលក្រសួងអប់រំបានអនុម័ត ឆ្នាំ២០១៥ បានដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗចំនួន៩ ដើម្បីធ្វើកំណែទម្រង់គ្រូបង្រៀនក្នុងគោលដៅ គុណភាព ស្តង់ដា ប្រសិទ្ធភាព និងសមត្ថភាពរបស់គ្រូបង្រៀនកម្ពុជាឱ្យឈានចូលស្តង់ដា ប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់។

(២) រក្សាបាននូវសុខដុមនីយកម្មការងាររបស់បុគ្គលិកអប់រំ ការសិក្សារបស់គរុសិស្ស និង ការចូលរួមអភិវឌ្ឍរបស់ភាគីពាក់ព័ន្ធ។

(៣) ជួសជុលនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៩) សម្រាប់ដំណើរការបណ្តុះបណ្តាលសរុបរួម១៣អគារ ស្មើ៩៦បន្ទប់ តាមអគារនីមួយៗ មានបង្គន់អនាម័យសរុប១៩បន្ទប់។ ការជួសជុលដោយថវិកាអង្គការយូនីសេហ្វ(UNICEF) ថវិកាអង្គការយូណេស្កូ (UNESCO) ថវិកាអង្គការវ៉េតបាណា ប្រទេសន័រវេស្សន៍ ថវិកា ផែនដីមនុស្សនៃប្រទេសហៃលហ្សិក ថវិកាផែនដីមនុស្សនៃប្រទេសបារាំង ថវិកាអង្គការ AGRISUD ថវិកាគម្រោងអប់រំមូលដ្ឋាននិងបណ្តុះបណ្តាលគ្រូបង្រៀន(អ.ម.ប.គ) របស់ប្រទេសបែលហ្សិក ថវិកាប្រជាជនជប៉ុនតាមរយៈស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ថវិការបស់គរុសិស្សជំនាន់ទី៣៤(លាបថ្នាំ) ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា។ ប្រការនេះបង្ហាញថាសាលាមានទំនាក់ទំនងល្អជាមួយ ថ្នាក់ដឹកនាំនៃក្រសួង អប់រំ អង្គការ ដៃគូអភិវឌ្ឍវិស័យអប់រំ និងភាគីពាក់ព័ន្ធ ចូលរួមគាំទ្រអភិវឌ្ឍនៅសាលា គរុកោសល្យ និងវិក្រឹតការខេត្ត (PTTC, 2022)។

(៤) រៀបចំរចនាសម្ព័ន្ធការងារច្បាស់លាស់មានបំណែងចែកភារកិច្ច អនុវត្តតួនាទីភារកិច្ច តាមកម្រិត និងរៀបចំគោលការណ៍ណែនាំផ្ទៃក្នុងសាលារៀន(PTTC, 2022)។

(៥) រៀបចំផែនការអភិវឌ្ឍសាលាគរុកោសល្យ និងវិក្រឹតការ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា "កំណែទម្រង់ការអប់រំគ្រូបង្រៀននៅសាលា គរុកោសល្យ"។

(៦) រៀបចំកម្មវិធីច្បាស់លាស់ក្នុងការបណ្តុះបណ្តាលតាមប្រព័ន្ធ១២+២ នេះ គឺមានសារៈសំខាន់ណាស់ដើម្បីកសាងធនធានមនុស្សឱ្យបានចូលរួមអភិវឌ្ឍសង្គមជាតិ។

(៧) លើកទឹកចិត្តគាំទ្រគ្រូឧទ្ទេសមានសមត្ថភាពកម្រិតគុណវុឌ្ឍិ បរិញ្ញាបត្រ (២៧នាក់) បរិញ្ញាបត្រជាន់ខ្ពស់ (១៥នាក់) និងខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់ (០១នាក់)។

(៨) បណ្តុះបណ្តាលគ្រូបង្រៀនសរុបរួម១០៤វគ្គ ចំនួន១១ ៣៩៥នាក់ ស្រី៥ ០១១នាក់ (គិតត្រឹមជំនាន់ទី៣៨) (PTTC, 2022)។ ប្រការនេះបង្ហាញថាសាលាគរុកោសល្យ និងវិក្រឹតការ មានជំនឿទៅលើការបណ្តុះបណ្តាលអភិវឌ្ឍធនធានមនុស្សផ្តោតលើគុណភាព សេចក្តីថ្លៃថ្នូរប្រកបដោយវិជ្ជាជីវៈ ចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គមឱ្យឆ្លើយតបនឹងច្បាប់ស្តីពីច្បាប់អប់រំ អំពីការបណ្តុះបណ្តាលបុគ្គលិកអប់រំ ត្រង់មាត្រា២០ បានចែងថា "បុគ្គលិកអប់រំត្រូវឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យដែលទទួលស្គាល់ក្រសួងទទួលបន្ទុកវិស័យអប់រំ" ។

(៩) សម្របសម្រួលដល់គ្រូឧទ្ទេសចំនួន៤នាក់ ស្រី៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី "**Professional Development Program in English Language Teaching Methodology for Cambodian Master Teacher Trainers**" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ខែឧសភា ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌល SEMEO Regional Language Center ប្រទេស សិង្ហបុរី តាមលិខិតឧទ្ទេសនាមលេខ៣០៧៤ អយក.ឧទន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ (ក្រសួងអយក, ២០១៧)។

(១០) សម្របសម្រួលដល់គណៈគ្រប់គ្រងចំនួន២នាក់ ស្រី១នាក់ បានបន្តពង្រឹកសមត្ថភាពបន្ថែមថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រងអប់រំ (លិខិតឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន, ២០២២) និងឯកទេសប្រឹក្សាគរុកោសល្យ (លិខិតឧទ្ទេសនាមលេខ ១៨៥៤ អយក.ឧទន, ២០២២) គ្រូឧទ្ទេសចំនួន២នាក់ ស្រី១នាក់ បានបន្តពង្រឹកសមត្ថភាពបន្ថែមថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រងអប់រំ (លិខិត

ឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន, ២០២២) និងថ្នាក់បណ្ឌិត ឯកទេសគ្រប់គ្រងអប់រំ (បញ្ជីរាយនាមបេក្ខជន, ២០២១) នៅវិទ្យាស្ថានជាតិអប់រំ (NIE)។

(១១) សម្របសម្រួលដល់គ្រូឧទ្ទេសចំនួន៥នាក់ ស្រី២នាក់ ចូលរួមវគ្គសិក្ខាសាលាស្ដីអំពី "**Science and Technology Experience Course**" នៅសាកលវិទ្យាល័យ Nihon Fukushi University ទីក្រុង Nagoya ប្រទេស ជប៉ុន (No: 326 MoEYS/Adm, 2022)។

### ៤.៥.៣ ការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ

សាលាគរុកោសល្យ និងវិក្រឹតការ បានបង្កើតនូវសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍក្នុងនិងក្រៅប្រទេសសម្រាប់គាំទ្រដល់កម្មវិធីអប់រំរបស់សាលាកន្លងមក (PTTC, ២០២២) ដូចខាងក្រោមៈ

(១) សាកលវិទ្យាល័យប្រទេសជប៉ុន NIHON FUKUSHI UNIVERSITY គម្រោងបានផ្ដល់សម្ភារ ICT និងផ្ទាំងស្លាយសម្រាប់បន្ទប់រៀនភាសាអង់គ្លេស និងកុំព្យូទ័រ

(២) សាកលវិទ្យាល័យ UBON RATCHATHANI RAJABBAT

(៣) គ្រូស្ម័គ្រចិត្តជនជាតិហូឡង់ បង្រៀនភាសាអង់គ្លេស និងចិត្តវិទ្យាក្រៅម៉ោងតាមប្រព័ន្ធអនឡាញ

(៤) សាកលវិទ្យាល័យ UNIVERSITY I AGDER (UIA) ផ្លាស់ប្ដូរគ្រូ និងនិស្សិត

(៥) សាកលវិទ្យាល័យ SAVEZONE KOWEA គម្រោងអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស គរុសិស្ស

(៦) សាកលវិទ្យាល័យ SURIN RATCHATHANI RAJABHAT ប្រទេសថៃ កម្មវិធីផ្លាស់ប្ដូរវប្បធម៌គ្រូនិងគរុសិស្ស

(៧) សាកលវិទ្យាល័យ KAMPHAENG PHET RAJABHAT ទស្សនកិច្ចសិក្សាចែករំលែកបទពិសោធន៍

(៨) សាកលវិទ្យាល័យ កាលីហ្វញ៉ា សហរដ្ឋអាមេរិក (សាស្ត្រាចារ្យ HARY) បានផ្ដល់គម្រោងផ្ដល់កុំព្យូទ័រ និងអាហារូបករណ៍សិស្ស

(៩) អង្គការសុបិន្តសហគមន៍បញ្ជូនគ្រូបង្រៀនភាសាអង់គ្លេសក្នុងម៉ោងសិក្សា។

### ៤.៥.៤ ស្នាដៃនិងការសរសើរ

សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប (PTTC, 2022) បាន៖

(១) ទទួលទង់ជ័យលាភី "**ទង់ជ័យលាភីថ្នាក់លេខ១**" ឆ្នាំសិក្សា២០០៥-២០០៦ ពីក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៦។

(២) ទទួលប័ណ្ណសរសើរពីសាកលវិទ្យាល័យ UBON RATCHATHANI RAJABBAT (ប្រទេសថៃ) ឆ្នាំ២០០៨ (President of UBON RATCHATHANI RAJABHAT University (The Assistant Professor KASEM BOONROM) was very pleased to express their deep appreciation to SIEM REAP Provincial Teacher Training College, CAMBODIA, as a leading co-organizer of the 2$^{nd}$ International Conference on "**Multi-disciplinary Research and practice on Human Development**", 2-8 July 2008, Thailand, with faith and trust in the future, the partnership has built will last forever.

(៣) ចុះអនុស្សរណៈយោគយល់ (Memorandum of Understanding, MOU) រវាងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប (PTTC of SIEM REAP) ជាមួយសាកលវិទ្យាល័យ INDUSTRIAL TECHNOLOGY FACULTY OF SURINDRA RAJABHAT To: build a relationship on Academic, Arts and cultures cooperation, Research projects, Public Services, Student affairs and Education quality; participate research activities, seminars, conferences and academic meeting; exchange of Information, documents, publications and other teaching materials" ឆ្នាំ២០១៣។

(៤) ទទួលលិខិតថ្លែងអំណរគុណពីមន្ទីរពេទ្យបង្អែកខេត្តសៀមរាប អំពីការចាត់ចែងចូលរួមបរិច្ចាកឈាមពីគរុសិស្ស នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ សម្រាប់ការប្រើប្រាស់ក្នុងការជួយសង្គ្រោះអ្នកជំងឺដែលត្រូវការឈាមនៅមន្ទីរពេទ្យខេត្តសៀមរាប។

(៥) ទទួលប័ណ្ណសរសើរពីសាកលវិទ្យាល័យ SURINDRA RAJABHAT UNIVERSITY ការចូលរួមកម្មវិធី "The International Custom Fashion Show 2018" នាថ្ងៃទី២៥-៣១ ខែមករា ឆ្នាំ២០១៨ នៅប្រទេសថៃ។

(6) ទទួលប័ណ្ណសរសើរពីអង្គការ The Rotary Foundation, Certificate of Appreciation is awarded to SIEM REAP Provincial Teacher Training College, in grateful appreciation for supporting the Vocational Training Team Program which made a real difference to the experience and the education of future teachers, 1oth of January 2019.

## ៤.៦ បញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថាសាលាគរុកោសល្យ និងវិក្រឹតការខេត្តនៅមានចំណុចប្រឈមមួយចំនួនដូចខាងក្រោម៖

(១) គុណវឌ្ឍិគ្រូឧទ្ទេសមួយចំនួនពុំទាន់ស្មើគ្នានៃកម្រិតកក្របខណ្ឌនៅឡើយ។

(២) សមត្ថភាពដំបូងរបស់គរុសិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងកុំព្យូទ័រពុំទាន់ល្អប្រសើរនៅឡើយ។

(៣) បច្ចុប្បន្នប្រទេសកម្ពុជាស្ថិតក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.0 (Industry 4.0) ដែលទាមទារគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស អនុវត្តឱ្យទាន់សង្គមបែបឌីជីថល។

## ៤.៧ ភាពជោគជ័យក្នុងការអនុវត្តការធានាគុណភាពអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន ក្នុងនោះកំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ (ក្រសួងអយក, ២០១៨)។ ដើម្បី

ឆ្លើយតបនឹងគោលនយោបាយស្តីពីគ្រូបង្រៀន (TPAP) (ក្រសួងអយក, ២០១៥) ក្របខណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន និងនាយកសាលារៀន (CPD) ក្រសួងអប់រំ (២០១៩) បានៈ

(១) ដាក់ចេញនូវអាទិភាពនៃកំណែទម្រង់អប់រំគ្រូបង្រៀននៅសាលាគរុកោសល្យ ដើម្បីពង្រឹងសមត្ថភាពគ្រូឧទ្ទេសលើចំណេះដឹងមុខវិជ្ជា វិធីសាស្ត្របង្រៀន និងបច្ចេកវិទ្យាព័ត៌មានវិទ្យា (MoESYS, 2019; ESP-2019-23) និងពិចារណាដើម្បីទាក់ទាញរក្សាគ្រូឧទ្ទេសមានគុណវុឌ្ឍិខ្ពស់នៃគន្លងអាជីពគ្រូឧទ្ទេសសាលាគរុកោសល្យ (CPD, 2019)។

(២) លើកទឹកចិត្តឱ្យមន្ត្រីអប់រំបន្តបង្កើននិងពង្រីកគុណវុឌ្ឍិរបស់ខ្លួននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ (CPD, 2019)។

(៣) លើកកម្ពស់ការអភិវឌ្ឍអាជីព ការដំឡើងឋានៈផ្អែកលើគុណផលការងារ និងការដំឡើងកាំប្រាក់តាមគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈក្នុងវិស័យអប់រំ ផែនការមេស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈការអនុវត្តការងារវិក្រឹតការឬវិក្រឹតការនៅនឹងកន្លែង (CPD, ២០១៩)។

(៤) ពង្រឹងនិងពង្រីកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងស្តង់ដា ដើម្បីលើកកម្ពស់គុណភាពបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន (MoEYS; CPD, 2019)។

(៥) ផ្តល់ឱកាសដល់សាលាគរុកោសល្យលើកសំណើផ្តល់ប័ណ្ណសរសើរ ដំឡើងឋានន្តរសក្តិ ឬការលើកទឹកចិត្តផ្សេងៗទៀតតាមទំហំការងារ និងចាត់តាំងបុគ្គលិកចូលរួមក្នុងសិក្ខាសាលានិងកម្មវិធីផ្សេងៗ (ប្រការ៣៤នៃប្រកាសលេខ ២៩៥៤ អយក.ប្រក, ២០២០)។

(៦) គរុសិស្សក្រោយបញ្ចប់ការសិក្សាកម្មវិធីអប់រំគ្រូបង្រៀនបាននូវកញ្ចប់សមត្ថភាពស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា និងស្តង់ដាសមត្ថភាពគ្រូបង្រៀនរបស់អាស៊ានក្នុងសតវត្សទី២១ អាចបង្ហាញសមត្ថភាពក្នុងការគិតប្រកបដោយការច្នៃប្រឌិត ការឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយ ការត្រិះរិះ និងការដោះស្រាយបញ្ហា និងទទួលស្គាល់ឱ្យតម្លៃគណនេយ្យភាពនៃកិច្ចការគ្រូបង្រៀន (CPD, 2020)។

(៧) គ្រូចេញថ្មីមានឱកាសពង្រឹង និងពង្រីកសមត្ថភាពទទួលបានបទពិសោធន៍ល្អតាមរយៈការធ្វើកម្មសិក្សាមួយឆ្នាំដំបូងដោយមានការណែនាំពីគ្រូប្រឹក្សា និងអធិការកិច្ចពីនាយកសាលា (CPD, ២០១៩)។

(៨) លើកទឹកចិត្តគ្រូបង្រៀនឱ្យឆ្លើយតបនឹងគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន (Teacher Career Pathway) ដែលចែកចេញជា៣គន្លង គឺ (១)គន្លងគ្រូបង្រៀន (២)គន្លងគណៈគ្រប់គ្រងសាលារៀន (៣)គន្លងអ្នកឯកទេសអប់រំ (ក្រសួងអប់រំ, ២០២១)។ គន្លងនីមួយៗមាន៣កម្រិតនៃលក្ខណៈវិនិច្ឆ័យតម្លើងឋានៈ (គុណវុឌ្ឍិ ចំណេះដឹង អតីតភាពការងារអនុវត្តគន្លងអាជីពគ្រូបង្រៀន និងការវាយតម្លៃគុណផលការងារ) (CPD, ២០១៩)។

(៩) ដាក់ចេញគោលនយោយាបាយស្តីពីគ្រូបង្រៀន (TPAP) (ក្រសួងអយក, ២០១៥) ត្រង់ **យុទ្ធសាស្ត្រទី៤ ការអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន** ក្នុងនោះ យុទ្ធសាស្ត្រ៤.១ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សម្ភារឧបទ្ទេស(បង្រៀន និងរៀន) បរិក្ខារឧបករណ៍ICT បន្ទប់ពិសោធន៍ ។ល។ យុទ្ធសាស្ត្រ៤.២ ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន (ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន) (MoEYS, 2019; ESP 2019-23)។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក ៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

អ្នកសិក្សាស្រាវជ្រាវបានប្រើវិធីសាស្ត្រក្នុងការចុះប្រមូលទិន្នន័យ តាមបែបបរិមាណវិស័យ និងបែបគុណវិស័យ។ ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់សូចនាករក្នុងការរៀបចំកម្រងសំណួរដើម្បីឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ បង្ហាញពីឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំ គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤)កម្មវិធីអប់រំ (៥) សេវាគរុសិស្ស/និស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨) ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

ជាលទ្ធផលនៃការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំ បានបង្ហាញថាគណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០៥ គម្លាតស្តង់ដា=១,០៧)។ គ្រូឧទ្ទេសបានផ្តល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៣,៧៦ គម្លាតស្តង់ដា=០,៨៣)។ ចំណែកគរុសិស្សបានផ្តល់ទិន្នន័យសរុបក្នុងកម្រិត "ល្អ" (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,២០ គម្លាតស្តង់ដា=០,៥០)។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលបានបង្ហាញជូននេះ អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថា ស្ថានភាពនៃការធានាគុណភាពអប់រំតាមការអនុវត្តស្តង់ដាទាំង៩នៃការធានាគុណភាពអប់រំទទួលកម្រិតល្អគួរជាទីមោទនៈ (មធ្យមភាគកម្រិតអត្រាពិន្ទុ=៤,០១)។ ប្រការនេះបង្ហាញថាសាលាគរុកោសល្យ និងវិក្រិតការខេត្តសៀមរាបបានបំពេញគ្រប់សូចនាករនៃស្តង់ដាជាតិភាគច្រើន។ ក្នុងន័យនេះ គណៈគ្រប់គ្រងបានផ្សព្វផ្សាយចក្ខុវិស័យបេសកកម្មនិងគោលបំណង បានទូលំទូលាយដល់ភាគីពាក់ព័ន្ធ មានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា ព្រមទាំងបានកំណត់តួនាទីនិងការទទួលខុសត្រូវ។ ចំពោះគ្រូឧទ្ទេសបានដើរតួនាទីអនុវត្តកិច្ចការផ្សេងកម្រិតល្អដែលគណៈគ្រប់គ្រងបានប្រគល់ភារកិច្ចឱ្យបានបំពេញភារកិច្ចរបស់ខ្លួន គឺដើម្បីលទ្ធផលសិក្សារបស់គរុសិស្ស

ប្រកបដោយគុណភាព។ ចំណែកគរុសិស្សបានចូលរួមរាល់គ្រប់សកម្មភាពនៃការសិក្សាកម្រិតល្អណាស់តាមរយៈការណែនាំ ការខិតខំប្រឹងប្រែងរបស់សាលា និងភាគីពាក់ព័ន្ធ។

ទោះបីយ៉ាងណា លទ្ធផលនេះក៏នៅមានចំណុចប្រឈមមួយផងដែរដោយគុណវឌ្ឍិគ្រូឧទ្ទេសមួយចំនួនពុំទាន់ស្មើគ្នានៃកម្រិតកក្របខណ្ឌនៅឡើយ (ទាបជាងបរិញ្ញាបត្រមាន២,២៧ភាគរយ បរិញ្ញាបត្រមាន៦១,៣៦ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់មាន៣៤,០៩ភាគរយ និងខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់មាន២,២៧ភាគរយ)។ សមត្ថភាពជំបូងរបស់គរុសិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងកុំព្យូទ័រពុំទាន់ល្អប្រសើរនៅឡើយ។ បច្ចុប្បន្នប្រទេសកម្ពុជាស្ថិតក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.០ (Industry 4.0) ដែលទាមទារគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្សអនុវត្តឱ្យទាន់សង្គមបែបឌីជីថលឱ្យឆ្លើយតបនឹងកំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ គោលនយោបាយស្តីពីគ្រូបង្រៀន (TPAP) និងក្របខណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន (CPD)។

## ៥.២ សំណូមពរ

តាមរយៈលទ្ធផលនេះ អ្នកសិក្សាស្រាវជ្រាវបានសំណូមពរដល់អ្នកគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់និងភាគីពាក់ព័ន្ធ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យកាន់តែមានគុណភាពអប់រំល្អប្រសើរបន្ថែមទៀតដូចតទៅៈ

### ៥.២.១ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ គួរៈ

- រៀបចំការប្រឡងជ្រើសរើសបឋមសិក្សាតាមបែបស្តង់ដាឱ្យឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ត្រង់ចំណុច៣ គឺ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានប្រយោជន៍។
- ជួយរិក្រឹតការឡើងវិញដល់គ្រូបឋមសិក្សាមានសញ្ញាបត្រ ដើម្បីពង្រីកចំណេះដឹងបន្ថែមលើផ្នែកវិធីសាស្រ្តបង្រៀននិងរៀនតាមបែបអប់រំសតវត្សទី២១នៅតាមមូលដ្ឋាន។

- រៀបចំប្រឡងជ្រើសរើសគ្រូបឋមសិក្សាឱ្យមានវិញ្ញាសាភាសាអង់គ្លេស ត្បិតពួកគាត់ត្រូវបង្រៀនភាសាអង់គ្លេសដល់សិស្សបន្ត។
- បើកវគ្គបំប៉នសមត្ថភាពក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុកថ្មី(DTMT) ចុះពិនិត្យគ្រូបង្រៀនចេញថ្មីនៅតាមសាលារៀន។
- រៀបចំផែនការសកម្មភាពគៀរគរថវិកាបន្ថែម ជាមួយអង្គការដៃគូអភិវឌ្ឍវិស័យអប់រំ សប្បុរសជន និងក្រសួងពាក់ព័ន្ធបើកវគ្គបំប៉នសមត្ថភាពគ្រូឧទ្ទេស បង្កើនគុណវឌ្ឍិកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង/ឬថ្នាក់បណ្ឌិត ដើម្បីធានាគុណភាពអប់រំប្រកបដោយគុណភាពឱ្យឆ្លើយតបនឹងក្របខណ្ឌគុណវឌ្ឍិជាតិកម្ពុជា (អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា)
- ចុះពិនិត្យតាមដាន និងវាយតម្លៃ ទទួលស្គាល់គុណភាពអប់រំតាមប្រព័ន្ធក្រេឌីត ពង្រីកការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ដើម្បីបង្កើនសមត្ថភាពនិងគុណវុឌ្ឍិគ្រូបង្រៀនអាចប្រជាប្រសងជាមួយបុគ្គលិកអប់រំនៃប្រទេសក្នុងតំបន់ និងអាស៊ាន។

### ៥.២.២ មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ គួរៈ

- ចូលរួមសហការរាល់គ្រប់កម្មវិធីជាមួយសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ដែលមានការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល ការិយាល័យបឋមសិក្សា និងការិយាល័យអធិការកិច្ច ដើម្បីចុះពិនិត្យជួយគរុសិស្សពេលចុះកម្មសិក្សាគរុកោសល្យ ចុះអធិការកិច្ច ដើម្បីពង្រឹងគុណភាពអប់រំ និងបច្ចេកទេសបង្រៀននិងរៀន ព្រមទាំងបញ្ជ្រាបចំណេះដឹងវង្វាយតម្លៃតេស្តស្តង់ដា (PISA) ដល់គរុសិស្សបន្ថែម។
- ចូលរួមបន្តការគាំទ្រអភិវឌ្ឍកម្មវិធីអប់រំបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យស្របតាមស្តង់ដាសមត្ថភាពកម្រិតគុណវុឌ្ឍិជាតិ បានចែងក្នុងប្រការ២នៃអនុក្រឹត្យលេខ១៤៣ អនក្រ.បក ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងចែងក្នុងប្រការ១០ ប្រការ១១ ប្រការ១២ និងប្រការ១៣ នៃប្រកាសលេខ ២៩៥៤ អយក.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០។

- ទំនាក់ទំនងជាមួយក្រសួងអប់រំ ជួយបន្ថែមដល់សាលាគរុកោសល្យ និងវិក្រឹតការ ពីព្រោះសាលាគរុកោសល្យជានីតិបុគ្គលសាធារណៈគ្រប់គ្រងគាំទ្រដោយរដ្ឋ តាមរយៈការប្រឡងជ្រើសរើសគរុសិស្សបណ្តុះបណ្តាល និងឧបត្ថម្ភអាហារូបករណ៍។
- ផ្តល់គុណតម្លៃ ភាពយុត្តិធម៌ ដល់បេក្ខជនទាំងពីរភេទដែលមានសមត្ថភាពប្រកបដោយបរិយាបន្ន ស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាផ្តោតយកចិត្តទុកដាក់ដោយតម្កល់ "មនុស្ស" ជាអាទិភាពទី១នៃវិស័យអាទិភាព៤ ដែលចតុកោណទី១ គឺការអភិវឌ្ឍធនធានមនុស្ស។

### ៥.២.៣ សាលាគរុកោសល្យ និងវិក្រឹតការ

សាលាគរុកោសល្យ និងវិក្រិតការ គួរ៖

- បង្កើនការទំនាក់ទំនងបន្ថែមជាមមួយមន្ទីរអប់រំ និងសាលារៀន ពង្រឹងបន្ថែមផ្នែករដ្ឋបាលដឹកនាំគ្រប់គ្រង ការចុះអធិការកិច្ចថ្នាក់រៀនពង្រឹងបន្ថែមផ្នែកបច្ចេកទេស និងជួយតម្រង់ទិសផ្សព្វផ្សាយការវង្វាយតម្លៃតេស្តស្តង់ដា (PISA)។
- ទំនាក់ទំនងបន្ថែមជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបន្តអនុវត្តការធានាគុណភាពអប់រំ ការបណ្តុះបណ្តាលធនធានមនុស្សផ្សារភ្ជាប់នឹងការអនុវត្តផ្ទាល់ (នវានុវត្តន៍) ឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០ ត្រង់យុទ្ធសាស្ត្រចំណុច ៥.១ គឺកសាងនិងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ ទាំងគុណភាព និងសមាសភាពមានសីលធម៌វិជ្ជាជីវៈដោយពិនិត្យពិចារណាទៅលើកត្តាសមភាពយេនឌ័រ។
- រៀបចំផែនការសកម្មភាពស្នើសុំក្រសួងអប់រំ បើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនបន្ថែមដែលបានចេញបម្រើការងារនៅមូលដ្ឋាន និងគ្រូចេញថ្មី ដើម្បីបង្កើនគុណវុឌ្ឍិតាមប្រព័ន្ធក្រេឌីតដើម្បីឆ្លើយតបនឹងអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៤ ស្តីពីក្របខណ្ឌគុណវឌ្ឍិជាតិកម្ពុជា។

- បង្កើតការទំនាក់ទំនងជាមួយវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដើម្បីដកស្រង់បទពិសោធន៍អំពីការដឹកនាំគ្រប់គ្រង វិធីសាស្ត្របង្រៀននិងរៀន និងពង្រីកកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធ១២+២ ទៅជា១២+៤ ឱ្យស្របតាមតម្រូវការជាតិ កំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ ដើម្បីក្លាយជាវិទ្យាស្ថានគរុកោសល្យ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩ ។
- បន្តការអនុវត្តប្រកាសលេខ២៩៥៤ អយក.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីគោលការណ៍និងបន្តការការងារគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាល ត្រង់ប្រការ១០ គឺតួនាទី និងភារកិច្ចការបណ្តុះបណ្តាលដល់គរុសិស្ស គរុនិស្សិត និងបុគ្គលិកអប់រំ។
- ធ្វើបច្ចុប្បន្នភាពកម្មវិធីអប់រំតាមប្រព័ន្ធក្រេឌីត និងតាមប្រព័ន្ធ១២+២ ទៅជា១២+៤ ដើម្បីត្រៀមប្រែក្លាយសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ទៅជាវិទ្យាស្ថានគរុកោសល្យ ឱ្យឆ្លើយតបនឹងកំណែទម្រង់សាលារៀននៅកម្ពុជា (ហង់ជួន ណារ៉ុន, ២០២០) ស្តីពីកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូនៅកម្ពុជា (p.329-357)។

### ៥.២.៤ សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ប្រធានបទនៃការសិក្សាស្រាវជ្រាវនេះផ្តោតលើ "ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប" មានវិសាលភាពទៅលើ១គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅខេត្តសៀមរាប។ សម្រាប់ការសិក្សាស្រាវជ្រាវបន្តគួរផ្តោតលើ៖

- ការសិក្សាប្រៀបធៀបទៅលើការធានាគុណភាពអប់រំរវាងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងវិទ្យាស្ថានគរុកោសល្យ។
- យុទ្ធសាស្ត្រនៃការអនុវត្តការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ដោយពង្រីកចំនួនសំណាកតាមបណ្តាខេត្តនានា ដើម្បីធានានិរន្តរភាពគុណភាពអប់រំនៅកម្ពុជា។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារជាភាសាខ្មែរ


កង ឱម (២០២០) *ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា*។ ក្រសួងអយក។

ក្រសួងអប់រំ យុវជន និងកីឡា (២០១០) *ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១២) *គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) *បញ្ញត្តិនៃការធានាគុណភាពអប់រំ កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *ឧបករណ៍វាយតម្លៃនាយក នាយិកាសាលារៀនល្អ* ជាឧបសម្ព័ន្ធទី១ នៃប្រកាសលេខ៧៦១ អយក,ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ*។ ភ្នំពេញ។ អយក។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ការអប់រំនៅប្រទេសកម្ពុជា៖ លទ្ធផលពីការចូលរួមរបស់ប្រទេសកម្ពុជា ក្នុងកម្មវិធីអន្តរជាតិស្តីពីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (ESP 2019-2023)*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ២០៣០ "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤"*។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *សន្និបាតអប់រំ ឆ្នាំសិក្សា២០១៧-២០១៨ ទិសដៅឆ្នាំសិក្សា ២០១៨-២០១៩* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា - គ.ទ.ក. (២០១៩) *សៀវភៅណែនាំស្តីពី ការអនុវត្តស្តង់ដាជាតិនិង និទ្ទេសបទសម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា* ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ក្របខណ្ឌ និងផែនការសកម្មភាព ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជា ប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២០) *ប្រកាសលេខ២៩៥៤ អយក.ប្រក ស្តីពីគោលការណ៍ និងយន្តការ ការងារគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០២០-២០២១* ។ ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២២) *ផែនការមេស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ ២០២២-២០២៨* ។ ភ្នំពេញ។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (២០២២) *ប្រកាសលេខ ១១៧ MISTI/ ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌ស្រាវជ្រាវ* ។ ភ្នំពេញ។

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (២០១៦) *សៀវភៅណែនាំ ស្តីពី ដំណើរការនៃការ ទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា* ។ ក្រសួងអយក។ ភ្នំពេញ។

ចាន់ សុខុម (២០២១) *វិធីសាស្ត្រស្រាវជ្រាវអប់រំ* ។ មជ្ឈមណ្ឌលអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍ (ERIC)។

ចាន់ សុភាព, ឈាង សង្វាត, សៀង វាសនា (២០២១) និក្ខេបបទស្តីពី *គំរូនៃភាពជាអ្នកដឹកនាំគ្រប់គ្រង សាលារៀនរបស់នាយកមធ្យមសិក្សាទុតិយភូមិក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាក្នុង ខេត្តបន្ទាយមានជ័យ*។ វិទ្យាស្ថានជាតិអប់រំ។ ភ្នំពេញ។

ឆយ អូន (១៩៩៨) *ប្រវត្តិក្រសួងអប់រំ យុវជន និងកីឡា (ផ្នែកទី២)*។ នាយកដ្ឋានបុគ្គលិក។

ឈុំ សារ៉ាត់, សៀង សុវណ្ណា, ចាប រតនា, នួវ រីាំ, ជ័យ សារិន (២០១៨) សារណាស្តីពី *ឥទ្ធិពលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាទៅលើការបំពេញភារកិច្ចរបស់គ្រូបង្រៀន*។ វិទ្យាស្ថានជាតិអប់រំ។ ភ្នំពេញ។

ជា តត, សិត សេង, លឹម វ៉ាន់ (២០១៩) និក្ខេបបទស្តីពី *កម្រិតនៃការជួយសិស្សរៀនយឺតនៅបឋមសិក្សាករណីសិក្សា៖ ខេត្តតាកែវ*។ វិទ្យាស្ថានជាតិអប់រំ។ ភ្នំពេញ។

ជាង ចាន់ណាក់, ឈាង សង្វាត, សៀង វាសនា (២០២០) និក្ខេបបទ *ផលប៉ះពាល់នៃដំណើរការអនុវត្តគោលនយោបាយ ស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ*។ វិទ្យាស្ថានជាតិអប់រំ។ ភ្នំពេញ។

ជួន ណាត *វចនានុក្រមខ្មែរ (ភាគទី១ ភាគទី២)* ។ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១២ គ.ស. ១៩៦៨ ។ ភ្នំពេញ។

ឈាង សង្វាត (២០២១) *វិធីសាស្ត្រស្រាវជ្រាវអប់រំ* ។ វិទ្យាស្ថានជាតិអប់រំ (NIE)។ ភ្នំពេញ។

ឌី សមស៊ីដេត (២០១៦) *ឯកសារបង្ហាញស្តីពីផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន (TPAP)* ។ ក្រសួងអប់រំ យុវជន និងកីឡា។ វិទ្យាស្ថានជាតិបច្ចេកវិទ្យា (សន្និបាតអប់រំ ២០១៦)។

ណាត ប៊ុនរឿន - លឹម ប៉េង (១៩៩៧) *ក្រមសីលធម៌វិជ្ជាជីវៈ* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។ ក្រសួងអយក។ ភ្នំពេញ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០១០) *ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន* ។ ក្រសួងអយក។ ភ្នំពេញ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០១៥) *គោលនយោបាយស្តីពីគ្រូបង្រៀន* ។ ក្រសួងអយក។ ភ្នំពេញ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០១៦) *ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន* ។ ក្រសួងអយក។ ភ្នំពេញ។

ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ (២០០៧) *ច្បាប់ ស្តីពីការអប់រំ* ។ ប្រទេសកម្ពុជា។

យូណេស្កូ UNESCO (២០១៥) *វិស័យអប់រំឆ្នាំ២០៣០ (សេចក្តីប្រកាសទីក្រុងអ៊ីនឈុន (Incheon) ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា)* ឯកសារបកប្រែពីភាសាអង់គ្លេស និងត្រូវបានផ្ទៀងផ្ទាត់ដោយក្រុមការងារអង្គការភាពជាដៃគូអប់រំក្រៅរាជដ្ឋាភិបាល (NEP)។ សេចក្តីប្រកាសទីក្រុងអ៊ីនឈុន។

យូណេស្កូ UNESCO (២០២២) *ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព៖ ផែនទីបង្ហាញផ្លូវ (ESD For 2030)* ។

រាជរដ្ឋាភិបាលកម្ពុជា (២០១៤) *ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា* ។ ប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០១៤) អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ *ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា* ។ ប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤* ។ ប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) *គោលនយោបាយជាតិ ស្តីពីការសិក្សាពេញមួយជីវិត* ។ ក្រសួងអយក។ ប្រទេសកម្ពុជា។

វីអេសអូ VSO, យូណេស្កូ, NEP (២០១៤) *សិទ្ធិទទួលបានការអប់រំនៅកម្ពុជា* ។

សាម អ៊ីន (ប្រែសម្រួលចេញពីអត្ថបទដើម ខែមីនា ២០២១) *ភាពជាអ្នកដឹកនាំ៥កម្រិត* ។

សិត សេង (២០២១) *កំណែទម្រង់ការអប់រំគ្រូបង្រៀនឆ្ពោះទៅគុណសម្បទាសតវត្សទី២១* ។ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC)។ ភ្នំពេញ។

សុខ សិរី (២០២១) *វិធីសាស្ត្រស្រាវជ្រាវអប់រំ* ។ NIE RUPP

សៀង សុវណ្ណា (២០២១) *កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា* ។ វិទ្យាស្ថានជាតិអប់រំ (NIE)។

ហង់ជួន ណារ៉ុន (២០១៦) *កំណែទម្រង់វិស័យអប់រំនៅកម្ពុជា* ។ ភ្នំពេញ។

ហង់ជួន ណារ៉ុន (២០២០) - *បាឋកថាស្តីពី កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន* ក្រសួងអយក។ ភ្នំពេញ។

ហង់ជួន ណារ៉ុន (២០២០) *កំណែទម្រង់សាលារៀននៅកម្ពុជា School Reform in Cambodia* ។ ក្រសួងអយក។ ភ្នំពេញ។ ទំព័រ៣២៩

ហង់ជួន ណារ៉ុន (២០២០) *កំណែទម្រង់សាលារៀននៅកម្ពុជា* ។ ក្រសួងអយក។ ភ្នំពេញ។

ហង់ជួន ណារ៉ុន (២០២២) *បាឋកថា ស្តីពីការសម្រេចអាទិភាពកំណែទម្រង់វិស័យអប់រំតាមរយៈការគ្រប់គ្រងផ្អែកលើលទ្ធផលដើម្បីកសាងមូលធនមនុស្សនៅកម្ពុជា* ។ ក្រសួងអយក។ ភ្នំពេញ។

ហង់ជួន ណារ៉ុន (២០២២) *សុន្ទរកថាថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២០-២០២១ និងលើកទិសដៅឆ្នាំសិក្សា២០២១-២០២២* ។ ក្រសួងអយក។ ភ្នំពេញ។

អាស៊ាន (២០១៦) *គោលការណ៍ណែនាំអាស៊ាន ស្តីពីការការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវឌ្ឍិសមត្ថភាព* ។ ទីក្រុងហ្សាកាតា។

អាស៊ាន (២០១៨) *រដ្ឋធម្មនុញ្ញអាស៊ាន (The ASEAN Charter)* ។

អ៊ឹម សានី - ឌី ប៊ុណ្ណា - សៀង សុវណ្ណា (២០២១) និក្ខេបបទស្តីពី *ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ*។ វិទ្យាស្ថានជាតិអប់រំ។ ភ្នំពេញ។

## ២. ឯកសារជាភាសាអង់គ្លេស

ASEAN UNIVERSITY NEWORK (2015). *Guide-to-AUN-QA-Assessment-at-Programme-Level-Version-3*

ASEAN UNIVERSITY NEWORK QUALITY ASSURANCE. *MANUAL FOR THE IMPLEMENTATION OF THE GUIDELINES.*

Chet, C., Sok, S., Vong, C. and Sok, V. (2021) *The use of a tracer study to advance the undergraduate program at the Royal University of Phnom Penh.* Cambodia Journal of Basic and Applied Research (CJBAR), 3(2), 14–31.

Dy, S. S. (2017). *A roadmap for teacher policy development in Cambodia: learning from international experience and application and good practice.* Cambodia Education Review, 1(1), 69-94.

John C. Maxwell (2011). *The 5 levels of Leadership*.

Khieng Sothy, Srinivasa Madhur and Chhem Rethy, eds. 2015. *Cambodia Education 2015: Employment and Empowerment*. Phnom Penh: CDRI.

Laura M. Desimone (2009) *Improving Impact Studies of Teachers' Professional Development: Toward Better Conceptualizations and Measures*. Education & Human Development.

Matin M. Chemers (1997) *Leadership Change and Organizational Effectiveness*.

MoEYS (2015). *Teacher Policy Action Plan (TPAP)*.

MoEYS (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development*. Phnom Penh: Author.

MoEYS (2018) *K-12 Student Learning Assessment Framework*. MoEYS.

MoEYS (2019) *Continuous Professional Development Framework for Teachers and School Directors*.

MoEYS (2019) *Education Strategic Plan 2019-2023*. MoEYS.

MoEYS - ACC (2016, 2019) *Guidelines and Rubrics for National Standards for Accredition of Higher Education Institutions*.

MoEYS (2021) *Teacher Career Pathway Framework*.

MoEYS (2022) *Sakura Science Ex-change Program on "Science and Technology Experience Course"*. (No: 326 MoEYS/Adm).

Phanna Kov (2022) *THE EDUCATION SYSTEMS IN CAMBODIA AND THAILAND: A COMPARATIVE PERSPECTIVE*. Cambodian Education Forum. Phnom Penh, Cambodia

RUPP (2020) *Guideline for Internal Quality Assurance Assessment*. Quality Assurance Office, 5th Floor, Building A. Royal University of Phnom Penh. Russian Federation Boulevard, Toul Kork, Phnom Penh. www.rupp.edu.kh

Sokhom Chan (2014) *DELEVEOPMENT OF INTERNAL QUALITY ASSURANCE INDICATORS OF FACULTY OF EDUCATION IN CAMBODIA*. Chulalongkorn University. Thailand

Sot, V., Sok, S., and Dickinson, G. (2019). *Four Decades of Teacher Development: Teacher Preparation and Teacher Upgrading Programs in Cambodia from 1979 to 2018*. Cambodia Education Review, 3(1), 115–139.

The ET2020 Working Group (2018). *Quality Assurances for school development* (Second edition April 2018). p.3

United Nations Institute for Training and Research (2017) *Quality Assurance Framework*.

Vagias, Wade M. (2006). *Likert-type scale response anchors*. Clemson International Institute for Tourism & Research Development, Department of Parks, Recreation and Tourism Management. Clemson University.

Yvonne Hodgson (2012) *Lessons Learned in Implementing Peer-Assisted Learning*.

Zita Mohd Fahmi (2015). *Development in ASEAN Quality Assuring Qualifications – Challenges*. Sarkaya University, Sarkaya Turkey. M ALAYSIAN QUALIFICATIONS AGENCY.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី 1៖ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

(**កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង**)

**កម្រងសំណួរសម្រាប់ស្រាវជ្រាវ**
**ប្រធានបទ**
**ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ**
**នៅខេត្តសៀមរាប**

**សូមគោរពជូន**
**លោកនាយកនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**

ខ្ញុំបាទឈ្មោះ **ម៉ៃ ខែង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទក្រោមប្រធានបទ "**ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប**" ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សិត សេង** គ្រូដឹកនាំគោល និង**លោកបណ្ឌិត នូវ វីរ៉ា** គ្រូដឹកនាំរង ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ ដើម្បីឈ្វេងយល់ពីស្ថានភាពនៃការធានាគុណភាពអប់រំ និងបង្ហាញឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប។

ទិន្នន័យដែលប្រមូលបាននេះ សម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ទិន្នន័យជាក់លាក់ដែលប្រមូលបានពីលោក លោកស្រី ជាបុគ្គលិកអប់រំ មានគោលបំណងយកទៅប្រើប្រាស់ក្នុងសិក្សាស្រាវជ្រាវការវិភាគ ឆ្លើយតបនឹងប្រធានបទខាងលើ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក លោកស្រី ក្នុងការបំពេញកម្រងសំណួរទាំងនេះ ទោះបីជាមានការមមាញឹកក្នុងការងារ។ ចម្លើយរបស់លោក លោកស្រី នឹងត្រូវបានរក្សាសម្ងាត់ និងយកមកប្រើសម្រាប់តែការស្រាវជ្រាវតែប៉ុណ្ណោះ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមលោក លោកស្រី មេត្តាគូសសញ្ញា (✓) ដាក់ក្នុងប្រអប់ □ ដែលត្រូវនឹងស្ថានភាពទូទៅរបស់លោក លោកស្រី (សូមគូសតែចម្លើយមួយគត់) ដូចខាងក្រោម៖

**១. ភេទ៖**

□ក. ប្រុស □ខ. ស្រី

**២. អាយុ៖**

□ក. ២០-៣០ឆ្នាំ □ខ. ៣១-៤០ឆ្នាំ □គ. ៤១-៥០ឆ្នាំ □ឃ. លើស៥០ឆ្នាំ

**៣. កម្រិតវប្បធម៌៖**

□ក. ទាបជាងបរិញ្ញាបត្រ □ខ. បរិញ្ញាបត្រ □គ. បរិញ្ញាបត្រជាន់ខ្ពស់

□ឃ. ខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់

**៤. បទពិសោធន៍ការងារ៖**

□ក. ១-៥ឆ្នាំ □ខ. ៦-១០ឆ្នាំ □គ. ១១-១៥ ឆ្នាំ □ឃ. ១៦-២០ឆ្នាំ □ង. លើសពី២០ឆ្នាំ

**ជាគណៈគ្រប់គ្រង៖**

□ក. ១-៥ឆ្នាំ □ខ. ៦-១០ឆ្នាំ □គ. ១១-១៥ ឆ្នាំ □ឃ. ១៦-២០ឆ្នាំ □ង. លើសពី២០ឆ្នាំ

**៥. មុខវិជ្ជាឯកទេស៖**....................................................................................................

**៦. កំពុងបង្រៀនគរុសិស្សឆ្នាំទី៖**................ **បង្រៀនមុខវិជ្ជា៖**......................................................

**ផ្នែកទី២៖ ស្ថានភាពនៃការធានាគុណភាពអប់រំ**

**ការណែនាំ៖** ការធានាគុណភាពអប់រំ ការលើកកម្ពស់គុណភាពអប់រំ ការធានានិរន្តរភាព ការទទួលស្គាល់គុណភាពអប់រំកាន់តែសុក្រឹត យុត្តិធម៌ និងអាចទទួលយកបានតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំទាំង៩ (ACC, 2016, 2019) គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ច និងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវាគរុសិស្ស/និស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨) ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

សូមលោក លោកស្រី អានឃ្លាខាងក្រោមឱ្យបានច្បាស់ ជ្រើសរើសកម្រិតអត្រាពិន្ទុលើសូចនាករដែលលោក លោកស្រីយល់ឃើញត្រូវនឹងស្ថានភាពបច្ចុប្បន្នតាមកម្រិតអត្រាពិន្ទុចង្អុលបង្ហាញ រួចគូសសញ្ញា (✓) ដាក់ក្នុងប្រអប់ □ ដូចខាងក្រោម៖

**កម្រិតអត្រាពិន្ទុ៖**

៥ = បានអនុវត្តសូចនាករពេញលេញតាមតម្រូវការ

៤ = បានអនុវត្តសូចនាករស្ទើតែពេញលេញតាមតម្រូវការ

៣ = បានអនុវត្តសូចនាករជាមធ្យម ឬ លើសពីកម្រិតមធ្យម ធៀបនឹងតាមតម្រូវការ

២ = បានអនុវត្តសូចនាករក្រោមមធ្យម ធៀបនឹងតាមតម្រូវការ

១ = បានអនុវត្តសូចនាករបានបន្តិចបន្តួចតាមតម្រូវការ

| ល.រ | សូចនាករនីមួយៗ | កម្រិតអត្រាពិន្ទុ | | | | |
|---|---|---|---|---|---|---|
| **ស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ចក្ខុវិស័យ បេសកកម្ម និងគោលបំណងមានការឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដោយរួមបញ្ចូលទាំងកិច្ចការពារ និងថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | សាលា ពិនិត្យ កែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង ក្នុងអំឡុងពេលមួយទៀងទាត់ ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍសាលា។ | | | | | |
| ៣ | សាលា ផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងគោលបំណង បានទូលំទូលាយដល់ភាគីពាក់ព័ន្ធតាមរយៈការបោះពុម្ព និងគេហទំព័ររបស់សាលា។ | | | | | |
| **ស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា មានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា។ | | | | | |
| ២ | សាលា កំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមអភិបាលច្បាស់លាស់ដោយអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធ។ | | | | | |
| ៣ | ផែនការការអភិវឌ្ឍន៍របស់សាលាមានសង្គតិភាពជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។ | | | | | |
| ៤ | បុគ្គលិករដ្ឋបាល មានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍ ស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ | | | | | |
| ៥ | តួនាទី និង ភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដាច់ដោយឡែកពីតួនាទី និងភារកិច្ច នៃកិច្ចការរដ្ឋបាល។ | | | | | |
| ៦ | ក្រុមប្រឹក្សាភិបាល វាយតម្លៃប្រសិទ្ធភាពនៃការងាររបស់ខ្លួនដោយទៀងទាត់។ | | | | | |
| **ស្តង់ដា៣៖ បុគ្គលិកអប់រំ** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | គុណវុឌ្ឍិ បទពិសោធន៍ និងការបណ្តុះបណ្តាលរបស់គ្រូឧទ្ទេសពេញម៉ោង និងវេលាការ ស្របនឹងជំនាញ និងកម្រិតបណ្តុះបណ្តាលដែលត្រូវបង្រៀនស្របតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន។ | | | | | |
| ២ | គ្រូឧទ្ទេសបង្រៀនពេញម៉ោងមានចំនួនគ្រប់គ្រាន់ ដើម្បីធានាប្រសិទ្ធភាពនៃការបង្រៀន និងណែនាំគរុសិស្ស។ | | | | | |
| ៣ | សាលា មានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកគ្រូឧទ្ទេស និងបុគ្គលិក។ | | | | | |
| ៤ | សាលា មានការរក្សាទុកឯកសាររបស់គ្រូឧទ្ទេសពេញម៉ោង វេលាការ និងបុគ្គលិកត្រឹមត្រូវ។ | | | | | |
| ៥ | សាលា ផ្តល់ប្រាក់បៀវត្ស និងផលប្រយោជន៍នានាសម្រាប់ទាក់ទាញ និងរក្សាគ្រូឧទ្ទេសដែលមានសមត្ថភាពខ្ពស់ឱ្យនៅបម្រើការក្នុងសាលា។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | សាលា មានបញ្ញប់ថវិកាសមរម្យសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូឧទ្ទេស និងបុគ្គលិក។ | | | | | |
| ៧ | សាលា កំណត់ទំហំការងារដល់គ្រូឧទ្ទេសសមល្មម ស្របតាមការទទួលខុសត្រូវក្នុងការបង្រៀន ការផ្តល់ប្រឹក្សា ការស្រាវជ្រាវ និង/ឬកិច្ចការក្នុងគណៈកម្មការនានា។ | | | | | |
| ៨ | ការវាយតម្លៃប្រចាំឆ្នាំលើការបំពេញការងាររបស់បុគ្គលិកអប់រំពេញម៉ោង និងវេលាការធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ។ | | | | | |
| ៩ | យោបល់កែលម្អពីការវាយតម្លៃត្រូវបានផ្តល់ដល់សាមីខ្លួន និងមានការពិភាក្សារវាងភាគីសងខាង។ | | | | | |
| ១០ | សាលា មានយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការស្រាវជ្រាវ និងសកម្មភាពសិក្សា ស្របតាមបេសកកម្មរបស់សាលា ហើយមានយុទ្ធសាស្ត្រនេះអភិវឌ្ឍឡើងដោយមានការចូលរួមពីគ្រូឧទ្ទេស និងសមាជិកពាក់ព័ន្ធ។ | | | | | |
| ១១ | សាលា ផ្តល់ការណែនាំច្បាស់លាស់ដល់បុគ្គលិក និងគ្រូឧទ្ទេស អំពីគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីក្នុងការគាំទ្រដល់ការស្រាវជ្រាវ និងសកម្មភាពសិក្សា។ | | | | | |
| **ស្តង់ដា៤៖ កម្មវិធីអប់រំ** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា មានគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ | | | | | |
| ២ | កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម។ | | | | | |
| ៣ | មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានប្លង់មេរៀនលម្អិតច្បាស់លាស់ដោយផ្អែកលើសៀវភៅសិក្សាគោល សៀវភៅយោង គេហទំព័រ ឯកសារសិក្សា និងបង្រៀនផ្សេងៗ។ | | | | | |
| ៤ | សាលា មានយន្តការកំណត់ចំនួនក្រេឌីតសិក្សា និងគោលការណ៍នៃការផ្ទេរក្រេឌីតសមស្របតាមបទបញ្ញត្តិជាធរមាន។ | | | | | |
| ៥ | គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុសិស្សដោយបញ្ជាក់ពីចំណេះដឹង ជំនាញ និង/ឬ អាកប្បកិរិយាដែលគរុសិស្សនឹងទទួលបាន។ | | | | | |
| ៦ | សាលា ប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុសិស្សដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | សាលា ពិនិត្យ និងកែលម្អកម្មវិធីសិក្សាអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ | | | | | |
| **ស្តង់ដា៥៖ សេវាគរុសិស្ស/និស្សិត** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | គោលនយោបាយ ឬ គោលការណ៍ ស្តីពីការជ្រើសរើសគរុសិស្សចូលរៀន បានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ។ | | | | | |
| ២ | អ្នកគ្រប់គ្រង និងបុគ្គលិក ប្រតិបត្តិត្រូវមានគុណវុឌ្ឍិ និងបទពិសោធន៍ និងមានកំណត់តួនាទី ភារកិច្ចច្បាស់លាស់។ | | | | | |
| ៣ | សាលា ផ្តល់សេវាប្រឹក្សា សេវាសុខភាព និងកម្មវិធីអប់រំសុខភាពស្របតាមតម្រូវការជាក់ស្តែង។ | | | | | |
| ៤ | សាលា មានគោលនយោបាយ ឬគោលការណ៍ ស្តីពីអាហារូបករណ៍ដោយមានចែងលក្ខខណ្ឌច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ។ | | | | | |
| ៥ | គរុសិស្សចូលរៀនថ្មី នៅគ្រប់សញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិសពេញលេញ។ | | | | | |
| ៦ | សាលា បង្កើត និងធានាដំណើរការប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់។ | | | | | |
| ៧ | សាលា មានគោលនយោបាយអំពីការផ្ទេរក្រេឌីត និងអនុវត្តបានត្រឹមត្រូវ។ | | | | | |
| ៨ | គរុសិស្សទទួលបានឱកាសក្នុងការចូលរួមសកម្មភាពបន្ថែមលើការសិក្សា និងកម្មវិធីហ្វឹកហាត់ការងារ។ | | | | | |
| ៩ | សាលា ជួយគរុសិស្សក្នុងការធ្វើផែនការអភិវឌ្ឍអាជីព និងជួយរកការងារឱ្យគរុសិស្ស ព្រមទាំងតាមដានលទ្ធផលការងាររបស់គរុសិស្ស។ | | | | | |
| ១០ | សាលា ត្រូវធ្វើការស្រាវជ្រាវអំពីលទ្ធផល និងភាពជោគជ័យក្នុងការទទួលបានរបស់គរុសិស្សដែលបានបញ្ចប់ការសិក្សា។ | | | | | |
| ១១ | គរុសិស្សទទួលបានឱកាសចូលរួមក្នុងសេវាជួយសហគមន៍ និងសកម្មភាពជួយសង្គមផ្សេងៗ។ | | | | | |
| ១២ | សាលា មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយរាល់បណ្តឹងតវ៉ារបស់គរុសិស្ស។ | | | | | |
| ១៣ | សាលា មានគោលនយោបាយ ឬគោលការណ៍ ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សាគរុសិស្ស និងអត្រាបញ្ចប់ការសិក្សា។ | | | | | |

| ស្តង់ដា៦៖ ធនធានសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|---|
| ១ | បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផល ដល់ការសិក្សា និងស្រាវជ្រាវ។ | | | | | |
| ២ | បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្ដីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗ។ | | | | | |
| ៣ | បណ្ណាល័យមានបណ្ណារក្ស និងបុគ្គលិកបម្រើការគ្រប់គ្រាន់ និង ទទួលបានការបណ្ដុះបណ្ដាលផ្នែកគ្រប់គ្រងបណ្ណាល័យ ហើយមាន សមត្ថភាព បម្រើតម្រូវការរបស់គរុសិស្ស និងគ្រូឧទ្ទេស។ | | | | | |
| ៤ | ចំនួនម៉ោងបើកបម្រើសេវារបស់បណ្ណាល័យស្របទៅនឹងតម្រូវការ របស់គរុសិស្ស និងគ្រូឧទ្ទេស។ | | | | | |
| ៥ | គរុសិស្ស និងគ្រូឧទ្ទេសទទួលបានការណែនាំ និងតម្រង់ទិសអំពី របៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ | | | | | |
| ៦ | គរុសិស្ស និងគ្រូឧទ្ទេសទទួលបានឱកាសក្នុងការប្រើប្រាស់ធនធាន សិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូនិម្មិតសម្រាប់បំពេញការងារសិក្សា និងស្រាវជ្រាវ ស្របតាមកម្មវិធីអប់រំ។ | | | | | |
| ៧ | បណ្ណាល័យមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រផែនការរយៈពេលវែង និងរយៈពេលខ្លី ដើម្បីអភិវឌ្ឍន៍បណ្ណាល័យឱ្យកាន់តែប្រសើរឡើង។ | | | | | |
| ៨ | សាលា មានបន្ទប់ពិសោធន៍ទូទៅ និងឯកទេស ប្រដាប់ដោយបរិក្ខារ ពេញលេញ សម្រាប់គាំទ្រដល់ការបង្រៀន ការសិក្សា និងការ ស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។ | | | | | |
| ៩ | សាលា មានផែនការអភិវឌ្ឍ បន្ទប់ពិសោធន៍ រយៈពេលវែង និងខ្លី។ | | | | | |
| ១០ | សាលា មានបុគ្គលិកដែលបានឆ្លងកាត់ការបណ្ដុះបណ្ដាលត្រឹមត្រូវ និងមានចំនួនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការ និងដំណើរការរបស់ បន្ទប់ពិសោធន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងការសិក្សា។ | | | | | |
| ១១ | សាលា មានគោលនយោបាយ ឬគោលការណ៍ អំពីសុវត្ថិភាព និង អនុវត្តប្រកបដោយប្រសិទ្ធភាព។ | | | | | |
| ១២ | សាលា មានធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិតគ្រប់គ្រាន់សម្រាប់ គាំទ្រការសិក្សា ដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើ តម្រូវការទូទៅ និងឯកទេស ដើម្បីបំពេញតម្រូវការតាមកម្មវិធីអប់រំ។ | | | | | |
| ១៣ | សាលា ផ្ដល់វគ្គបណ្ដុះបណ្ដាលសមស្របអំពីការប្រើប្រាស់ធនធាន បច្ចេកវិទ្យា ដែលមាននៅក្នុងគ្រឹះស្ថានដល់គ្រូឧទ្ទេស បុគ្គលិក និង គរុសិស្ស។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤ | សាលា មានបុគ្គលិក ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់គាំទ្រ និងជួយសម្រួលផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា។ | | | | | |
| **ស្តង់ដា៧៖ ធនធានរូបវន្ត** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា មានធនធានរូបវន្តគ្រប់គ្រាន់សម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំនិងសកម្មភាពផ្សេងៗរួមទាំងសកម្មភាពសិក្សារបស់គរុសិស្សដែលកំពុងសិក្សាបច្ចុប្បន្ន។ | | | | | |
| ២ | សាលា មានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព។ | | | | | |
| ៣ | បទបញ្ជា និង/សេចក្តីណែនាំស្តីពីសុខភាព សុវត្ថិភាព និងសន្តិសុខត្រូវបានផ្សព្វផ្សាយ អនុវត្ត និងវាយតម្លៃជាប្រចាំ។ | | | | | |
| ៤ | សាលា មានការសាកល្បងជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រាមានអាសន្ន។ | | | | | |
| ៥ | សាលា មានគោលនយោបាយ ឬគោលការណ៍សុវត្ថិភាព ស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធព័ត៌មានអេឡិចត្រូនិកផ្លូវការ រួមទាំងឃ្លាំងការពារអគ្គិភ័យនិងការថតចម្លងទុក។ | | | | | |
| ៦ | សាលា មានផែនការអភិវឌ្ឍន៍ធនធានរូបវន្តរយៈពេលវែងនិងខ្លី និងបានអនុវត្ត។ | | | | | |
| **ស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា បង្ហាញអំពីស្ថិរភាពហិរញ្ញវត្ថុ ដោយផ្តល់ភស្តុតាងលើភាពគ្រប់គ្រាន់នៃថវិកា ដើម្បីបំពេញតម្រូវការចំណាយលើបុគ្គលិក ប្រព័ន្ធប្រតិបត្តិការ និងដើមទុន ក្នុងការគាំទ្រដល់កម្មវិធីអប់រំរបស់សាលា។ | | | | | |
| ២ | សាលា មានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប ដែលត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំទទួលបន្ទុកជាប្រចាំ។ | | | | | |
| ៣ | សាលា រៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានពិពណ៌នាលម្អិតអំពីចំណូលនិងចំណាយតាមផ្នែក និង មានចែងអំពីថវិកាបម្រុងសម្រាប់ការចំណាយផ្សេងៗ។ | | | | | |
| ៤ | តំណាងមកផ្នែកពាក់ព័ន្ធផ្សេងៗរបស់សាលាមានឱកាសចូលរៀបចំផែនការថវិកា។ | | | | | |
| ៥ | សាលា ធ្វើសវនកម្មជាប្រចាំដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការមានឋានៈស្មើ។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | សាលា បានបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅក្រសួងអប់រំ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមកាលបរិច្ឆេទកំណត់។ | | | | | |
| **ស្តង់ដា៩៖ ការធានាគុណភាពអប់រំផ្ទៃក្នុង** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា មានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងដោយមានគោលការណ៍ណែនាំ និងនីតិវិធីច្បាស់លាស់។ | | | | | |
| ២ | ដំណើរការគុណភាពអប់រំមានការចូលរួម និងសហការពីគណៈគ្រប់គ្រង គ្រប់ជាន់ថ្នាក់រួមទាំងបុគ្គលិក គរុសិស្ស និងភាគីពាក់ព័ន្ធ។ | | | | | |
| ៣ | ប្រព័ន្ធធានាគុណភាពអប់រំប្រកាសឱ្យប្រើប្រាស់ និងទទួលបានការគាំទ្រ ពីថ្នាក់ដឹកនាំដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្ត។ | | | | | |
| ៤ | សាលា ផ្តល់ធនធានគ្រប់គ្រាន់សម្រាប់បង្កើត និងគាំទ្រប្រព័ន្ធធានាគុណភាពអប់រំប្រកបដោយប្រសិទ្ធភាព។ | | | | | |
| ៥ | លទ្ធផលស្វ័យវាយតម្លៃត្រូវបានប្រើប្រាស់ និងបញ្ចូលទៅក្នុងផែនការលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍។ | | | | | |
| ៦ | សាលា រៀបចំចងក្រងសៀវភៅស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុង។ | | | | | |

**មតិយោបល់បន្ថែម៖**

១. តើអ្នកយល់ឃើញដូចម្តេចចំពោះការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ ?

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

២. តើអ្នកយល់ឃើញដូចម្តេចចំពោះការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ?

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

**សូមអរគុណ!**

ឧបសម្ព័ន្ធទី 2៖ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស

(**កម្រងសំណួរសម្រាប់គ្រូឧទ្ទេស**)

**កម្រងសំណួរសម្រាប់ស្រាវជ្រាវ**
**ប្រធានបទ**
**ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ**
**នៅខេត្តសៀមរាប**

**សូមគោរពជូន**
**លោក លោកស្រី គ្រូឧទ្ទេសនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**

ខ្ញុំបាទឈ្មោះ **ម៉ៃ ខែង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទក្រោមប្រធានបទ "**ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប**" ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សិត សេង** គ្រូដឹកនាំគោល និង**លោកបណ្ឌិត នូវ វីរ៉ា** គ្រូដឹកនាំរង ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ ដើម្បីឈ្វេងយល់ពីស្ថានភាពនៃការជានាគុណភាពអប់រំ និងបង្ហាញឧត្តមានុវត្តនិងបញ្ហាប្រឈមក្នុងការអនុវត្តការជានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប។

ទិន្នន័យដែលប្រមូលបាននេះ សម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ទិន្នន័យជាក់លាក់ដែលប្រមូលបានពីលោក លោកស្រី ជាបុគ្គលិកអប់រំ មានគោលបំណងយកទៅប្រើប្រាស់ក្នុងសិក្សាស្រាវជ្រាវការវិភាគ ឆ្លើយតបនឹងប្រធានបទខាងលើ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក លោកស្រី ក្នុងការបំពេញកម្រងសំណួរទាំងនេះ ទោះបីជាមានការមមាញឹកក្នុងការងារ។ ចម្លើយរបស់លោក លោកស្រី នឹងត្រូវបានរក្សាសម្ងាត់ និងយកមកប្រើសម្រាប់តែការស្រាវជ្រាវតែប៉ុណ្ណោះ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមលោក លោកស្រី មេត្តាគូសសញ្ញា (✓) ដាក់ក្នុងប្រអប់ □ ដែលត្រូវនឹងស្ថានភាពទូទៅរបស់លោក លោកស្រី (សូមគូសតែចម្លើយមួយគត់) ដូចខាងក្រោម៖

**១. ភេទ៖**

□ក. ប្រុស □ខ. ស្រី

**២. អាយុ៖**

□ក. ២០-៣០ឆ្នាំ □ខ. ៣១-៤០ឆ្នាំ □គ. ៤១-៥០ឆ្នាំ □ឃ. លើស៥០ឆ្នាំ

៣. កម្រិតវប្បធម៌៖

☐ក. ទាបជាងបរិញ្ញាបត្រ ☐ខ. បរិញ្ញាបត្រ ☐គ. បរិញ្ញាបត្រជាន់ខ្ពស់

☐ឃ. ខ្ពស់ជាងបរិញ្ញាបត្រជាន់ខ្ពស់

៤. បទពិសោធន៍ការងារ៖

☐ក. ១-៥ឆ្នាំ ☐ខ. ៦-១០ឆ្នាំ ☐គ. ១១-១៥ ឆ្នាំ ☐ឃ. ១៦-២០ឆ្នាំ ☐ង. លើសពី២០ឆ្នាំ

៥. មុខវិជ្ជាឯកទេស៖..........................................................................................................

៦. កំពុងបង្រៀនគរុសិស្សឆ្នាំទី៖................ បង្រៀនមុខវិជ្ជា៖.....................................................

## ផ្នែកទី២៖ ស្ថានភាពនៃការធានាគុណភាពអប់រំ

**ការណែនាំ៖** ការធានាគុណភាពអប់រំ ការលើកកម្ពស់គុណភាពអប់រំ ការធានានិរន្តរភាព ការទទួលស្គាល់គុណភាពអប់រំកាន់តែសុក្រឹត យុត្តិធម៌ និងអាចទទួលយកបានតាមស្តង់ដាជាតិនៃការធានាគុណភាពអប់រំទាំង៩ (ACC, 2016, 2019) គឺ៖ (១) ចក្ខុវិស័យ បេសកកម្ម និងគោលដៅ (២) អភិបាលកិច្ចនិងការគ្រប់គ្រង (៣) បុគ្គលិកអប់រំ (៤) កម្មវិធីអប់រំ (៥) សេវាគរុសិស្ស/និស្សិត (៦) ធនធានសិក្សា (៧) ធនធានរូបវន្ត (៨) ធនធានហិរញ្ញវត្ថុ (៩) ការធានាគុណភាពអប់រំផ្ទៃក្នុង។

សូមលោក លោកស្រី អានឃ្លាខាងក្រោមឱ្យបានច្បាស់ ជ្រើសរើសកម្រិតអត្រាពិន្ទុលើសូចនាករដែលលោក លោកស្រីយល់ឃើញត្រូវនឹងស្ថានភាពបច្ចុប្បន្នតាមកម្រិតអត្រាពិន្ទុចង្អុលបង្ហាញ រួចគូសសញ្ញា (✓) ដាក់ក្នុងប្រអប់ ☐ ដូចខាងក្រោម៖

**កម្រិតអត្រាពិន្ទុ៖**

**៥** = បានអនុវត្តសូចនាករពេញលេញតាមតម្រូវការ

**៤** = បានអនុវត្តសូចនាករស្ទើតែពេញលេញតាមតម្រូវការ

**៣** = បានអនុវត្តសូចនាករជាមធ្យម ឬ លើសពីកម្រិតមធ្យម ធៀបនឹងតាមតម្រូវការ

**២** = បានអនុវត្តសូចនាករក្រោមមធ្យម ធៀបនឹងតាមតម្រូវការ

**១** = បានអនុវត្តសូចនាករបានបន្តិចបន្តួចតាមតម្រូវការ

| ល.រ | សូចនាករនីមួយៗ | កម្រិតអត្រាពិន្ទុ | | | | |
|---|---|---|---|---|---|---|
| **ស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ចក្ខុវិស័យ បេសកកម្ម និងគោលបំណងមានការឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដោយរួមបញ្ចូលទាំងកិច្ចការពារ និងថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | សាលា ពិនិត្យ កែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលបំណង ក្នុងអំឡុងពេលមួយទៀងទាត់ ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍសាលា។ | | | | | |
| ៣ | សាលា ផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងគោលបំណង បានទូលំទូលាយដល់ភាគីពាក់ព័ន្ធតាមរយៈការបោះពុម្ព និងគេហទំព័ររបស់សាលា។ | | | | | |
| **ស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | សាលា មានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាចនិងទំនាក់ទំនងការងារក្នុងសាលា។ | | | | | |
| ២ | សាលា កំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមអភិបាលច្បាស់លាស់ដោយអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធ។ | | | | | |
| ៦ | លោក ណាំ ពៅ | ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងដំណើរការបង្រៀន និងរៀននៅមធ្យមសិក្សាបឋមភូមិក្នុងស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ | |

**ក្រុមទី១០**

| ល.រ | គោត្តនាម-នាម | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | ផ្សេងៗ |
|---|---|---|---|
| ១ | លោក ម៉ូញ ណុយ | ស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំ នៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | |
| ២ | លោក សួន សារុនឡឿន | ការពិសោធមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យធនធាន( ករណីសិក្សាក្នុងខេត្តស្វាយរៀង) | |
| ៣ | លោក ហៀង ណេន | ការរួមបញ្ចូលភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា ក្នុងខេត្តកំពង់ចាម | |
| ៤ | លោកស្រី ហេង សុគន្ធារី | កត្តាជះឥទ្ធិពលគម្លាតយេនឌ័រក្នុងការអប់រំស្ទែមនៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | |
| ៥ | លោក ជិប ឌីន | ស្ថានភាពនៃការអនុវត្តកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ក្នុងខេត្តកំពង់ធំ | |

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**បានឃើញ និងឯកភាព**

ជ. **ប្រធានគណៈកម្មាធិការកំណែទម្រង់**

អនុប្រធាន

**បណ្ឌិត ឈូក ច័ន្ទឆាយា**

**កន្លែងទទួល៖**

- ការិយាល័យ/ដេប៉ាតឺម៉ង់នៃវ.ជ.អ.ដែលពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វ.ជ.អ.

## ឧបសម្ព័ន្ធទី ៩៖ សេចក្តីជូនដំណឹង ស្តីពីការប្រគល់សេចក្តីព្រាងនិក្ខេបបទលើកទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :......[illegible]..........វជអ.

**សេចក្តីជូនដំណឹង**
**ស្តីពី ការប្រគល់សេចក្តីព្រាងនិក្ខេបបទលើកទី១**
**របស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

យោង៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ស្តីពីវឌ្ឍនភាពនិក្ខេបបទ និងការការពារបញ្ចប់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។

វិទ្យាស្ថានជាតិអប់រំ សូមជូនដំណឹងដល់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ដែលកំពុងបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំទាំងអស់ជ្រាបថា៖ ការការពារសាកល្បងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពីម៉ោង០៨:០០ – ១៧:០០រសៀលនៅ អគារH បន្ទប់ប្រជុំជាន់ទី១ ។ ហេតុដូចនេះ និស្សិតទាំងអស់ត្រូវប្រគល់សេចក្តីព្រាងនិក្ខេបបទស្រាវជ្រាវលើកទី១( soft copy, hard copy) និងលិខិតបញ្ជាក់ពីគ្រូដឹកនាំបង្គោល គ្រូដឹកនាំរងអនុញ្ញាតឱ្យការពារសាកល្បង និងពាក្យសុំការពារបញ្ចប់ មកដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការយ៉ាងយូរត្រឹមថ្ងៃអាទិត្យទី១៩ ខែកញ្ញា ឆ្នាំ២០២២ ម៉ោង១៧:០០នាទីរសៀលជាកំហិត ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមនិស្សិតទាំងអស់ប្រគល់សេចក្តីព្រាងនិក្ខេបបទស្រាវជ្រាវលើកទី១ និងលិខិតបញ្ជាក់ពីលោកគ្រូដឹកនាំបង្គោល និងដឹកនាំរងអនុញ្ញាត្តិឱ្យការពារសាកល្បង និងពាក្យសុំការពារបញ្ចប់តាមកាលកំណត់ខាងលើ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២

ឧបសម្ព័ន្ធទី 10៖ កម្មវិធីបណ្ដុះបណ្ដាល និងកាលបរិច្ឆេទការពារបញ្ចប់វគ្គសិក្សា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :.....✓..........ខជអ.**

**កម្មវិធីបណ្ដុះបណ្ដាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**
**ជំនាន់ទី៩ ស្ដីពីវឌ្ឍនភាពនិក្ខេបបទ និងការការពារបញ្ចប់វគ្គសិក្សា**

| **លរ** | **ចំណងជើង** | **កាលបរិច្ឆេទ** | **ថ្ងៃកំណត់** |
|---|---|---|---|
| ១ | ការពារសំណើប្រធានបទស្រាវជ្រាវ | ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ២ | សេចក្ដីផ្ដើម | ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ៣ | រំលឹកទ្រឹស្ដី | ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ៤ | វិធីសាស្ត្រស្រាវជ្រាវ និងការប្រមូលទិន្នន័យ | ខែឧសភា ដល់ កក្កដា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ៥ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការពិភាក្សា | ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ៦ | សេចក្ដីសន្និដ្ឋាន និងសំណូមពរ | ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ | ថ្ងៃសៅរ៍ |
| ៧ | ការពារនិក្ខេបបទសាកល្បង | ចាប់ពីថ្ងៃទី០១-០២ ខែតុលា ឆ្នាំ២០២២ | |
| ៨ | ការទទួលនិក្ខេបបទ សម្រាប់ការពារបញ្ចប់ | ចាប់ពីថ្ងៃទី០៣-០៨ ខែតុលា ឆ្នាំ២០២២ | ០៨ តុលា ២០២២ (ម៉ោង១៧:00នាទី) |
| ៩ | ការការពារនិក្ខេបបទបញ្ចប់វគ្គសិក្សា | ថ្ងៃទី០៥-០៦ ខែវិច្ឆិកា ឆ្នាំ២០២២ (ពីម៉ោង៧:៣០ ដល់១៧:00នាទី) | |
| ១០ | ប្រគល់និក្ខេបបទចុងក្រោយ បន្ទាប់ពីការពារបញ្ចប់ដោយជោគជ័យ | ថ្ងៃទី២៦-៣០ ខែវិច្ឆិកា ឆ្នាំ២០២២ | ៣០ វិច្ឆិកា ២០២២ (ម៉ោង១៧:00នាទី) |

ចំណាំ៖ សូមទាក់ទងមកកាន់ដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការនៃវិទ្យាស្ថានជាតិអប់រំរាល់ចម្ងល់ផ្សេងៗស្ដីអំពីការសរសេរនិក្ខេបបទ។

ថ្ងៃ សុក្រ ៣ រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២២
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**
**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

# ឧបសម្ព័ន្ធទី 11៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ២៣៤១ អយក.វដក

**លិខិតចូល**
មកដល់ថ្ងៃទី ៣០.០៥.២០២២
លេខ ៤០៩ ក.ក

ថ្ងៃ សុក្រ ១៣កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ឧបសម្ព័ន្ធទី 12៖ លិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ជូនដំណឹងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
លេខ: ៤៩៦ អយកខ.សក

**ជម្រាបជូន**
**លោកនាយក សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**

កម្មវត្ថុ ៖ ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

យោង ៖ -លិខិតលេខ២៣៤១ អយក.វជអ ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតឧទ្ទេសនាមលេខ២៤៦៥ អយក.ឧទន ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកនាយក ជ្រាបថា៖ លោក ម៉ៃ ខែង មន្ត្រីការិយាល័យ និងគ្រប់គ្រងជំនួយ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ត្រូវសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ លើប្រធានបទស្រាវជ្រាវ "ស្ថានភាពនៃការធានាគុណភាពអប់រំ នៅសាលាគរុកោសល្យ និងវិក្រឹតការ នៅខេត្តសៀមរាប" ក្នុងការសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាត្រូវការប្រមូលទិន្នន័យពីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ កាលបរិច្ឆេទចុះប្រមូលទិន្នន័យ និងសម្ភាសន៍ ចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម លោកនាយក ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យនេះឱ្យបានលទ្ធផលល្អ។

សូម លោកនាយក ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃអង្គារ ១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
សៀមរាប ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

លី ប៊ុនណា

**ចម្លងជូន ៖**
-រដ្ឋបាលក្រុងស្រុកទាំង១២
«ដើម្បីជូនជ្រាប»
- សាមីខ្លួន «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: មណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាបកម្ពុជា
ទូរស័ព្ទ: 063 210 740
អ៊ីមែល: siem.reap@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

## ឧបសម្ព័ន្ធទី 13៖ លិខិតអនុញ្ញាតរបស់សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**សាលាគរុកោសល្យនិងវិក្រឹតការ**
**ខេត្តសៀមរាប**
**លេខ៖ ១៩៧ សគវ.សរ**

**នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប**
**សូមអញ្ជើញ**

លោក/លោកស្រី ជានាយករង នាយិការង បុគ្គលិក គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្ត នាយក-នាយិការង និងគ្រូបង្រៀននៃសាលាអនុវត្តន៍គរុកោសល្យ។

កម្មវត្ថុ៖ អញ្ជើញចូលរួមប្រជុំប្រចាំខែមិថុនា និងកក្កដាឆ្នាំ២០២២
កាលបរិច្ឆេទ៖ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២២
ពេលវេលា៖ ម៉ោង ៨:០០ ព្រឹក
ទីកន្លែង៖ នៅអគារ M
របៀបវារៈ

១-បង្ហាញគោលបំណងនៃការចុះស្រាវជ្រាវរបស់លោកម៉ៃ ខេង
២-ការទូទាត់ថវិកា
៣-ការគ្រប់គ្រងបុគ្គលិក
៤-ការអភិវឌ្ឍសមត្ថភាពបុគ្គលិក
៥-សេចក្តីផ្សេងៗ

អាស្រ័យដូចបានជម្រាបជូនខាងលើសូមលោក-លោកស្រីអញ្ជើញចូលរួមដោយការទទួលខុសត្រូវ។

បញ្ជាក់

-សូមអ្នកពាក់ព័ន្ធត្រៀមរបាយការណ៍

ថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
សៀមរាប, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២២
**នាយកសាលា**

**ឈត់ ឆៀង**

អាសយដ្ឋាន៖ មហាវិថីហ្សាលដឺហ្គោល ភូមិមណ្ឌលបេ៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
លេខទូរស័ព្ទ៖ (+៨៥៥) ១២ ៩១០ ២០៥/១៦ ៦៨២ ៥០១ Email: chhorthchhieng@gmail.com

## ឧបសម្ព័ន្ធទី 14៖ លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:..៧៧០២៧..អយក.ទក

### លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា ២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និង គ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ឆ្នាំសិក្សា២០២១-២០២២ ដែលបានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាម និស្សិត |
|---|---|---|---|---|
| ១ | បណ្ឌិត គួយ សុគាន | លោកស្រី ប៊ុន សុផានី | គុណវុឌ្ឍិគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសជះឥទ្ធិពលដល់ការបង្រៀន និងរៀនលើជំនាញឯកទេសអគ្គិសនី នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | លោក កែវ សោភ័ណ |
| ២ | លោក ម៉ន មុនិន្ទ | បណ្ឌិត ឈាង សង្វាត | ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ | លោកស្រី ជា ច័ន្ទសុភ័ក្ត្រ |
| ៣ | បណ្ឌិត ឈូក ច័ន្ទឆាយា | ឯកឧត្តមបណ្ឌិត ឌី ខាំបូលី | ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយកសាលា ជាមួយនឹងអត្តសញ្ញាណវិជ្ជាជីវៈនិងភាពពេញចិត្តក្នុងការបំពេញការងាររបស់គ្រូ | លោក ថន ឌីណា |
| ៤ | លោក ឌី បុណ្ណា | បណ្ឌិត ឡឹយ សុគា | ស្ថានភាពនៃការអនុវត្តស្ទែម (STEM) នៅសាលាធនធានក្នុងខេត្តរតនគិរី | លោក ទ្រី វាសនា |
| ៥ | បណ្ឌិត ម៉ម ចាន់សៀន | បណ្ឌិត នូវ វីរ៉ា | សមត្ថភាពរបស់អតីតគរុសិស្សនៃសាលាគរុកោសល្យ និងក្រឹតការខេត្តសៀមរាបធៀបនឹងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន | លោក នួន សាក់ក់ |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៦ | ឯកឧត្តមបណ្ឌិត ឌី ខាំបូលី | ឯកឧត្តមបណ្ឌិត ជ័យ សារិន | ស្ថានភាពនៃការអនុវត្តការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកក្នុងខេត្តព្រៃវែងក្រោយ ប្រតិភូកម្មមុខងារ | លោក បាន វណ្ណជឿន |
| ៧ | បណ្ឌិត សោន វណ្ណៈ | បណ្ឌិត មឿន លិនណា | គណនេយ្យភាពនាយកសាលាលើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ | លោក ផាន់ ម៉ៅ |
| ៨ | ឯកឧត្តមបណ្ឌិត សិត សេង | បណ្ឌិត នូវ វ៉ា | ស្ថានភាពនៃការធានាគុណភាពអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការនៅខេត្តសៀមរាប | លោក ម៉ៃ ខែង |
| ៩ | បណ្ឌិត ឈន ថន | បណ្ឌិត មឿន លិនណា | ការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូចទៅរដ្ឋ បាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង | លោក យ៉ុង សុផានា |
| ១០ | បណ្ឌិត នូវ វ៉ា | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | កត្តានាំឱ្យមានវិសមភាពយេនឌ័រក្នុងផ្នែកផែនការអប់រំ | លោកស្រី វ៉ន ពិសិដ្ឋ |
| ១១ | បណ្ឌិត នី រដ្ឋា | លោក គីម លាង | ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សានៅខេត្តត្បូងឃ្មុំ | លោក សន សីហា |
| ១២ | បណ្ឌិត នូវ វ៉ា | ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម | ការអនុវត្តគោលការណ៍ការគ្រប់គ្រងធនធានមនុស្សរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការនៃក្រសួងអប់រំ យុវជន និងកីឡា | លោកស្រី សរ សុគន្ធារស |
| ១៣ | បណ្ឌិត អាន រ៉ូប្រាវ | បណ្ឌិត ឡឹយ សុគា | ការអនុវត្តការគ្រប់គ្រងការងាររដ្ឋបាលរបស់គណៈគ្រប់គ្រងសាលាបឋមសិក្សា ក្នុងខេត្តរតនគិរី | លោក សួន ពេញ |
| ១៤ | បណ្ឌិត អ៊ុំ ចាន់ចំណាន | លោកស្រី ឯម សុភាលក្ស្មី | ការពិសោធមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យធនធាន(ករណីសិក្សាក្នុងខេត្តស្វាយរៀង) | លោក សួន សារុនឌឿន |
| ១៥ | បណ្ឌិត លី គិមឡុង | លោក លឹម វ៉ាន់ | ស្ថានភាពការសិក្សារបស់សិស្សថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមក្នុងបរិបទកូវីដ-១៩ នៅកម្រិតវិទ្យាល័យនៃខេត្តកោះកុង | លោក សៅ រិទ្ធ |
| ១៦ | បណ្ឌិត បូ ច័ន្ទគុលិកា | បណ្ឌិត ម៉ម ចាន់សៀន | ការពង្រឹងសមត្ថភាពសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាបដើម្បីប្រែក្លាយជាវិទ្យាស្ថានគរុកោសល្យ | លោកស្រី ហ៊ិន មករា |

| | | | | |
|---|---|---|---|---|
| ១៧ | បណ្ឌិត ឈិញ នីដា | បណ្ឌិត លី គិមឡុង | ការប្រើប្រាស់ICTលើ ការបង្រៀន និងរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិៈ ករណីសិក្សា ក្នុងខេត្តព្រៃវែង | លោក ឡុង សីម៉ា |
| ១៨ | បណ្ឌិត នី ផ្ងៃ | បណ្ឌិត ឈិញ ស៊ីថា | ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួនក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សានៅរាជធានីភ្នំពេញ | លោក អ៊ឹម សៀន |
| ១៩ | បណ្ឌិត ឡឹយ សុគា | បណ្ឌិត អែ សុងហ៊ាង | កត្តាដែលប៉ះពាល់ដល់ប្រសិទ្ធភាពការរៀនគណិតវិទ្យារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ ករណីសិក្សាខេត្តស្វាយរៀង | លោកស្រី អ៊ិន ម៉ុល |
| ២០ | ឯកឧត្តមបណ្ឌិត ជ័យ សារិន | ឯកឧត្តមបណ្ឌិត សិត សេង | ការដឹកនាំគ្រប់គ្រងថ្នាក់រៀនរបស់គ្រូឧទ្ទេសមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល | លោកស្រី សុខ ផល្លី |
| ២១ | ឯកឧត្តមបណ្ឌិត សិត សេង | បណ្ឌិត គួយ សុគាន | ការគ្រប់គ្រងបរិស្ថានសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង | លោក រឹម សារាត់ |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលការកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួលៈ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដ្ឋ

ឧបសម្ព័ន្ធទី 15៖ អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៤៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្ល្យសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យ និងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យមកស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១ ..**

ត្រូវបានផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្ល្យសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យមកស្ថិតក្រោម

ការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានគ្រូបង្រៀន គុណភាពបណ្ដុះបណ្ដាល និងវិក្រឹតការបុគ្គលិកអប់រំ ស្របតាមគោលនយោបាយកំណែទម្រង់គ្រូបង្រៀន និងកំណែទម្រង់វិស័យអប់រំ។

**មាត្រា២ .-**

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគញ្ញសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ដែលត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា មានឈ្មោះនិងទីតាំងដូចខាងក្រោម៖

**ក. មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ**

១.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មានទីតាំងនៅក្រុងកំពង់ចាម ខេត្តកំពង់ចាម

២.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ មានទីតាំងនៅក្រុងដូនកែវ ខេត្តតាកែវ

៣.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង និងអនុវិទ្យាល័យអនុវត្តន៍ មានទីតាំងនៅក្រុងព្រៃវែង ខេត្តព្រៃវែង

៤.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល និងអនុវិទ្យាល័យ ហ៊ុន សែន អនុវត្តន៍ មានទីតាំងនៅក្រុងតាខ្មៅ ខេត្តកណ្ដាល

៥.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគញ្ញសានខេត្តស្ទឹងត្រែង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**ខ. សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ទាំង១៥**

១.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ចាម និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន មានទីតាំងនៅក្រុងកំពង់ចាម ខេត្តកំពង់ចាម

២.សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តព្រៃវែង និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន ព្រៃវែង មានទីតាំងនៅក្រុងព្រៃវែង ខេត្តព្រៃវែង

៣.សាលាគរុកោសល្យនិងវិក្រឹតការខេត្តតាកែវ និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន តាកែវ មានទីតាំងនៅក្រុងដូនកែវ ខេត្តតាកែវ

៤.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកណ្ដាល និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងតាខ្មៅ ខេត្តកណ្ដាល

៥.សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តកំពង់ធំ និងសាលាបឋមសិក្សា ហ៊ុន សែន អនុវត្តន៍ មានទីតាំងនៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ

៦.សាលាគរុកោសល្យនិងវិក្រឹតការខេត្តសៀមរាប និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងសៀមរាប ខេត្តសៀមរាប

៧.សាលាគរុកោសល្យនិងវិក្រឹតការខេត្តក្រចេះ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងក្រចេះ ខេត្តក្រចេះ

៨.សាលាគរុកោសល្យនិងវិក្រឹតការខេត្តស្វាយរៀង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងស្វាយរៀង ខេត្តស្វាយរៀង

៩.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពត និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងកំពត ខេត្តកំពត

១០.សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះសីហនុ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

១១.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ឆ្នាំង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

១២.សាលាគរុកោសល្យនិងវិក្រឹតការខេត្តពោធិ៍សាត់ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

១៣.សាលាគរុកោសល្យនិងវិក្រឹតការខេត្តបន្ទាយមានជ័យ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

១៤.សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះវិហារ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងព្រះវិហារ ខេត្តព្រះវិហារ

១៥.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ស្ពឺ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**មាត្រា៣ ._**

បុគ្គលិកអប់រំ ថវិកា ចលនទ្រព្យ និងអចលនទ្រព្យគ្រប់ប្រភេទនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ត្រូវផ្ទេរមកឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំយន្តការការងារនិងគោលការណ៍សម្រាប់គ្រប់គ្រង ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ ._**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀនដែលមានរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាជាប្រធាន ដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត សាលាអនុវត្តន៍ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងកញ្ចប់ថវិកាដោយឡែកដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសម្រាប់ដំណើរការការងាររបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន។

**មាត្រា៥ ._**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការអនុវត្តសេចក្តីសម្រេចលេខ៤៨ ស.ស.រ. ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៨៣ស្តីពីការបណ្តុះបណ្តាលគ្រូកម្រិតសិក្សាទី១រយៈពេលវែងនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីសម្រេចលេខ១៣៦ ស.ស.រ. ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៨៤ស្តីពីការបើកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង និងសេចក្តីសម្រេចលេខ១៣៧ ស.ស.រ. ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៨៤ស្តីពីការបង្កើតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ សម្រាប់

បណ្តុះបណ្តាលនិងវិក្រឹតការគ្រូកម្រិតសិក្សាទី២របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥ រោច ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី 16៖ ប្រកាសលេខ ២៩៥៤ អយក.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៩៥៤ អយក.ប្រក

# ប្រកាស
## ស្តីពី
## គោលការណ៍ និងយន្តការការងារគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ ទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យបាត់ដំបង

- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងកំណត់អំពី គោលការណ៍ និងយន្តការការងារគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីអភិវឌ្ឍធនធានគ្រូបង្រៀនឆ្លើយតបទៅនឹងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ស្របតាមអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅកំណត់អំពី៖

- គោលការណ៍នៃការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនតាមរយៈគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន
- ធានាគុណភាព និងប្រសិទ្ធភាពការបណ្តុះបណ្តាលគ្រូបង្រៀន
- យន្តការការងារនិងការគ្រប់គ្រងរដ្ឋបាលរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ បច្ចេកទេស និងទ្រព្យសម្បត្តិរដ្ឋនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ ព្រមទាំងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនផ្សេងទៀត និងសាលាអនុវត្តន៍ដែលបានផ្ទេរការគ្រប់គ្រងឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី២
## គោលការណ៍គ្រប់គ្រង

**ប្រការ៤ ._**

គោលការណ៍គ្រប់គ្រង ត្រូវបានកំណត់លើការគ្រប់គ្រងបុគ្គលិក គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គ្រប់គ្រងបច្ចេកទេស និងការគ្រប់គ្រងសាលាអនុវត្តន៍។

## ផ្នែកទី១
## ការគ្រប់គ្រងបុគ្គលិក

**ប្រការ៥ ..**

បុគ្គលិកអប់រំរបស់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវជាមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈវិស័យអប់រំដែលបានតែងតាំងឱ្យបម្រើការងារនៅគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវលើកសំណើសុំជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួនដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិក ត្រូវជានានូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព អព្យាក្រឹត និងសមធម៌ ស្ថិតក្រោមការទទួលខុសត្រូវរបស់គ្រឹះស្ថាននីមួយៗ។

**ប្រការ៦ ..**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀននីមួយៗ ត្រូវរៀបចំផែនការតម្រូវការបុគ្គលិក និងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិកអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការការងារក្នុងអង្គភាពរបស់ខ្លួន។

លេខាធិការដ្ឋាននៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ត្រូវប្រមូលនិងបូកសរុបផែនការជ្រើសរើសបុគ្គលិក និងផែនការអភិវឌ្ឍន៍សមត្ថភាព។

**ប្រការ៧ ..**

បុគ្គលិកអប់រំនៃគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវគោរពកាតព្វកិច្ចស្របតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន លិខិតបទដ្ឋានគតិយុត្តជាធរមាន និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយគណៈគ្រប់គ្រងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន។

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់បុគ្គលិកអប់រំឱ្យស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានខាងលើ។

**ប្រការ៨ ..**

ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន មានតួនាទីនិងភារកិច្ចក្នុងការគ្រប់គ្រងបុគ្គលិក ដូចខាងក្រោម៖

- រៀបចំផែនការបង្កើនសមត្ថភាពបុគ្គលិក គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន
- បំប៉នសមត្ថភាពការប្រើប្រាស់កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត
- រៀបចំកម្មវិធីវិក្រឹតការគ្រូបង្រៀន និងធ្វើវិក្រឹតការទៀងទាត់ចំពោះគ្រូបង្រៀន ដូចជាកម្មវិធីពន្លឿន កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន
- សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំការប្រឡងចូលគ្រឹះស្ថាន ស្របតាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៩ ..**

គណៈគ្រប់គ្រង គ្រូឧទ្ទេស និងបុគ្គលិកនៃគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវទទួលបានការលើកទឹកចិត្តតាមគោលការណ៍កំណត់។

# ផ្នែកទី២
# ការគ្រប់គ្រងដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការ

**ប្រការ១០ ._**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន មានតួនាទីនិងភារកិច្ចផ្តល់ការបណ្តុះបណ្តាលនិងវិក្រឹតការ ដល់គរុសិស្ស គរុនិស្សិត និងបុគ្គលិកអប់រំ ដូចខាងក្រោម៖

- បណ្តុះបណ្តាល និងវិក្រឹតការក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម ឬក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យប្រែក្លាយទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាដល់គ្រូឧទ្ទេស និងគ្រូកម្រិតមូលដ្ឋាន
- អភិវឌ្ឍសមត្ថភាពបន្តដល់បុគ្គលិកអប់រំ
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការការងារ
- ស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការរបស់គ្រឹះស្ថាន
- អនុវត្តកិច្ចការផ្សេងៗទៀតតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ១១ ._**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវអនុវត្តភារកិច្ចសំខាន់ៗមួយចំនួន មុនចាប់ផ្តើមដំណើរការសិក្សា មានដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំមុនដំណើរការបណ្តុះបណ្តាល
- រៀបចំសេវាបង្រៀននិងដឹកនាំគ្រូឧទ្ទេសដើម្បីរៀបចំផែនការបណ្តុះបណ្តាល
- រៀបចំមូលដ្ឋានសម្ភារៈសម្រាប់បម្រើការសិក្សា និងចាត់តាំងគ្រូឧទ្ទេសទទួលបន្ទុកថ្នាក់នីមួយៗ
- ជំរុញឱ្យមានការរៀបចំកិច្ចតែងការបង្រៀនត្រឹមត្រូវតាមកម្មវិធីសិក្សា
- រៀបចំថ្នាក់សម្រាប់គរុសិស្ស គរុនិស្សិតចូលរៀន កាលវិភាគសិក្សា និងព្រាងកម្មវិធីមួយសប្តាហ៍ដំបូងពេលគរុសិស្សចូលមក
- ផ្សព្វផ្សាយឯកសារជំនាញផ្សេងៗដែលពាក់ព័ន្ធ។

**ប្រការ១២ ._**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបំពេញភារកិច្ចសំខាន់ៗមួយចំនួន ក្នុងអំឡុងពេលបណ្តុះបណ្តាល ដូចខាងក្រោម៖

- រៀបចំផែនការ និងកម្មវិធីប្រជុំប្រចាំសប្តាហ៍របស់គរុសិស្ស គរុនិស្សិតដោយសួរសុខទុក្ខជាប្រចាំ
- រៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់នីមួយៗ
- អនុវត្តកម្មវិធីមួយសប្តាហ៍ដំបូងដែលបានត្រៀមទុក
- អនុវត្តកម្មវិធីសិក្សា វាយតម្លៃសិក្សាជាដំណាក់ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ

- ពិនិត្យតាមដាននិងវាយតម្លៃការសិក្សារបស់គរុសិស្ស គរុនិស្សិតជាប្រចាំ
- បង្ហាញលទ្ធផលក្រោយពេលវាយតម្លៃការសិក្សារបស់គរុសិស្ស គរុនិស្សិត
- លើកទឹកចិត្តគរុសិស្ស គរុនិស្សិតដែលមានស្នាដៃ
- រៀបចំគណៈកម្មការយុវជន និងគណៈគ្រប់គ្រងអន្តេវាសិកដ្ឋានប្រចាំជំនាន់
- សហការរៀបចំកម្មវិធីពិនិត្យសុខភាពដល់គរុសិស្ស គរុនិស្សិត
- អញ្ជើញមាតាបិតា ឬអ្នកអាណាព្យាបាលមកជួបគណៈគ្រប់គ្រង ដើម្បីទទួលបានព័ត៌មាន (សម្រាប់ឆ្នាំទី១)
- ណែនាំដល់គរុសិស្ស គរុនិស្សិតពេលគោរពទង់ជាតិជាប្រចាំ
- តាមដានជាប្រចាំ វត្តមាន អវត្តមានគរុសិស្ស គរុនិស្សិត
- ធ្វើរបាយការណ៍ជូនគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន។

**ប្រការ១៣ ._**

គ្រូឧទ្ទេសនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបំពេញតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវវិធីសាស្ត្របង្រៀន និងរៀន ដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការប្រតិបត្តិ
- ដឹកនាំការរៀន ការបង្រៀន និងការស្រាវជ្រាវ ដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈដល់គរុសិស្ស គរុនិស្សិត
- អនុវត្តកម្មវិធីសិក្សាឱ្យបានពេញលេញប្រកបដោយគុណភាព និងប្រសិទ្ធភាព
- សហការ និងដឹកនាំកម្មសិក្សារបស់គរុសិស្ស គរុនិស្សិត
- គ្រប់គ្រងគរុសិស្ស គរុនិស្សិត និងត្រួតពិនិត្យដំណើរការសិក្សានិងលទ្ធផលសិក្សា
- បំពេញភារកិច្ចផ្សេងទៀត តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងអនុវត្តភារកិច្ចដែលគណៈគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនប្រគល់ជូន។

## ផ្នែកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**ប្រការ១៤ ._**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានតម្លាភាព និងគណនេយ្យភាពចំពោះក្រសួងអប់រំ យុវជន និងកីឡា លើការគ្រប់គ្រងហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ១៥ ._**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងថវិកា តាមគោលការណ៍ណែនាំជាធរមាន។

គណៈកម្មការគ្រប់គ្រងថវិកា មានសមាសភាព៖

| | |
|---|---|
| - នាយក/នាយិកាគ្រឹះស្ថាន | ប្រធាន |
| - នាយករង/នាយិការងទទួលបន្ទុកគណនេយ្យ | អនុប្រធាន |
| - តំណាងគ្រប់ការិយាល័យជំនាញ ឬផ្នែក | សមាជិក |
| - មន្ត្រីទទួលបន្ទុកគណនេយ្យ | សមាជិក |
| - មន្ត្រីទទួលបន្ទុកបេឡា | សមាជិក |

- មន្ត្រីទទួលបន្ទុកទ្រព្យសម្បត្តិរដ្ឋ សមាជិក

**ប្រការ១៦ ..**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានមន្ត្រីទទួលបន្ទុកគណនេយ្យ និងមន្ត្រីទទួលបន្ទុកបេឡា ហើយមានលក្ខណៈសម្បត្តិ ដូចខាងក្រោម៖

- ចំណេះដឹងផ្នែកហិរញ្ញវត្ថុ
- បទពិសោធន៍ការងារហិរញ្ញវត្ថុ
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ
- ចំណេះដឹងផ្នែកកុំព្យូទ័រ
- ឆន្ទៈខ្ពស់ក្នុងការបំពេញការងារ
- មានទំនួលខុសត្រូវខ្ពស់។

**ប្រការ១៧ ..**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានភារកិច្ចនិងការទទួលខុសត្រូវក្នុងការរៀបចំថវិកា ដោយអនុលោមតាមមាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។

ភារកិច្ចនិងការទទួលខុសត្រូវដោយឡែកមានដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិការបស់ក្រសួង ស្របជាមួយផែនការអភិវឌ្ឍន៍គ្រឹះស្ថាន និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអប់រំ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពសាមីដោយបែងចែកលម្អិត តាមចំណាត់ថ្នាក់ដែលបានកំណត់ក្នុងមាតិកាថវិកា
- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពសាមី
- រៀបចំបូកសរុបគម្រោងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់សាលាអនុវត្តន៍ដែលស្ថិតនៅក្រោមឱវាទ ព្រមទាំងបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុ
- កៀរគរធនធានពីគ្រប់ប្រភពផ្សេងៗសម្រាប់បណ្តុះបណ្តាល វិក្រឹតការ និងស្រាវជ្រាវ
- ចូលរួមប្រជុំចរចាថវិកាតាមការចាំបាច់របស់ក្រសួង។

**ប្រការ១៨ ..**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវអនុវត្តថវិកាដូចខាងក្រោម ៖

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួនក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានអនុម័តប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- រៀបចំកម្មវិធីចំណូល ចំណាយរបស់អង្គភាព ដើម្បីដាក់ជូននាយកដ្ឋានហិរញ្ញវត្ថុ
- ត្រួតពិនិត្យនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់អង្គភាពសាមី
- ស្នើសុំចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកា ដើម្បីដាក់ជូននាយកដ្ឋានហិរញ្ញវត្ថុសម្រាប់បំពេញតម្រូវការចំណាយជាក់ស្តែង
- មានសិទ្ធិពេញលេញក្នុងកិច្ចប្រតិបត្តិការចំណូលរបស់ខ្លួន

- មានសិទ្ធិពេញលេញក្នុងការអនុវត្តចំណាយសម្រាប់ថវិកាដំណើរការគ្រឹះស្ថាន ដោយអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់ជាមុន និងមានសិទ្ធិពេញលេញក្នុងការស្នើសុំចំណាយផ្សេងៗដោយផ្ទាល់មកអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចរាល់លិខិតស្នើសុំថវិកាចំណាយ លិខិតយុត្តិការ និងសក្ខីប័ត្រចំណាយថវិកាឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់ក្នុងមាតិកាថវិកា
- ត្រូវរៀបចំសំណើសុំបើកផ្តល់សាច់ប្រាក់មុនសម្រាប់មូលនិធិដំណើរការសាលារៀនរបស់សាលាអនុវត្តន៍ដែលស្ថិតក្រោមឱវាទ ដោយភ្ជាប់មកជាមួយនូវកម្មវិធីចំណាយសាច់ប្រាក់ ព្រមទាំងបញ្ជូនទៅនាយកដ្ឋានហិរញ្ញវត្ថុ
- គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវប្រមូលរបាយការណ៍ទូទាត់ចំណាយថវិកាពីសាលាអនុវត្តន៍ដើម្បីរៀបចំបូកសរុបជាតារាងរបាយការណ៍ទូទាត់តាមជំពូក គណនី អនុគណនី រួចបញ្ជូនជារៀងរាល់ដើមខែនៃត្រីមាសបន្ទាប់ទៅនាយកដ្ឋានហិរញ្ញវត្ថុ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនរបាយការណ៍ឱ្យបានមុនថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗ។

**ប្រការ១៩.-**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវរៀបចំកិច្ចបញ្ជិកាគណនេយ្យ និងការទូទាត់ដូចខាងក្រោម៖

**១.ការកត់ត្រា** ត្រូវអនុវត្តតាមនីតិវិធីកត់ត្រាចំណូល ចំណាយ ក្នុងកិច្ចបញ្ជិកាគណនេយ្យ រួមមាន៖

- កិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច (ប័ណ្ណចំណូល ប័ណ្ណចំណាយ បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ និងបញ្ជីបេឡា)
- កិច្ចបញ្ជិកាគណនេយ្យសម្ភារៈ (ប័ណ្ណបញ្ចូលសម្ភារៈទំនិញ ប័ណ្ណបញ្ចេញសម្ភារៈទំនិញ និងបញ្ជីវិភាគសម្ភារៈទំនិញ)។

**២.ការទូទាត់** ត្រូវអនុវត្តតាមនីតិវិធីនៃការទូទាត់ចំណាយរួមមាន៖

- **ការស្នើសុំទូទាត់ថវិកាដំណើរការៈ** មន្ត្រីទទួលគណនេយ្យរបស់គ្រឹះស្ថាន ត្រូវប្រមូលឯកសារលិខិតយុត្តិការ និងប្រមូលសក្ខីបត្រចំណាយរួមមាន លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗ និងប័ណ្ណចំណាយ។ រៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី និងអនុគណនី រីឯសក្ខីបត្រចំណាយ លិខិតយុត្តិការ ឯកសារច្បាប់ដើមពាក់ព័ន្ធផ្សេងៗ និងរបាយការណ៍ចំណាយថវិកានិងកិច្ចបញ្ជិកាគណនេយ្យ ត្រូវរក្សាទុកនៅអង្គភាពសាមី ដើម្បីជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយ។ ចំពោះគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបញ្ជូនរបាយការណ៍ទូទាត់ចំណាយថវិកា នៅរៀងរាល់ដើមខែនៃត្រីមាសបន្ទាប់ទៅនាយកដ្ឋានហិរញ្ញវត្ថុ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗ។
- **ការទូទាត់ចំណាយៈ** មន្ត្រីទទួលគណនេយ្យរបស់គ្រឹះស្ថាន មានសិទ្ធិពេញលេញក្នុងការស្នើសុំទូទាត់ ដោយផ្ទាល់មកនាយកដ្ឋានហិរញ្ញវត្ថុ សម្រាប់ចំណាយក្រៅពីថវិកាដំណើរការ(អាហារូបករណ៍ អគ្គិសនី ទឹក សេវាអីនធើណេត ទូរស័ព្ទ...)។

**ប្រការ២០.-**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម របស់អង្គភាពសាមី និងបូកសរុបរបាយការណ៍សមិទ្ធកម្មរបស់សាលាអនុវត្តន៍ ស្របតាមការណែនាំរបស់នាយកដ្ឋានហិរញ្ញវត្ថុ ក្នុង

ក្របខណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ហើយផ្ញើជូននាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រសួង តាមកាលបរិច្ឆេទដែលបានកំណត់។

## ផ្នែកទី៤
## ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**ប្រការ២១ ._**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ២២ ._**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវស្នើសុំមកក្រសួងអប់រំ យុវជន និងកីឡា បង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីគ្រប់គ្រង និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋ ពិនិត្យនិងវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងលើកសំណើចាត់ចែងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថាន តាមការណែនាំនិងនីតិវិធីជាធរមាន។

ក្រុមការងារ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រួមមាន ប្រធាន អនុប្រធាន និងសមាជិកទាំងអស់ ត្រូវត្រួតពិនិត្យទ្រព្យសម្បត្តិរដ្ឋជាប្រចាំ សម្រេចលើការកំណត់ស្ថានភាពនិងតម្លៃទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថាន និងការស្នើសុំជម្រះបញ្ជីមកក្រសួង ព្រមទាំងអនុវត្តការកិច្ចផ្សេងទៀតដូចមានចែកក្នុងសេចក្ដីសម្រេចបង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមនីតិវិធីជាធរមាន។

**ប្រការ២៣ ._**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវពិនិត្យតាមដានស្ថានភាពទ្រព្យសម្បត្តិរដ្ឋក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានមួយឆ្នាំចំនួនពីរដង។ លើកទី១ ក្នុងខែមិថុនា ដើម្បីពិនិត្យ វាយតម្លៃ ស្ថានភាពរបស់ទ្រព្យសម្បត្តិរដ្ឋទាំងនោះ ករណីខូច ត្រូវស្នើសុំជម្រះ និងខ្វះត្រូវលើកផែនការតម្រូវការ។ លើកទី២ ក្នុងខែធ្នូ ពិនិត្យមើលស្ថានភាពសម្ភារៈ ធ្វើបច្ចុប្បន្នភាពនិងរៀបចំបញ្ជីសារពើភណ្ឌ។

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវណែនាំដល់សាលាអនុវត្តន៍ ការិយាល័យ ផ្នែកនីមួយៗក្នុងរចនាសម្ព័ន្ធរបស់គ្រឹះស្ថានឱ្យរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជាប្រចាំរៀងរាល់ឆ្នាំ។

**ប្រការ២៤ ._**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវស្នើសុំជម្រះទ្រព្យសម្បត្តិរដ្ឋដែលខូចប្រើប្រាស់លែងកើត ឬផ្ទេរចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទៅក្រសួងអប់រំ យុវជន និងកីឡា ដែលមាននាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋជាសេនាធិការ។

លក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី៥
## ការគ្រប់គ្រងសាលាអនុវត្តន៍

**ប្រការ២៥ .-**

សាលាអនុវត្តន៍ជាផ្នែកមួយនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ហើយសាលាអនុវត្តន៍ត្រូវគ្រប់គ្រងដោយនាយក១(មួយ)រូប និងនាយករងទៅតាមនិយាមដែលបានកំណត់ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន ហើយជាសេនាធិការឱ្យនាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

សាលាអនុវត្តន៍ ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទាំងការងាររដ្ឋបាល ការងារបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និងបច្ចេកទេស។

**ប្រការ២៦ .-**

សាលាអនុវត្តន៍ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ រួចបញ្ជូនមកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីដាក់បញ្ចូលក្នុងផែនការរួមរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

**ប្រការ២៧ .-**

ចំណូលនិងចំណាយរបស់សាលាអនុវត្តន៍ ត្រូវឆ្លងកាត់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកត់ត្រាកិច្ចបញ្ជីគណនេយ្យ។

សាលាអនុវត្តន៍ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(គ.ម.ស) ដើម្បីគ្រប់គ្រងការកិច្ចដំណើរការ និងអភិវឌ្ឍសាលារៀន។ សមាសភាពនៃគណៈកម្មការនេះ ត្រូវអនុវត្តតាមសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ។

សាលាអនុវត្តន៍មានសិទ្ធិពេញលេញក្នុងការប្រមូលចំណូល ឬកៀរគរថវិកាបន្ថែមដោយមានការចូលរួមពីសហគមន៍ អាណាព្យាបាលសិស្ស សប្បុរសជន អង្គការ ឬវិស័យឯកជន។

**ប្រការ២៨ .-**

សាលាអនុវត្តន៍ ត្រូវអនុវត្តការគ្រប់គ្រងថវិកាដូចខាងក្រោម៖

- **គណនេយ្យភាពថវិកា:** នៅពេលបានទទួលសាច់ប្រាក់ គ្រប់សាលាអនុវត្តន៍ ត្រូវប្រជុំផ្សព្វផ្សាយ និងបិទផ្សាយលើបញ្ជរព័ត៌មានជូនលោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធនូវព័ត៌មានដូចជាចំនួនសាច់ប្រាក់ដែលទទួលបាន និងគម្រោងចំណាយប្រចាំត្រីមាស។ គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ត្រូវសហការចាត់ចែង គ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិកា។

- **កិច្ចបញ្ជិកាគណនេយ្យៈ** ត្រូវអនុវត្តតាមនីតិវិធីកត់ត្រាចំណូល ចំណាយក្នុងកិច្ចបញ្ជិកាគណនេយ្យ ដូចជា៖ កិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច (ប័ណ្ណចំណូល ប័ណ្ណចំណាយ បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ និងបញ្ជីបេឡា) និងកិច្ចបញ្ជិកាគណនេយ្យសម្ភារៈ (ប័ណ្ណបញ្ចូលសម្ភារៈ ទំនិញ ប័ណ្ណបញ្ចេញសម្ភារៈ ទំនិញ និងបញ្ជីវិភាគសម្ភារៈ ទំនិញ)។
- **ការទូទាត់** ត្រូវអនុវត្តតាមនីតិវិធីនៃការទូទាត់ចំណាយ ដូចជា៖ ប្រមូលឯកសារលិខិតយុត្តិការ និងប្រមូលសក្ខីបត្រចំណាយ (លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗ និងប័ណ្ណចំណាយ)

ការរៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី និងអនុគណនី រីឯសក្ខីបត្រចំណាយ លិខិតយុត្តិការ ឯកសារច្បាប់ដើមពាក់ព័ន្ធផ្សេងៗ និងរបាយការណ៍ចំណាយថវិកានិងកិច្ចបញ្ជិកាគណនេយ្យ ត្រូវរក្សាទុកនៅអង្គភាពសាមី ដើម្បីជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយ។

សាលាអនុវត្តន៍ ត្រូវបញ្ជូនរបាយការណ៍ទូទាត់ចំណាយថវិកាសរុបច្បាប់ដើម តាមជំពូក គណនី អនុគណនីនៅរៀងរាល់ដើមខែនៃត្រីមាសបន្ទាប់ ទៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីធ្វើការបូកសរុប។

សាលាអនុវត្តន៍ ត្រូវរៀបចំនិងបញ្ជូនរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំទៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីបូកសរុប។

**ប្រការ២៩ ._**

សាលាអនុវត្តន៍ ត្រូវប្រមូលសិស្សចូលរៀនតាមឆ្នាំសិក្សានីមួយៗ ដោយស្របតាមគោលការណ៍ណែនាំរបស់ក្រសួងពាក់ព័ន្ធទៅតាមកាលបរិច្ឆេទចូលរៀន ដោយសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

**ប្រការ៣០ ._**

សាលាអនុវត្តន៍ ត្រូវអនុវត្តកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការកំណត់និយាមថ្នាក់សិស្សនៅសាលាអនុវត្តន៍ ត្រូវអនុវត្តតាមគោលការណ៍ណែនាំជាធរមានរបស់ក្រសួងអប់រំ យុវជន និងកីឡាពាក់ព័ន្ធកម្រិតនៃការបណ្តុះបណ្តាល។

នាយកសាលាអនុវត្តន៍ ត្រូវរៀបចំសំណុំឯកសារពាក់ព័ន្ធការសិក្សារបស់សិស្ស ដោយមានការឯកភាពពីនាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ជូនដល់សិស្សដើម្បីបន្តភូមិសិក្សាតាមតម្រូវការរបស់គ្រឹះស្ថានសិក្សាថ្មី។

នាយកសាលាអនុវត្តន៍ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់សិស្សយកទៅអនុវត្តស្របតាមប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ។

នាយកសាលាអនុវត្តន៍ ត្រូវរៀបចំរបាយការណ៍ការងារតាមគោលការណ៍កំណត់ ដោយមានការឯកភាពពីនាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន តាមកាលកំណត់។

**ប្រការ៣១ ..**

បុគ្គលិកអប់រំដែលបម្រើការងារនៅសាលាអនុវត្តន៍ គឺជាបុគ្គលិកនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវអនុវត្តការងារតាមការកំណត់របស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៣២ ..**

រាល់កិច្ចដំណើរការរៀន បង្រៀន ប្រឡង ប្រជុំបច្ចេកទេស និងការងារបច្ចេកទេសផ្សេងទៀតរបស់សាលាអនុវត្តន៍ ត្រូវអនុវត្តដូចគ្រឹះស្ថានសិក្សាចំណេះទូទៅដទៃទៀតដែរ ស្របតាមគោលការណ៍ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## យន្តការការងារនិងការគ្រប់គ្រងរដ្ឋបាល

**ប្រការ៣៣ ..**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានទំនាក់ទំនងការងារបុគ្គលិកជាមួយនាយកដ្ឋានបុគ្គលិក ការងារហិរញ្ញវត្ថុជាមួយនាយកដ្ឋានហិរញ្ញវត្ថុ ការងារសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋជាមួយនាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ ការងារបច្ចេកទេសជាមួយនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងនាយកដ្ឋានជំនាញពាក់ព័ន្ធផ្សេងៗទៀតតាមការចាំបាច់ តាមរយៈលេខាធិការដ្ឋាននៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន។

ទំនាក់ទំនងរដ្ឋបាលតាមប្រព័ន្ធឌីជីថល ត្រូវបានលើកទឹកចិត្ត។

**ប្រការ៣៤ ..**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន មានតួនាទីនិងភារកិច្ច ពាក់ព័ន្ធយន្តការការងារនិងការគ្រប់គ្រងរដ្ឋបាល ដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការអភិវឌ្ឍន៍គ្រឹះស្ថានរយៈពេលខ្លី មធ្យម និងវែង
- រៀបចំផែនការសកម្មភាពការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង បំណែងចែកភារកិច្ច ក្រុមគ្រូឧទ្ទេសតាមមុខវិជ្ជាឯកទេស កន្លែងធ្វើការ របស់ក្រុមគ្រូឧទ្ទេស បុគ្គលិកអប់រំ និងដោះស្រាយបញ្ហានានាដែលកើតមាន
- រៀបចំប្រាក់ម៉ោងបន្ថែម និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនដល់បុគ្គលិកអប់រំក្នុងគ្រឹះស្ថាន
- ចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ការជម្រះបញ្ជីសារពើភណ្ឌ និងការងារលទ្ធកម្ម
- សហការ ទំនាក់ទំនងជាមួយអាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិពាក់ព័ន្ធកិច្ចដំណើរការរបស់គ្រឹះស្ថាន
- លើកសំណើផ្តល់ប័ណ្ណសរសើរ ដំឡើងឋានន្តរសក្តិ ឬការលើកទឹកចិត្តផ្សេងៗទៀតតាមទំហំការងារ និងចាត់តាំងបុគ្គលិកចូលរួមក្នុងសិក្ខាសាលានិងកម្មវិធីផ្សេងៗ

- រៀបចំគ្រប់គ្រងសណ្ដាប់ធ្នាប់ ការរស់នៅរបស់គ្រូ និងគរុសិស្ស គរុនិស្សិតក្នុងអន្តេវាសិកដ្ឋាន
- កែលម្អបរិស្ថានសាលារៀន និងបរិស្ថានសិក្សា
- រៀបចំការចុះពិនិត្យតាមដានការបង្រៀនរបស់គ្រូចេញថ្មី
- គ្រប់គ្រងសាលាអនុវត្តន៍ឱ្យដំណើរការល្អ
- រៀបចំរបាយការណ៍សមិទ្ធកម្ម និងរបាយការណ៍លទ្ធផលការងារ។

**ប្រការ៣៥ ._**

លេខាធិការដ្ឋានគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ត្រូវផ្សព្វផ្សាយរាល់ការសម្រេចទាំងឡាយរបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនដល់នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពពាក់ព័ន្ធ។

**ប្រការ៣៦ ._**

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវធ្វើរបាយការណ៍លទ្ធផលការងារ មកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈលេខាធិការដ្ឋានគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន។

## ជំពូកទី៤
## គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនផ្សេងទៀត

**ប្រការ៣៧ ._**

គោលការណ៍គ្រប់គ្រងបុគ្គលិក គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គ្រប់គ្រងបច្ចេកទេស និងការគ្រប់គ្រងសាលាអនុវត្តន៍របស់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនផ្សេងទៀត ដែលមិនបានកំណត់ក្នុងអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្ដីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមគោលការណ៍ និងយន្តការការងារគ្រប់គ្រងដែលកំពុងអនុវត្តជាធរមាន។

**ប្រការ៣៨ ._**

សាលាអនុវត្តន៍នៃគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ដែលមិនបានកំណត់ក្នុងអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្ដីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមគោលការណ៍កំណត់ការគ្រប់គ្រងសាលាអនុវត្តន៍ក្នុងផ្នែកទី៥ ប្រការ២៥ ប្រការ២៦ ប្រការ២៧ ប្រការ២៨ ប្រការ២៩ ប្រការ៣០ ប្រការ៣១ និងប្រការ៣២ នៃប្រកាសនេះ។

## ជំពូកទី៥
## ខ្សែគណនេយ្យភាព

**ប្រការ៣៩ .-**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា លើភារកិច្ចរបស់ខ្លួនក្នុងការងារបណ្តុះបណ្តាលគ្រូបង្រៀនស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយផែនការយុទ្ធសាស្ត្រស្តង់ដា និងកម្មវិធីកំណែទម្រង់នានារបស់ក្រសួង និងរាជរដ្ឋាភិបាល។

**ប្រការ៤០ .-**

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានគណនេយ្យភាពចំពោះមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត លើការងាររដ្ឋបាល ការងារសម្របសម្រួលដំណើរការប្រឡង និងការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ៤១ .-**

មន្ទីរអប់រំ យុវជន និងកីឡាត្រូវមានគណនេយ្យភាពចំពោះក្រសួងអប់រំ យុវជន និងកីឡាលើគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន អំពីការងាររដ្ឋបាល ការងារសម្របសម្រួលដំណើរការប្រឡងជ្រើសរើស ការត្រួតពិនិត្យតាមដាន និងការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ៤២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១កើត ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០២០

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

-ដើម្បីជូនជ្រាប-

- ដូចប្រការ៤៣

-ដើម្បីអនុវត្ត-

- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋាននីតិកម្ម